អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 17-July-2017, 08:00
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្ដីនៅដំណាក់កាលពីរ
# លើសេចក្ដីសន្និដ្ឋានផ្ទាល់មាត់បិទបញ្ចប់កិច្ចពិភាក្សាដេញដោល
# សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧**

**ម៉ោង ០៩:០០នាទី**

**សវនាការលើកទី៥០២**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន  ជាប្រធាន
ចៅក្រម យ៉ា សុខន
ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*
ចៅក្រម យូរ ឧត្តរា
ចៅក្រម ម៉ាទីន ខារ៉ុបគីន
*(Judge Martin KAROPKIN)*
ចៅក្រម ធូ មណី (បម្រុង)

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ័ង
កញ្ញា ស្តាវ៉ូរូឡា ប៉ាប៉ាដូពូឡូស
*(Ms.Stavoroula PAPADOPOULOS)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង
លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*
លោក វីល្លៀម ស្មីត *(Mr. William Smith)*
លោក សេង ប៊ុនឃាង
លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d’ESTMAEL)*
លោក ឌេល លីសាក់ *(Mr. Dale Lysak)*
លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី
*(Mr. Joseph Andrew BOYLE)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

លោកស្រី ដូរីន ជិន *(Ms. Doreen CHEN)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡៅ ជុនធី

លោក ហុង គឹមសួន

លោក វ៉េន ពៅ

លោក គឹម ម៉េងឃី

លោកស្រី ជេត វណ្ណលី

លោកស្រី ទី ស្រ៊ីនណា

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី សួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក ខេល លីសាក់ | អង់គ្លេស |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| លោកស្រី ជា លាង | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:១៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ ធ្វើសវនាការស្ដាប់សន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលលើសំណុំរឿង០០២ ដែលនឹងធ្វើឡើងដោយសហព្រះរាជ-អាជ្ញា។

ក្រឡាបញ្ជីសវនាការកញ្ញា ជា ស៊ីវហ័ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមកិច្ចដំណើរការសវនាការនៅថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន។ សម្រាប់សវនាការស្ដាប់សេចក្ដីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះ មានវត្តមាន។ លើកលែងតែលោក ពេជ អង្គ សហមេធាវីជាតិនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានជូនដំណឹងមកថា គាត់នឹងអវត្តមាននៅក្នុងសវនាការនៅថ្ងៃនេះ ដោយមូលហេតុផ្ទាល់ខ្លួន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមាន នៅក្នុងបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សូមអរគុណលោកប្រធាន។

[០៩:០៣:៣១]

**ប្រធានអង្គជំនុំ៖**

អរគុណកញ្ញា ជា ស៊ីវហ័ង។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ ដែលបានបញ្ជាក់ថា ដែលគាត់មានបញ្ហាសុខភាពឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខ ឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូល

រួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យ ព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះ ថាមានអាការៈវិលមុខ ឈឺចង្កេះជាប្រចាំ និងបានផ្ដល់អនុសាសន៍ថា សុំឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់មួយស្ថិតក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន ៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួមតាមដានកិច្ចដំណើរការសវនាការ ពីចម្ងាយនៅក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិ ដើម្បីបន្តធ្វើការ ធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន។

[០៩:០៥:១៨]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម សូមជម្រាបសួរភាគីទាំងអស់។ នៅពេលដែលយើងឈប់សម្រាកកាលពីម្សិលមិញ ខ្ញុំបាននិយាយអំពីឧក្រិដ្ឋកម្មនៃការដាក់<>ឃុំឃាំង ហើយនិងការដកហូតនូវសេរីភាពរបស់មនុស្សរាប់ពាន់នៅមន្ទីរសន្តិសុខនោះ ដោយមិនមានដំណើរការនីតិវិធីអ្វី<ទាល់>តែសោះ។

ឥឡូវនេះ ខ្ញុំនឹងលើកឡើងអំពីប្រធានមួយ ដែលគេលើកឡើងជាច្រើនដងរួចមកហើយ នៅពេលដែលយើងពិនិត្យមើលទៅលើភស្តុតាងទាក់ទងទៅនឹងការចាប់ខ្លួនមនុស្ស ហើយនិងបញ្ជូនទៅមន្ទីរសន្តិសុខរបស់កម្ពុជាប្រជាធិបតេយ្យ។ ហើយនេះគឺជាការប្រើប្រាស់ចម្លើយសារភាពមកពីស-២១ ដែលយើងនឹងពិភាក្សានៅពេលក្រោយ គឺចម្លើយសារភាពដែលទទួលបានដោយការធ្វើទារុណកម្ម គឺការ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ឆ្លើយដាក់<គ្នា>ទៅវិញទៅមក ហើយវាជាមូលដ្ឋានសម្រាប់ការចាប់ខ្លួនបន្ថែមទៀត<>។

[០៩:០៦:២៧]

នៅអូរកន្សែង យើងបានស្ដាប់ឮ នោម សែ ដែលជាប្រធានមន្ទីរសន្តិសុខ ហើយនិងអនុប្រធានរបស់គាត់គឺ ឈិន គឹមថុង ដែលពួកគាត់ទាំងពីរបានមកផ្ដល់សក្ខីកម្មថា ចម្លើយសារភាពត្រូវបានផ្ញើពីភ្នំពេញទៅលេខាកងពល៨០១ ស សារឿន ហៅ រឿន នោះ។ ហើយទាហានកងពលដែលមានឈ្មោះនៅក្នុងចម្លើយសារភាពនេះត្រូវបានចាប់ខ្លួន ហើយត្រូវគេបញ្ជូនទៅគុកកងពលនៅអូរកន្សែង។ យើងឃើញអំពីការអះអាងរបស់សក្ខីកម្មនៅក្នុងឯកសារចម្លើយសារភាពរបស់មន្ទីរស-២១ ផងដែរ ដែលនៅក្នុងចម្លើយសារភាពនោះ គឺមានអក្សរសរសេរដៃរបស់ សុន សេន ផ្ញើជូនលេខាកងពល រឿន ស្នើឲ្យគាត់ពិនិត្យទៅលើចម្លើយសារភាព ហើយនិងចាប់ឈ្មោះដែលពាក់ព័ន្ធពី៨០១។

យើងក៏ឃើញ<ភាពស៊ីសង្វាក់គ្នា>ផងដែរ គឺរបាយការណ៍ថ្ងៃ២៩ មីនា ១៩៧៧ គឺឯកសារ E3/1060 គឺជារបាយការណ៍មកពីលេខាភូមិភាគផ្ញើជូន សុន សេន។ ខ្ញុំសូមដកស្រង់៖ "យើងតាមដានសភាពការណ៍<សមាសធាតុ>ទាំងថ្មី ទាំងចាស់ គឺអ្នកទំនាស់<ដែលនាំឲ្យអន្តរាយដល់បដិវត្តន៍។ គោលដៅទាំងនោះរួមមានអ្នកប្រឆាំងមាគ៌ាបដិវត្តន៍ ហើយនឹងអ្នកដែលខ្លាំងឆ្លើយដាក់។"> យើង<ក៏>ឃើញនូវភស្តុតាងដដែលនៅភ្នំក្រោល គឺតំបន់១០៥។ កម្មាភិបាលមកពីតំបន់១០៥ គឺកម្មាភិបាលជាន់ខ្ពស់ត្រូវបានស្ដាប់ចម្លើយដោយ ក.ស.ច.ស ប៉ុន្តែគាត់បានស្លាប់បាត់ទៅហើយ មុនពេលដែល<ការជំនុំជម្រះ>នេះចាប់ផ្ដើម។ គឺគាត់ថាឃើញចម្លើយសារភាព ដែលគេបញ្ជូនមកពី -- គឺគេបញ្ជូនទៅ<ប្រធាន>យោធា<>តំបន់១០៥។ គឺយើងឃើញសារទូរលេខដែលនៅសល់របស់<លេខាតំបន់> សៅ សា<រុន> ដែលផ្ញើជូនទៅមេដឹកនាំនៅភ្នំពេញ ទាក់ទងទៅនឹងសមមិត្ត សុត ដែលប្រព្រឹត្តខុសសីលធម៌ជាមួយនារីម្នាក់ ហើយបណ្ដាលឲ្យមានការចាប់ខ្លួន<ទាំងពីរនាក់>។ សា<រុន បានកត់សម្គាល់>ថា សុត ត្រូវបានគេឆ្លើយដាក់ពីមុនមកដោយ អា<ជួន> អាក្បត់ <ជួន>។ ហើយគាត់សុំការណែនាំពីមជ្ឈិម អំពីអ្វីដែលត្រូវធ្វើចំពោះអាក្បត់មួយនេះ។

[០៩:០៩:២២]

ហើយលោក លោកស្រីចៅក្រម អាចកត់សម្គាល់ឃើញផងដែរថា នៅក្នុងសារទូរលេខនេះ នៅផ្នែកខាងលើខាងស្ដាំ គឺបានបញ្ជាក់ថាឯកសារនេះគឺត្រូវបញ្ជូនទៅ នួន ជា ជាពិសេស។ នៅក្នុងសក្ខីកម្មរបស់គាត់នៅក្នុងតុលាការនេះ សៅ សា<រុន> បានទទួលស្គាល់ថា បានបញ្ជូនសារទូរលេខនេះ ហើយ

គាត់ក៏ទទួលស្គាល់ផងដែរថា គាត់ទទួលបានឈ្មោះមកពីខាងមជ្ឈិម គឺឈ្មោះរបស់កម្មាភិបាលតំបន់ ១០៥ ដែលត្រូវបានគេឆ្លើយដាក់នៅក្នុងចម្លើយសារភាពស-២១របស់ <ជួន>។ <ជួន ធ្លាប់ធ្វើ>ជាប្រធានមន្ទីរពាណិជ្ជកម្មតំបន់។ សា<រុន> បានអះអាងថា គាត់ទទួលបានការណែនាំពីមេដឹកនាំនៅភ្នំពេញឲ្យដោះលែងសមមិត្ត សុត ប៉ុន្តែយើងឃើញថា នៅក្នុងសវនាការនេះ គឺបញ្ជាក់ថា វាជាការនិយាយកុហកទេ។ សាក្សីពីររូបមកពីតំបន់១០៥ គឺ ចាន់ <តួយ> ហើយនិង ប៊ុន <ឡឹងចូយ> បានបញ្ជាក់ថា <ពួក>គាត់<ទាំងពីរនាក់>ស្គាល់ សុត។ <គាត់ជាមេដឹកនាំល្បីឈ្មោះនៅក្នុងតំបន់នោះទទួលខុសត្រូវលើកម្លាំងការងារ និងជាបងប្អូនរបស់ប្រធានឃោធាតំបន់។ >ហើយពួកគាត់ទាំងពីរនាក់បានបញ្ជាក់ថា ផ្ទុយទៅនឹងអ្វីដែលយើងបានស្តាប់ឮ<ពី> សៅ សា<រុន>, សុត បាត់ខ្លួនពីខេត្តមណ្ឌលគិរី ហើយមិនដែលឃើញម្តងទៀតនោះឡើយ។

ខ្ញុំចង់<រំឭក>ផងដែរថា យើងបានស្តាប់ឮហេតុការណ៍មួយទៀត នៅក្នុងផ្នែកភ្នំក្រោលដែរ ហើយប្រហែលជាលោក លោកស្រីចៅក្រមនៅចាំគឺ ប៊ុន ឡឹងចូយ បានបញ្ជាក់អំពី<ក្រុមមនុស្សរត់គេចទៅ>វៀតណាម<ក្នុងចំណោមនោះម្នាក់មកពីការិយាល័យពាណិជ្ជកម្ម>។ ប្រពន្ធ<ៗ>របស់<របស់ពួកគេ>គឺមិនបានរត់គេចទេ។ <ពួកគេស្ថិតនៅខាងក្រោយ។ ហើយរង្វាន់សម្រាប់រឿងនេះដូចដែល>យើងបានឃើញ<ហើយ គឺ>គេបញ្ជូន<>ទៅស-២១។

ចំពោះមន្ទីរសន្តិសុខស-២១ <លោកចៅក្រមជាទីគោរព!> គឺយើងឃើញថា មានឯកសារជាច្រើន<ណាស់> ហើយឥឡូវនេះ ខ្ញុំសូមបង្ហាញឯកសារមួយដែលជាចម្លើយសារភាពដែលគេបញ្ជូនយកទៅធ្វើជាមូលដ្ឋានដើម្បីការចាប់ខ្លួន គឺឯកសារ គឺលិខិត ខែឧសភា ៧៧ ផ្ញើមកពីកងពល៣១០ ផ្ញើជូន ឌុច ដែលបញ្ជាក់ថា មនុស្សប្រាំពីរនាក់ត្រូវបានបញ្ជូនទៅស-២១ ដោយសារតែឈ្មោះ និងសកម្មភាពរបស់គេត្រូវបានឆ្លើយដាក់នៅក្នុងកំណត់ហេតុចម្លើយសារភាព គឺឯកសារ E3/1050។

[០៩:១២:២៤]

លក្ខណៈនៃការចាប់ខ្លួនតាមអំពើចិត្ត និងក្រៅប្រព័ន្ធតុលាការហ្នឹង គឺបង្ហាញច្បាស់ផងដែរ នៅក្នុងលិខិតដែលផ្ញើជូនចេញពីគណៈកំពង់ផែកំពង់សោមផ្ញើជូន ឌុច នៅថ្ងៃ០១ មិថុនា ៧៧ ទាក់ទងទៅនឹងកម្មាភិបាលមកពីភមិភាគឧត្តរ ដែលត្រូវបានគេបញ្ជូនទៅស-២១។ ឯកសារ E3/1155 គឺឯកសារនេះ បានបង្ហាញថា របបនេះបានប្រើប្រាស់ការចាប់ខ្លួនតាមអំពើចិត្ត។ លិខិតបានសរសេរថា៖ “ជូនចំពោះសមមិត្ត ឌុច ជាទីនឹករឭក និង ជាទីស្រឡាញ់។ ថ្ងៃនេះ សូមបញ្ជូនមនុស្សម្នាក់ឈ្មោះ វង មក

<លោក>។ អានេះជាមនុស្សនៅមន្ទីរភស្តុភារឧត្តរជាមួយ អាធុច។ <ប្រពន្ធវាក៏យ៉ាងនេះ។ វាជា ភឿន របស់ អានី ខាងពាណិជ្ជកម្ម។> សកម្មភាពវាដែលនាំឱ្យបញ្ជូនមក គឺបើកបរឡាន ជាន់ហ្វ្រាំងអូសកង់ សុទ្ធតែ១០, ២០ម៉ែត្រ។ ម្តងវាយកអេឡេវេតទ័រ សម្រាប់លើកអីវ៉ាន់ដ៏តូចទៅអូសអាគ្រុយដ៏ធំ អូសមិនរួចវាដំឡើងកម្លាំងម៉ាស៊ីនទាល់តែក្តៅឡើងក្រហមឆាំង។ ហើយសកម្មភាពចុងក្រោយ គឺបើកអេឡេវេតទ័រចុះភ្នំ វាមិនប្រើប្រាំងទេ បែរជាទម្លាក់ប៉ែលអេឡេវេតទ័រ ឱ្យអូសថ្នល់ជំនួសហ្វ្រាំង។ អ៊ីចឹងហើយ ដោយសារប៉ែលនោះត្រូវអូសតាមថ្នល់ ក៏ខូចបូមអស់មួយ។ វាដោះចេញយកទៅជួសជុល ធ្វើឱ្យប្រេងបូមហូរចេញនៅសល់១០លីត្រ។ គឺដោយគោរព គឺធ្វើដោយឈ្មោះ <គ្រឹន>។" <លោកចៅក្រមជាទីគោរព យើងឃើញហើយ>នៅក្នុងរបបខ្មែរក្រហម <>ការ<>បើកបរដោយខុសបែបហ្នឹង គឺជាហេតុផលគ្រប់គ្រាន់មួយដើម្បីបញ្ជូនមនុស្សម្នាក់ទៅស-២១។

[០៩:១៥:០០]

ហេតុដូច្នេះហើយ យើងចាំបាច់ត្រូវការ -- ហេតុដូច្នេះយើងត្រូវការនូវតុលាការ និងនីតិវិធីដ៏ល្អមួយ មុនពេលដែលយើងអាចដកហូតសេរីភាព ឬក៏សិទ្ធិសេរីភាពរបស់មនុស្សណាម្នាក់។ <ខណៈពេលដែលខ្លឹមសារក្នុងលិខិតនេះស្តាប់ទៅគួរឱ្យអស់សំណើចក្តី ក៏ប៉ុន្តែសាច់រឿងខាងចុង មិនមែនជារឿងលេងសើចនោះទេ។> គាត់គឺជាអ្នកបើកបរ គាត់ជាប្រធានកងវរសេនាតូច ឈ្មោះ <ស្រេង> ស្រ៊ាង <ហៅក្រៅឈ្មោះ វង> ត្រូវបានគេបញ្ជូនទៅស-២១ នៅថ្ងៃ០១ មិថុនា ៧៧ ហើយប្រហែលជាមិនដល់៣អាទិត្យ ក្រោយមកគាត់ត្រូវបានគេយកទៅសម្លាប់។ គាត់គឺមានលេខរៀង ៤.៣១៤ នៅក្នុងបញ្ជីឈ្មោះអ្នកទោសរបស់ ក.ស.ច.ស<ស-២១។ លេខដែលគេពិឃាតគាត់គឺក្នុងឯកសារ E3/2285>។

នៅក្រាំងតាចាន់ក៏មានហេតុការណ៍អាក្រក់ៗកើតឡើងដូចគ្នាដែរ។ បញ្ជីឯកសារ<ក្នុងចំណោមឯកសារនានា>ដែលនៅសល់មកពីមន្ទីរឃុំឃាំងនោះបានបញ្ជាក់អំពីអ្នកទោស២៩រូប គឺជាឯកសារ E3/4083 គឺបានបញ្ជាក់ថា មានអ្នកទោស២៩ ហើយ២០នាក់ដំបូងហ្នឹង គឺភាគច្រើនជាអតីតទាហានលន់ នល់ ត្រូវបានគេរៀបរាប់ថា ចាប់ខ្លួន ដោយសារជាផ្នែកនៃបណ្តាញដែលប្រុងគេចខ្លួនទៅវៀត-ណាម ឬក៏ទៅថៃ។ ហើយអ្នកទោស៧រូបថែមទៀត គឺមានកំហុសដោយសារតែគាត់ធ្វើបាក់ស្នាបព្រា ឬក៏ធ្វើបាក់ចប នៅក្នុងសហករណ៍។ លេខ២៨ បានតវ៉ាថា មិនគួរហូបបបរនោះទេ។ ហើយលេខ២៩ គឺជាអតីតប្រធានភូមិ ឬក៏អតីតមេភូមិចាស់អាយុ៧៣ឆ្នាំ ដែលគាត់លួចម្ហូបអាហារយកទៅហូប។

លោក លោកស្រីចៅក្រម អាចពិនិត្យមើលនៅក្នុង*ស្លាយ*ដែលខ្ញុំបង្ហាញហ្នឹង គឺមានរូបភាព

បង្ហាញ។ ប្រហែលជាពាក់កណ្តាលនៃឯកសារនៅក្រាំងតាចាន់ គឺបង្ហាញថាប្រជាជន -- អ្នកទោសដែលជាប់នៅក្រាំងតាចាន់ គឺជាអតីតអ្នករដ្ឋការរបបសាធារណរដ្ឋ។ នេះគឺផ្អែកទៅលើការពិនិត្យមើលទៅលើឯកសាររបស់ក្រាំងតាចាន់ ហើយ<ការសន្និដ្ឋាន របស់ អៀ មេងទ្រី និង>ហង់រី ឡូកា <គឺមានលក្ខណៈដូចគ្នា នៅពេលដែលគេបានពិនិត្យសិក្សាឯកសារដែលនៅសេសសល់ទាំងនោះ>។

[០៩:១៧:៥១]

លោក លោកស្រីចៅក្រម នៅពេលដែលយើងស្តាប់សក្ខីកម្មរបស់ រៀល សន <អំពីការណែនាំពីគណៈស្រុកត្រាំកក់ ឲ្យបង្ហាញអត្តសញ្ញាណ និង>បោសសម្អាតអតីតលន់ នល់ មានឋានន្តរសក្តិខ្ពស់។ ហើយតារាងទី២នេះ <ក្នុងរូប ១.៦> គឺបង្ហាញថា ប្រហែលជា៧៥ភាគរយនៃអតីតទាហានលន់ នល់ត្រូវបានគេឃុំខ្លួននៅក្រាំងតាចាន់ ហើយពួកគាត់មានឋានៈចាប់ពីមេប៉ូលិស ឬក៏ខ្ពស់ជាងនេះទៅទៀត។ ទាក់ទងទៅនឹង<ការ>បោសសម្អាតអតីតមន្ត្រីរដ្ឋ និងកងទ័ព លន់លន់ មេធាវីការពារក្តីបានផ្តល់នូវសាក្សីដែលផ្ទុយពីនេះ ទៅលើបញ្ហានេះ លោក សៅ វ៉ាន់។ យើងត្រូវចងចាំថា គាត់គឺជាបុគ្គលម្នាក់ដែលបានចាកចេញពីត្រាំកក់ តាំងពីពេលដំបូងនៅក្នុងរបបនេះម៉្លេះ។ ហើយម្យ៉ាងទៀត គាត់ត្រូវបានគេចាប់ទុក ឬចាប់ ដោយសារតែបងប្អូនប្រុសរបស់គាត់ហ្នឹង គឺជាអតីតទាហាន លន់ លន់។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក្នុងចំណោមសក្ខីកម្មទាំងអស់របស់សាក្សី អំពីគោលនយោបាយនៅត្រាំកក់វិញ គឺទោះបីជាមានការយល់ជំទាស់ខុសគ្នាយ៉ាងម៉េចក៏ដោយ ប៉ុន្តែរបាយការណ៍ដែលនៅសល់បានបញ្ជាក់យ៉ាងច្បាស់ថា មានគោលនយោបាយ ហើយនិងមានការណែនាំពីថ្នាក់លើមកថ្នាក់ក្រោម ដើម្បីបោសសម្អាតអតីតទាហាន លន់ លន់។ ខ្ញុំបានបង្ហាញឯកសារនេះ ជូនដល់លោក លោកស្រីចៅក្រមរួចទៅហើយ ដូច្នេះថ្ងៃនេះ ខ្ញុំគ្រាន់តែរំឭកនូវឯកសារចំនួនពីរតែប៉ុណ្ណោះ។ នេះគឺជារបាយការណ៍ខែមេសា ៧៧ មកពីឃុំជាងទង ដែលនិយាយអំពីការណែនាំជាបន្តបន្ទាប់ពីអង្គការឲ្យបោសសម្អាតមន្ត្រីខ្មាំង ហើយបានកំណត់នូវបុគ្គលមួយចំនួនដែលជាអតីតរដ្ឋការរបបមុន។ ហើយឯកសារបន្តគឺឯកសារ ខែឧសភា ឆ្នាំ៧៧ ជារបាយការណ៍មកពីឃុំពពេល ដែលបញ្ជាក់ថា គ្រួសារ១០៦គ្រួសារដែលមានសរុបចំនួន៣៩៣ របស់អតីតទាហានរបបមុនត្រូវបានកម្ទេច។ ហើយឃុំនៅស្វែងរកថាតើមានគ្រួសារដែលនៅសេសសល់ដែរឬអត់ ជាគ្រួសារទាហានរបបមុន។

[០៩:២០:៣៣]

លោក លោកស្រីចៅក្រម ការចាប់ខ្លួន និងការឃុំខ្លួនមនុស្សព្រោះថា ពួកគេ ឬក៏សាច់ញាតិ

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

របស់ពួកគេហ្នឹង មានតួនាទី ឬក៏គាំទ្ររបបមុនហ្នឹង គឺមិនមែនជានីតិវិធីដ៏ត្រឹមត្រូវនោះឡើយ វាជាការធ្វើទុក្ខបុកម្នេញ គឺសាមញ្ញដូច្នេះឯង វាជាការធ្វើទុក្ខបុកម្នេញ។

ពាក់ព័ន្ធទៅនឹងក្រាំងតាចាន់ដូចគ្នានេះដែរ សាក្សីទី១ដែលបានមកផ្តល់សក្ខីកម្មនៅក្នុងសវនាការនេះ ប្រហែលជា២ឆ្នាំមុនគឺ មាស សុខា។ សមាជិកគ្រួសារគាត់សឹងតែទាំងអស់ ត្រូវបានគេចាប់ខ្លួន និងឃុំខ្លួននៅក្រាំងតាចាន់ អស់រយៈពេលរាប់ឆ្នាំ ព្រោះតែឪពុករបស់គាត់ និងបងថ្លៃរបស់គាត់ប៉ាន់បោះឆ្នោតទម្លាក់មេភូមិ។ សក្ខីកម្មរបស់គាត់ត្រូវ<គ្មានឹង>កំណត់ត្រារបស់មន្ទីរឃុំឃាំងជាច្រើនដែលបញ្ជាក់អំពីការចាប់ខ្លួនទាំងអស់នោះ។ ឧទាហរណ៍ដូចជា បញ្ជីអ្នកទោសខែឧសភា ៧៨ ដែលត្រូវបានឃុំឃាំងអស់រយៈពេលរាប់ខែ ឬរាប់ឆ្នាំ ហើយចុះហត្ថលេខាដោយប្រធានគុកក្រាំងតាចាន់ ឈ្មោះអាន។ ក្នុងបញ្ជីនេះគឺមាន<ទាំង>ម្តាយរបស់ មាស សុខា, ប្អូនស្រី ហើយនិងយោងផងដែរទៅលើការសម្លាប់ឪពុករបស់គាត់ និងបងថ្លៃរបស់គាត់។ ហើយនៅក្នុងបញ្ជីដដែលនេះ គឺមានឈ្មោះ <វង> សារុន <ត្រង់លេខ៤>គឺជាពេទ្យនារីដែលបានផ្តល់សក្ខីកម្មនៅក្នុងតុលាការនេះផងដែរ នៅផ្នែកចុងក្រោយនៃក្រាំងតាចាន់ អំពីការឃុំខ្លួន<កូន>របស់គាត់នៅក្រាំងតាចាន់។ ហើយប្រសិនបើយើងមើលទៅលើបញ្ជីដដែលនេះ ប្រសិនបើយើងមើលទៅកំណត់ត្រា<ដដែលហ្នឹង>នៅខាងស្តាំ គឺបានបញ្ជាក់ដោយ <អ៊ុច ហាន> ថា "នារីទាំងពីរនាក់នេះ <ត្រូវបានឆ្លើយដាក់ដោយ ហាន ធ្វើការ>នៅពេទ្យ២២"។

[០៩:២២:៤៣]

លោក លោកស្រីចៅក្រម! ដោយសារតែសហការីរបស់គាត់ឆ្លើយដាក់ឈ្មោះគាត់នៅក្នុងចម្លើយសារភាព ដោយសារតែការធ្វើទារុណកម្ម <ឬដោយសារការភ័យខ្លាច> ទើបធ្វើឲ្យ<វង> សារុន ហើយនិងកូនតូចរបស់គាត់ ត្រូវគេឃុំរយៈពេលមួយឆ្នាំកន្លះ នៅក្រាំងតាចាន់។ ឥឡូវនេះ ខ្ញុំសូមបង្ហាញនូវស្ថានភាពអមនុស្សធម៌ដែលគាត់ ហើយនិងអ្នកទោសដទៃទៀត ត្រូវបានគេឃុំនៅមន្ទីរឃុំឃាំងទាំងអស់នេះ ហើយនិងការលំបាកនានាដែលពួកគាត់ត្រូវប្រឈម។ ចំពោះប្រធានបទនេះ ខ្ញុំនិយាយអំពីគុកចំនួនបួន។ ដោយសារតែភស្តុតាងដែលលោក លោកស្រីចៅក្រមបានស្តាប់ឮ បានបង្ហាញយ៉ាងច្បាស់នូវទិដ្ឋភាពនៃការរស់នៅ ក៏ដូចជាទិដ្ឋភាពនៃការឃុំខ្លួន<របស់អ្នកដែលគេបោះត្រាថាជាខ្មាំង>នៅក្នុងមន្ទីរសន្តិសុខទាំងអស់នេះ រួចហើយ។ មានអង្គហេតុចំនួនប្រាំទាក់ទងទៅនឹងស្ថានភាពអមនុស្សធម៌ដែលអ្នកទោសទាំងអស់នេះត្រូវទទួលរង ហើយវាជាស្ថានភាពទូទៅមួយចំពោះមន្ទីរសន្តិសុខទាំងអស់។ លេខ១ អ្នកទោសត្រូវបានគេដាក់ខ្នោះដាក់ឃ្នាង នៅក្នុងបន្ទប់ឃុំឃាំង។ លេខ២ អ្នកទោសត្រូវបន្ទោបង់ទាំង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

<ជើង>ជាប់ខ្នោះនៅក្នុងគុក។ លេខ៣ គ្មានអនាម័យទាល់តែសោះ។ លេខ៤ អ្នកទោសមិនទទួលបានម្ហូបអាហារគ្រប់គ្រាន់។ ហើយលេខ៥ គឺអ្នកទោសធ្លាក់ខ្លួនឈឺ ប៉ុន្តែមិនទទួលបានការព្យាបាលត្រឹមត្រូវនោះឡើយ ហើយភាគច្រើនស្លាប់ដោយសារជំងឺ។

[០៩:២៤:២៤]

ឥឡូវនេះ ខ្ញុំសូមលើកយកនូវភស្តុតាងមួយចំនួនដើម្បីបង្ហាញទៅលើអង្គហេតុទាំងអស់នេះ។ ទាក់ទងទៅនឹងការដាក់ខ្នោះជើង យើងបានស្តាប់ឮថា<>អ្នកទោសត្រូវបានគេដាក់ខ្នោះជើងទាំងយប់ទាំងថ្ងៃ លើកលែងតែអ្នកមួយចំនួនតូចដែលគេចាត់ទុកថា អ្នកទោសស្រាល ហើយគេឱ្យធ្វើការនៅខាងក្រៅ។ នៅគុកធំ ជាទូទៅ គឺគេភ្ជាប់ខ្នោះជើងទៅនឹងបង្គោលដែក<វែង>មួយហើយអ្នកទោសដេកនៅលើកម្រាលឥដ្ឋជាជួរ ដូចដែលយើងឃើញនៅក្នុងរូប<>ដែល វ៉ាន់ ណាត បានគូរ។ នៅក្នុងរូបនេះ គឺយើងឃើញខ្នោះដែលគេប្រើប្រាស់ដាក់អ្នកទោស ហើយដែលនៅសល់ពីមន្ទីរស-២១ ហើយនិងនៅក្រាំងតាចាន់ផងដែរ។

ហើយនៅក្នុងរូបថតបន្ទាប់ ខ្ញុំសូមបន្តទៅ*ស្លាយ*បន្ទាប់។ នេះគឺជារូបថតដែល ឌុច បានបញ្ជាក់រួចទៅហើយ គឺជារូបថតរបស់ កុយ ធួន អតីតលេខាភូមិភាគឧត្តរ គាត់ត្រូវបានគេដាក់ខ្នោះនៅក្នុងគុក នៅពេលដែលគេសួរ<ចម្លើយ>គាត់នៅក្នុងបន្ទប់ឃុំឃាំងពិសេសរបស់គាត់នោះ។ ប្រធានគុកអូរកន្សែងក៏ទទួលស្គាល់ផងដែរ ពីការប្រើប្រាស់ខ្នោះឃ្នាងដែក និងខ្នោះឈើផងដែរ។ ហើយគាត់បញ្ជាក់ផងដែរ ថា<អ្នកទោសធ្ងន់ត្រូវដាក់ខ្នោះជើងរបៀបនេះ គ្រប់ពេលវេលា>សូម្បីតែ<ពេលដេក>នៅពេលយប់<ក៏ដោយ>។ ទាក់ទងចំពោះភ្នំក្រោលវិញ នែត សាវ៉ាត បានរៀបរាប់នៅក្នុងតុលាការនេះផងដែរថា មានមួយថ្ងៃនោះគេយកគាត់ទៅជាន់ទី២នៃមន្ទីរក-១៧ ហើយគាត់បានឃើញទាហានកងពល៩២០ ត្រូវបានគេឃុំឃាំងខ្លួនដោយ<កជើងជាប់>ខ្នោះ<ឈើ>។ អ្នកដែលនៅរស់រានមានជីវិតមកពីក្រាំងតាចាន់ ឈ្មោះ <វង> សារុន បាននិយាយអំពីផលប៉ះពាល់នៃការដាក់ខ្នោះជើងដែលគាត់ទទួលរង<បែបនេះដែរ>។ គាត់បាននិយាយថា <ខ្ញុំសូមដកស្រង់៖ “>ខ្ញុំគ្មានកម្លាំងដើរនោះទេ ហើយខ្ញុំទៅជាស្ពឹកកជើង ដោយសារតែខ្ញុំត្រូវបានគេដាក់ខ្នោះ។ នៅពេលដែលខ្ញុំដើរទៅបន្ទប់ឃុំសួរចម្លើយនោះ ខ្ញុំមិនទាំងដឹង មិនទាំងអាចដឹងថាជាជើងខ្ញុំផង។” ចំណុចទី២ គឺថាអ្នកទោសនៅមន្ទីរសន្តិសុខទាំងអស់នេះត្រូវបន្ទោបង់ ទាំងបត់ដែបត់ជើង ទាំងជាប់ខ្នោះឃ្នាងនៅក្នុងបន្ទប់ឃុំខ្លួនរបស់គេ ហើយគេបន្ទោបង់ដាក់សំបកដូង ឬ<បំពង់ឫស្សី ឬ>ក៏ធុងឈើ ពេលខ្លះគេប្រើប្រាស់កេសគ្រាប់។ ហើយធុងបន្ទោបង់នេះ

ត្រូវហុចពីអ្នកទោសមួយទៅអ្នកទោសមួយ ដូចដែល ជុំ ម៉ី បានផ្តល់សក្ខីកម្មដែរ គឺពួកគេហូប ហើយ និងគេងនៅក្នុងបន្ទប់តែមួយដែលពួកគេបន្ទោបង់នោះឯង។

[០៩:២៧:៤១]

ចំណុចទី៣ ដោយសារតែមិនមានអនាម័យ អ្នកទោសកើតចៃពេញខ្លួន។ ហើយបន្ទប់ឃុំឃាំងរបស់គេពេញទៅដោយសត្វល្អិត ហើយនិងកណ្តុរ។ ដូចដែល វ៉ាន់ ណាត រៀបរាប់នៅក្នុងសៀវភៅរបស់គាត់ គឺ "ទិដ្ឋភាពគុកកម្ពុជា" ខ្ញុំសូមដកស្រង់៖ "រាងកាយខ្ញុំចុះអន់ខ្សោយទៅ អន់ខ្សោយទៅ។ ឆ្អឹងជំនីរបស់ខ្ញុំលេចចេញមកក្រៅ ហើយខ្លួនខ្ញុំមើលទៅដូចមនុស្សចាស់អាយុ៧០ឆ្នាំ។ សក់ខ្ញុំឡើងកន្ទ្រើងដូចឫសឫស្សី ហើយវាក្លាយទៅជាសំបុកចៃ។ ខ្ញុំកើតដំបៅពេញខ្លួន។ ហើយអារម្មណ៍ហើយនិងចិត្តរបស់ខ្ញុំហោះហើរទៅឆ្ងាយ។ ខ្ញុំដឹងតែម៉្យាងគត់គឺឃ្លាន។" <បញ្ចប់ការដកស្រង់។> ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ដែលត្រូវបានគេឃុំខ្លួន៤ឆ្នាំនៅក្រាំងតាចាន់ បានរៀបរាប់អំពីស្ថានភាពដូចគ្នានៅគុកនោះ។ ខ្ញុំសូមដកស្រង់៖ "យើងមិនអាចនៅស្ងៀមបានទេ ដោយសារតែមានសង្កើច ហើយចៃខាំយើងគ្រប់ពេល។ ខ្ញុំសម្លាប់ចៃប្រហែលជារាប់លាន ដោយញោចនឹងឥដ្ឋ ឬមួយក៏ទះនឹង ញោចលើបាតដៃរបស់ខ្ញុំ។ ចៃហ្នឹងខាំយើងខ្លាំងពេក ដល់ស្បែកយើងស្ពឹកលែងដឹងឈឺទៅហើយ។" អតីតសមាជិកក្រាំងតាចាន់ ឈ្មោះ អ៊ាប ឌុច ដែលគេហៅថា ឌុច ធំហ្នឹង បានរៀបរាប់ប្រាប់ ក.ស.ច.ស អំពីទិដ្ឋភាពនៅពេលដែលគាត់ឃើញ នៅពេលដែលគាត់ទៅក្រាំងតាចាន់។ ខ្ញុំសូមដកស្រង់៖ "នៅពេលដែលខ្ញុំចូលពេលដែលគេបើកទ្វារខ្ញុំធំក្លិនស្អុយ ហើយឃើញមនុស្សទាំងអស់។ ខ្ញុំឱ្យគេបិទទ្វារ ខ្ញុំមិនចង់មើលតទៅទៀតនោះទេ។" <វង> សារុន បានផ្តល់សក្ខីកម្មថា នៅពេលដែលគាត់ចូលទៅក្នុងបន្ទប់ឃុំខ្លួន គាត់ធុំក្លិនខ្មោច។

[០៩:៣០:១១]

ចំណុចទី៤ អ្នកទោសនៅមន្ទីរសន្តិសុខទាំងអស់នេះ សឹងតែមិនដែលទទួលបានរបបអាហារ។ ពួកគេស្រេកឃ្លាន ហើយចុះខ្សោយជាបន្តិចម្តង បន្តិចម្តង <ហើយចុះស្គមយ៉ាងគំហុក មើលលែងយល់>។ <ស៊ុន វុធ> ដែលត្រូវបានឃុំខ្លួននៅក្នុងគុកភ្នំក្រោល បានផ្តល់សក្ខីកម្មថា គាត់មិនបានទទួលអាហារអីទាល់តែសោះនៅថ្ងៃទី១ ដែលគាត់ត្រូវបានគេឃុំខ្លួន។ ហើយបន្ទាប់មក គាត់ទទួលរបបអាហារជាបាយ ដែលមានទំហំប៉ុនមួយក្តាប់ដៃរបស់គាត់។ មាស សុខា បានរៀបរាប់ថា ម្តាយរបស់គាត់មិនមានអាហារហូបគ្រប់គ្រាន់ ដូច្នេះហើយគាត់មិនមានទឹកដោះ ទើបធ្វើឱ្យប្អូនតូចៗរបស់គាត់ពីរ

នាក់ស្លាប់ដោយសារតែអត់មានទឹកដោះ <ពីរទៅបីខែក្រោយពេលដែលគេត្រូវជាប់នៅមន្ទីរក្រាំងតាចាន់>។ ហើយនៅក្នុងបន្ទប់សវនាការខែមិថុនា ឆ្នាំ២០០៩ វ៉ាន់ ណាត បានផ្តល់សក្ខីកម្មដូចតទៅ សូមដកស្រង់៖ “ស្ថានភាពគឺអមនុស្សធម៌មែនទែន ហើយចំណីអាហារតិចតួច<ណាស់>។ ហើយគេមានឆ្នាំងបបរមួយធំ ដែលត្រូវចែកបបរទៅឲ្យអ្នកទោស៥០ទៅ៦០ គឺយើងទទួលបានបបរតែបីស្លាបព្រាទេក្នុងមួយពេល ហើយស្លាបព្រាហ្នឹងគឺថាតូចប៉ុននឹងស្លាបព្រាកាហ្វេ។ ខ្ញុំបាត់បង់កិត្តិយស កេរ្តិ៍ឈ្មោះរបស់ខ្ញុំដោយសារតែស្ថានភាពរបស់អ្នកទោស ហើយនិងអ្នកយាម វាខុសគ្នាមែនទែន។ ហើយប្រៀបធៀបទៅអ្នកទោសគឺថាដូចសត្វធាតុអ៊ីចឹង សូម្បីតែសត្វធាតុក៏ដោយ ក៏គេឲ្យចំណីអាហារវាគ្រប់គ្រាន់ដែរ។ ខ្ញុំមិនបានគិតពីអ្វីក្រៅពីការស្រេកឃ្លាននោះទេ។ ខ្ញុំស្រេកឃ្លានមែនទែន ហើយខ្ញុំមិនដែលជួបប្រទះបទពិសោធន៍បែបនេះទេពីមុន ហើយខ្ញុំបានគិតថា បើសិនណាជាអាចស៊ីសាច់មនុស្សបាន ក៏វាជាម្ហូបអាហារមួយដ៏ឆ្ងាញ់ផងដែរ។” <បញ្ចប់ការដកស្រង់។>

[០៩:៣២:២២]

ចំណុចទី៥ អង្គហេតុចំណុចទី៥ ដោយសារតែលទ្ធផលអាក្រក់ ហើយនិងស្ថានភាពអត់ឃ្លាននេះ អ្នកទោសក៏ធ្លាក់ខ្លួនឈឺ ហើយស្លាប់ជាច្រើន។ មេគុកអូរកន្សែងបានផ្តល់សក្ខីកម្មថា អ្នកទោសស្លាប់ដោយសារតែជំងឺច្រើនជាងដោយសារតែយកទៅសម្លាប់ចោល។ នៅឯក្រាំងតាចាន់<វិញ> មាស សុខា និង សយ សែន បានរៀបរាប់<របៀប>អ្នកទោសហ្នឹងបានស្លាប់នៅក្នុងបន្ទប់ឃុំឃាំង ហើយស្លាប់នៅពេលដែលជាប់ខ្នោះជើងរាប់ម៉ោង ឬក៏ពេញ១យប់តែម្តង រហូតដល់សពទាំងនោះត្រូវបានគេយកចេញ។ <វង់> សា<រុន> បានរៀបរាប់ថា ឪពុករបស់គាត់ និងកូនរបស់គាត់អាយុ១ឆ្នាំហ្នឹងស្លាប់ក្រោយពីឃ្លានខ្លាំង អត់ឃ្លានខ្លាំងពេក។ អ៊ីចឹងគេស៊ីកណ្តុរទាំងរស់តែម្តង។ នៅស-២១ ឯកសារដែលសល់ពីសម័យកាលនោះ គឺឯកសារ E3/833 បានលើកឡើងថា ប្រធានពេទ្យនៅស-២១ ឈ្មោះ ទ្រី គឺខ្លាចមានគេចាប់ខ្លួនដោយសារថាមានអ្នកទោសហ្នឹងស្លាប់ច្រើនពេក។ ហើយនៅក្នុងរបាយការណ៍ត្រួតអ្នកទោសប្រចាំថ្ងៃ ដែលអង្គជំនុំជម្រះបានទទួលយកកាលពីឆ្នាំមុននេះ គឺសៀវភៅពណ៌ទឹកក្រូច ដែលសាស្ត្រាចារ្យឈ្មោះ ហេន ណូស្តិ៍ បានទទួលបាននោះ គឺឯកសារ E3/10770។ នៅក្នុងរបាយការណ៍ប្រចាំថ្ងៃនេះ គឺមានគឺថាបញ្ជាក់ថា អ្នកទោសស្លាប់រាល់ថ្ងៃនៅទួលស្លែង។ ហើយរបាយការណ៍មានសរសេរនៅផ្នែកខាងក្រោម សរសេរដោយដៃតែម្តង។ ឧទាហរណ៍ របាយការណ៍នៅចុះថ្ងៃទី៣០ <> ខែកក្កដា ១៩៧៧ បានលើកឡើងថា សៅ ជិន ហៅ ជេត មកពីបាត់ដំបង គឺជាប្រធានរោងចក្រតម្បាញ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

គឺថាបានស្លាប់ដោយសារតែគាត់<មានជំងឺរាកមួល និង>រងរបួសធ្ងន់ពេក។

[០៩:២៣:៤៥]

<លោក លោកស្រីចៅក្រម ប្រហែលអាចនៅចាំបានថា >អ្នកទោសនៅស-២១ គឺ<គឺជាឪពុក>ដើមបណ្ដឹងរដ្ឋប្បវេណី សុន អែម <ដែល>បានផ្ដល់សក្ខីកម្ម<កាលពីឆ្នាំមុន នៅចំពោះមុខអង្គជំនុំជម្រះថា ឪពុករបស់គាត់មានសុខភាពល្អធម្មតាទេ មុនពេលគេចាប់ខ្លួនគាត់។> ហើយគាត់ក៏បានស្លាប់នៅស-២១នោះ ក្នុងរយៈពេល១ខែក្រោយមក។ <អង្គជំនុំជម្រះក៏ប្រហែលនៅចាំបានដែរ សុន អែម ប្រាប់ថា> ក្រោយពីការចាប់ខ្លួនឪពុករបស់គាត់ និង ពូរបស់គាត់ដែលជាប្រធានមន្ទីរភូមិភាគបស្ចិម សុន អែម នេះគេបានយកមកមន្ទីរអប់រំកែប្រែដែលដឹកនាំដោយ នួន ជា នៅទីក្រុងភ្នំពេញ គឺថាដែលជនជាប់ចោទនេះ ក៏បាន គាត់បាននិយាយ<យ៉ាងច្បាស់>អំពីការចាប់ខ្លួនឪពុកមាររបស់គាត់។

ទាក់ទងទៅនឹងរបាយការណ៍ប្រចាំថ្ងៃ ត្រួតពិនិត្យប្រចាំថ្ងៃអំពីជំងឺនេះ គឺឧបសម្ព័ន្ធ F.៤៨ គឺបានលើកឡើងអំពីចំនួនអ្នកស្លាប់ជាប្រចាំថ្ងៃ សម្រាប់រយៈពេលដែលយើងបានបង្ហាញនូវឯកសារនេះ គឺប្រហែលជានៅក្នុងខែមេសា ឬក៏ខែធ្នូ ឆ្នាំ១៩៧៧ ហើយក្នុងរយៈពេល២៥៨ថ្ងៃ គឺមានអ្នកទោសស្លាប់ដោយសារតែជំងឺបែបនេះរហូតដល់២៣៥នាក់<នៅក្នុងមន្ទីរស-២១ ដូចយើងបានឃើញនៅក្នុងតារាងនេះអ៊ីចឹង។ ក្នុងខណៈពេល>ស្ថានភាពនៅក្នុងគុកនេះ<កាន់តែ>អាក្រក់ទៅ អាក្រក់ទៅពីពេលមួយទៅពេលមួយ ជាពិសេសនៅក្នុងអំឡុងខែតុលា, វិច្ឆិកា និងខែធ្នូ ១៩៧៧ <យើងក៏ឃើញចំនួនអ្នកទោសស្លាប់កាន់តែកើនឡើងដែរ>។

បាទ ដើម្បីបញ្ចប់<វគ្គនៃ>បញ្ហាអំពើអមនុស្សធម៌នេះ លោក លោកស្រីចៅក្រម ជុំ ម៉ី បានរៀបរាប់អំពីភាពគួរឲ្យរន្ធត់ដែលអ្នកទោសបានប្រឈមមុខនៅពេលចូលទៅដល់ ស-២១។ ជាពិសេសគាត់បានលើកឡើងនៅក្នុងសវនាការឆ្នាំ២០០៩ថា គាត់បាននិយាយថា សូមដកស្រង់៖ “លោកសហព្រះរាជអាជ្ញា នៅពេលដែលខ្ញុំចូលទៅដល់បន្ទប់ និង កន្លែងឃុំខ្លួន<នោះ> គឺថាខ្ញុំមិនគិតថាខ្ញុំ<ឯងនេះ> អាចរស់រានមានជីវិតទេ។ នៅពេលនោះ នៅពេលដែលខ្ញុំ គឺខ្ញុំទម្លាក់ខ្លួនទៅសម្រាកទៅ គឺថាគ្រាន់តែរង់ចាំដើម្បីគេយកខ្ញុំទៅសម្លាប់ចោលតែប៉ុណ្ណោះ។” <មុនពេលនិយាយអំពីឧក្រិដ្ឋកម្ម>ការធ្វើទារុណកម្មវិញ<> ខ្ញុំសូមលើកឡើងខ្លីទេ អំពីអ្នករស់រានមានជីវិតមួយចំនួនដូចជា លោក ជុំ ម៉ី។ នៅក្នុងសវនាការនេះ មេធាវីការពារក្ដី នួន ជា បានវាយប្រហារទៅលើ ជុំ ម៉ី <>ដោយលើកឡើងគ្មានមូលដ្ឋានអ្វីថា ជុំ ម៉ី មិន<>ត្រូវបានគេឃុំខ្លួននៅស-២១ នោះទេ ប៉ុន្តែភស្តុតាងបានបង្ហាញអំពីការឃុំឃាំងខ្លួនរបស់

គាត់នៅស-២១ គឺថាមិនអាចប្រកែកបាននោះទេ។ អ្នកទោសដែលជាប់ដែលជាប់ជាមួយគាត់ឈ្មោះ ប៊ូ ម៉េង, អ្នកស្សួរចម្លើយ ប្រាក់ ខន ហើយនិងមេគុក ឌុច នេះតែម្តង ទាំងអស់នេះបានផ្តល់សក្ខីកម្មថា ជុំ មុី នេះគឺពិតជាជាប់នៅស-២១ មែនហើយ។ នៅក្នុងរូបថតរបស់អ្នករស់រានមានជីវិតពី ស-២១ លោក លោកស្រី នឹងឃើញថា ជុំ មុី ដែលនៅផ្នែកខាងឆ្វេងនេះ ជាមួយ វ៉ាន់ ណាត, ប៊ូ ម៉េង ហើយនិងអ្នករស់រានមានជីវិតដទៃទៀត។ មានបញ្ជីអ្នកទោសជាច្រើនដែលបញ្ជាក់អត្តសញ្ញាណរបស់គាត់រួមទាំងបញ្ជីមកពី បញ្ជីចូលទៅគុកស-២១ នៅថ្ងៃទី២៨ តុលា ១៩៧៨។ ហើយក៏មានចម្លើយសារភាពរបស់ ជុំ មុី ដែរ គឺចុះថ្ងៃទី០៨ វិច្ឆិកា ១៩៧៨ ដែលយើងអាចរកឃើញនៅក្នុងកំណត់ហេតុដែលសេសសល់ពីគុកនេះ ដែលហើយនេះ គឺជាភស្តុតាងហើយ។

[០៩:៣៩:០៦]

លោក លោកស្រីចៅក្រម ជាទីគោរព លោក លោកស្រីយល់ច្បាស់ហើយ នេះគឺជាការងាររបស់មេធាវីការពារក្តី ដែលត្រូវជំទាស់តវ៉ាជាមួយនឹងភស្តុតាង ប៉ុន្តែការវាយប្រហារទៅលើអ្នករស់រានមានជីវិត<ចុងក្រោយ>ពីស-២១នេះ គឺថាគ្មាន<គុណធម៌អីសោះឡើយ>។ យើងយល់ឃើញថា វាគ្រាន់តែបញ្ជាក់អំពីការអស់សង្ឃឹម <និង>ចំណុចខ្សោយរបស់ជំហររបស់ក្រុមមេធាវីការពារក្តី នួន ជា តែប៉ុណ្ណោះ។ <ឥឡូវនេះ ខ្ញុំសូមចូលទៅនិយាយ>ពាក់ព័ន្ធទៅនឹងការធ្វើទារុណកម្មនេះតែម្តង គឺថាមានការបញ្ជាក់ហួសពីវិមតិសង្ស័យថា <មាន>ការធ្វើទារុណកម្មត្រូវបានប្រើប្រាស់ដើម្បីទទួលយកចម្លើយ <>នៅមន្ទីរសន្តិសុខរបស់កម្ពុជាប្រជាធិបតេយ្យ។ ភស្តុតាងពីស-២១ ក៏បានបញ្ជាក់អំពីការធ្វើទារុណ-កម្មជាប្រចាំ យ៉ាងលើសលប់ <ហើយមិនអាចប្រកែកបាន>។ ការប្រើប្រាស់ការធ្វើទារុណកម្មនេះ គឺត្រូវបានអ្នករស់រានមានជីវិតរៀបរាប់ <ហើយមាន>អ្នកខ្លះ<>នៅ<តែ>មានស្លាកស្នាមនៅលើខ្លួននៅឡើយ ហើយទទួលការឈឺចាប់យ៉ាងខ្លាំង។ ហើយអ្នកស្សួរចម្លើយគុកនេះ ក៏បានទទួលស្គាល់ដែរ ហើយជាពិសេសគឺដោយមេគុកនេះតែម្តង ជាពិសេស នៅពេលដែលគាត់ត្រូវបានកាត់សេចក្តីនៅចំពោះឧក្រិដ្ឋកម្មនេះតែម្តង។ ពាក់ព័ន្ធទៅនឹងចម្លើយសារភាពដែលនៅសេសសល់ គឺថាយើងបានសំអាងទៅលើវិធីសាស្ត្រផ្សេងៗនៃការធ្វើទារុណកម្មដែលត្រូវបានប្រើប្រាស់ដើម្បីបំបាក់ស្មារតី<អ្នកទោស> និងបង្ខំឱ្យពួកគេឆ្លើយសារភាព។ សៀវភៅមួយដែលទទួលបាន ដែល<ទុកដាក់>ដោយអ្នកស្សួរចម្លើយនៅស-២១ ហ្នឹង <មានផ្ទុកការណែនាំដែលខ្លួនទទួលបាន ឱ្យធ្វើទារុណកម្មជាប្រព័ន្ធនៅក្នុងគុកនោះ។> ដូច្នេះ គ្មានអ្នកណាម្នាក់បដិសេធថា ឧក្រិដ្ឋកម្មនេះ មិនបានកើតឡើងនោះទេ។ ហើយទារុណកម្មដែលប្រើប្រាស់

នៅស-២១នេះ គឺថាមិនមែនជារឿងតូចតាចទេ គឺជាការវាយប្រហារ វាយដំយ៉ាងធ្ងន់ធ្ងរ<បន្សល់ទុករបួសស្នាម> មានការឆក់ខ្សែភ្លើង រហូតដល់សន្លប់បាត់បង់ស្មារតី។ ការគ្របមុខអ្នកទោសដោយស្បោងប្លាស្ទិកដើម្បីឲ្យថប់ដង្ហើម ការដកក្រចកដៃ ក្រចកជើង។ នៅថ្ងៃអង្គារនេះ <មេធាវី>ដើមបណ្ដឹងរដ្ឋប្បវេណីបាន -- ចាក់បង្ហាញជូនលោក លោកស្រីចៅក្រម អំពីសក្ខីកម្មរបស់ ជុំ ម៉ី ដែលគាត់ទទួលរងការឈឺចាប់នោះ នៅក្នុងអំឡុងពេលដែលគាត់ត្រូវបានសួរចម្លើយនៅស-២១។

[០៩:៤១:៥២]

នៅក្នុងសវនាការឆ្នាំ២០០៩ ប៊ូ ម៉េង បានធ្វើការរៀបរាប់អំពីការសួរចម្លើយនេះ ដូចតទៅ ខ្ញុំសូមអានចម្លើយរបស់គាត់៖ “គេមានដំបងជាច្រើន ហើយនៅពេលដែលគេទម្លាក់ដំបងហ្នឹងទៅលើឥដ្ឋហ្នឹង ដើម្បីឲ្យវាឮខ្លាំងៗ ហើយគេសួរខ្ញុំថា តើខ្ញុំពេញចិត្តឲ្យគេវាយខ្ញុំនឹងដំបងមួយណា? ម៉ម ណៃ បានលើកឡើង ហើយយក ក៏កញ្ឆក់យកដំបងមួយ ហើយវាយគាត់តែម្ដង។ <ពេលគាត់ហត់ខ្លាំង> បន្ទាប់មកម្នាក់ទៀតក៏ប្ដូរវេនគ្នា ដើម្បីវាយខ្ញុំ។ គាត់<>ឲ្យ<ខ្ញុំ>រាប់ ខ្ញុំរាប់ពីមួយដំបង ទៅដល់ដំបងទី១០។ ហើយគេនិយាយថា <ចុះឯងរាប់ឃើញដប់យ៉ាងម៉េចទៅ? អញវ៉ៃតែមួយដំបងតើ។> ខ្ញុំឈឺចាប់មែនទែននៅពេលនោះ។ គឺថានៅលើខ្នងរបស់ខ្ញុំ គឺមានរបួស ស្លាកស្នាមរបួសជាច្រើន នៅពេលដែលគេវាយខ្ញុំ គេសួរខ្ញុំថា តើអ្ហែង! ចូលជាមួយនឹង សេ.អ៊ី.អា ពីអង្កាល់? ហើយអាណាជាអ្នកណែនាំអ្ហែង ឲ្យចូលរួមជាមួយបណ្ដាញ សេ.អ៊ី.អា? ហើយអាពួកអស់នោះ ឈ្មោះអ្វីខ្លះដែរ? ខ្ញុំអត់ដឹងថា សេ.អ៊ី.អា ឬក៏ កា.ហ្សេ.បេ ហ្នឹង យ៉ាងម៉េចនោះទេ ដូច្នេះខ្ញុំមិនដឹងថា ឆ្លើយយ៉ាងម៉េចទៅជាមួយពួកគេទេ។ អ៊ីចឹងគេក៏ចេះតែបន្តវាយដំខ្ញុំតទៅទៀត។” បញ្ចប់ការដកស្រង់។

ហើយក្រោយមកទៀត ប៊ូ ម៉េង ហ្នឹង <ក្នុងអំឡុងពេលដែលគេសួរចម្លើយគាត់ គាត់>ក៏ត្រូវបានគេឆក់ខ្សែភ្លើង ឆក់ខ្សែភ្លើងទៅប្រដាប់ភេទរបស់គាត់។ សក្ខីកម្មរបស់ ប៊ូ ម៉េង និង ជុំ ម៉ី គឺវាស៊ីសង្វាក់គ្នាជាមួយនឹងរបាយការណ៍ និងកំណត់ហេតុ<នានា>ដែលអ្នកសួរចម្លើយស-២១ បានសរសេរ <ហើយ>បញ្ជាក់ថា អំពើទារុណកម្មនេះត្រូវបានប្រើប្រាស់ដើម្បីទទួលយកចម្លើយសារភាព។

[០៩:៤៤:០៥]

នៅក្នុងឯកសារ E3/7437 ចុះ<ខែ>កក្កដា ៧៨ រៀបរាប់អំពីការសួរចម្លើយអ្នកទោសម្នាក់ឈ្មោះ ស៊ូ <ហៀង>។ <អ្នកសួរចម្លើយសរសេរ ហើយ>ខ្ញុំសូមដកស្រង់៖ “ខ្ញុំ<>ឲ្យ<វាក្រាបសំពះ>នៅចំពោះ<>រូបសំណាកឆ្អឹងក្បាល។ <ដំបូង វាមិនតាមទេ ប៉ុន្តែក្រោយ វាយវាមក វាសារភាពថា

វាជាជន>ក្បត់<>។ ប៉ុន្តែ<វា>មិនបានប្រាប់ខ្ញុំអំពីខ្សែក្បត់របស់<វា>ទេ។ បន្ទាប់មកខ្ញុំក៏បាន<>ឆក់ខ្សែភ្លើងវាពីរបីដងទៀត ហើយ<ខ្ញុំ>និយាយអំពីនយោបាយ <>ដើម្បីបន្ទប់<វា>ហើយក្រោយមក <វា>បានសារភាពប្រាប់ថា <វា>មានជាប់ពាក់ព័ន្ធជាមួយនឹងខ្សែបណ្ដាញ សេ.អ៊ី.អា មែន។" បញ្ចប់ការដកស្រង់។

នៅក្នុងសវនាការនេះ ឆ្នាំ២០០៩ លោក លោកស្រីចៅក្រម ឌុច បានរៀបរាប់អំពីអ្នកទោសម្នាក់ដែលស្លាប់នៅពេលដែលគេបានគ្របមុខរបស់គាត់ដោយស្បោងផ្លាស្ទិក ហើយ<គាត់នៅចាំ>ឈ្មោះរបស់អ្នកទោសនោះ ឈ្មោះ <ពឹង> គឹមស៊ា។ ហើយមានការរៀបរាប់លម្អិតអំពីអតីតប្រធានគុក ស-២១ ដែលអង្គជំនុំជម្រះបានទទួលឯកសារនេះ កាលពីឆ្នាំទៅនេះ ហើយបានដាក់ទៅក្នុងសំណុំរឿង <ជា> ឯកសារដែលនឹងឃើញនេះ គឺនិយាយអំពីបញ្ជីត្រួតពិនិត្យអ្នកទោសប្រចាំថ្ងៃ ចុះថ្ងៃទី០៧ ឧសភា ១៩៧៨ គឺឯកសារ E3/9969 <នៅទំព័រខាងក្រោមជាចំណារសរសេរដោយដៃ៖> "<ពឹង> គឹមស៊ា ជាវេជ្ជបណ្ឌិតមកពីភូមិភាគពាយ័ព្យហ្នឹង គឺបានស្លាប់ដោយសារតែការធ្វើទារុណកម្ម ខ្យល់គនៅក្នុងកន្លែងសួរចម្លើយនេះតែម្តង។" <ខ្ញុំមិនមែនពេទ្យទេ ហើយខ្ញុំក៏មិនដឹងថា ខ្ញុំអានឈ្មោះច្បាស់ដែរ ប៉ុន្តែជំងឺ>សន្លប់<បាត់>ស្មារតី<ដោយសារខ្វះឈាមហូរទៅខួរក្បាល ជា>ចំណុច<មួយ>វាស៊ីសង្វាក់គ្នាទៅនឹងសក្ខីកម្មរបស់ ឌុច ដែលបានឆ្លើយនៅក្នុងឆ្នាំ២០០៩ហើយ ដែលថាគាត់អ្នកទោសហ្នឹង ស្លាប់ដោយសារតែថប់ដង្ហើម។

[០៩:៤៦:៣១]

ដូច្នេះយើងឃើញថា ឯកសារនេះ មិនត្រឹមតែបញ្ជាក់អំពីអំពើព្រៃផ្សៃ ចរិតលក្ខណៈនៃការធ្វើទារុណកម្មប៉ុណ្ណោះទេ ក៏ប៉ុន្តែលោក លោកស្រីចៅក្រម ក៏គួរកត់សម្គាល់ផងដែរអំពី<ភាពស៊ីសង្វាក់គ្នា និង>ការបញ្ជាក់អះអាង ដោយការចងចាំរបស់ ឌុច ដែលសាក្សីរូបនេះ គឺថា គាត់នៅចងចាំបានច្រើនមែនទែន ហើយអាចឲ្យជឿជាក់បានផង។ ហើយលោក លោកស្រីក៏បានឃើញឯកសារនេះពីមុនមកផងដែរ។ ហើយខ្ញុំសូមបង្ហាញជាថ្មីម្តងទៀត គឺឯកសារចុះខែកក្កដា ១៩៧៧ ដែល<ពិពណ៌នាសួរចម្លើយលេខាតំបន់ឈ្មោះ>កែ គឹមហួត។ <ខ្ញុំសូមដកស្រង់៖ ">នៅរសៀលថ្ងៃទី២១ ខែ៧ ឆ្នាំ៧៧ គឺយើងបានវាយដំ<វា> និងឆក់ជាមួយនឹងខ្សែភ្លើង<។ លើកនេះ វាជេរអ្នកវាយវាយ៉ាងខ្លាំង ហើយប្រាប់ថា 'វាយសម្លាប់អញមក' ឲ្យលាមកវាស៊ីពីរបីស្លាបព្រា។ ពេលយប់ យើងទៅមើលវាម្តងទៀត ហើយឆក់វានឹងខ្សែភ្លើង។ ម្តង>នេះ <ដូចជា>ធ្ងន់ធ្ងរមែនទែន។ វាទទួលការឈឺចាប់ ក្រោយមកវាសារភាព

ថា សារភាពដូចបានរាយការណ៍ខាងលើមែន។” <គេបញ្ចប់ដោយសរសេរថា “>ខ្សែចង្វាក់សហប្រតិបត្តិការរបស់ខ្ញុំ<ត្រូវ>បន្តធ្វើទារុណកម្មតទៅទៀត<ដោយម្ចាស់ការ ពីព្រោះខ្មាំងវង្វេងស្មារតី ហើយទីបញ្ចប់ ខ្មាំង>ក៏ស្លាប់ទៅ។” អ្វីដែលគួរឱ្យភ័យខ្លាចបំផុតនោះ លោក លោកស្រីចៅក្រម ដែលនេះគឺជាចំណុចដំបូងនៃការធ្វើទារុណកម្មទៅលើ កែ គឹមហួត នៅឡើយទេ<ក្នុងគុកស-២១ នោះ> ការធ្វើទារុណកម្មគឺបន្តរហូតទៅដល់៩ខែកន្លះ រហូតទៅដល់គាត់ត្រូវបានសម្លាប់<>នៅក្នុងខែឧសភា ឆ្នាំ១៩៧៨។

ប្រភពភស្តុតាងមួយដ៏សំខាន់ផ្សេងទៀត ដែលបញ្ជាក់អះអាងអំពីការប្រើប្រាស់ទារុណកម្មជាប្រព័ន្ធនៅស-២១នេះ គឺសៀវភៅកំណត់ត្រាដែលសល់ពីសម័យកាលនោះ <ដែលកត់ត្រាអំពីការណែនាំ និងការហ្វឹកហ្វឺនដែលពួកគេទទួលបាន។> ឯកសារE3/8368 ជាសៀវភៅកំណត់ត្រាមួយក្នុងចំណោមសៀវភៅកំណត់ត្រាជាច្រើន របស់អ្នកសួរចម្លើយ។ ហើយខ្ញុំសូមដកស្រង់៖ “ខ្មាំង មិនងាយសារភាពជាមួយនឹងយើង<ងាយៗ>ទេ។ នៅពេលពួកវាសារភាព យើងក៏និយាយពីរឿងនយោបាយ ហើយការធ្វើទារុណកម្មនេះគឺមិនអាចចៀសផុតបានទេ គឺគ្រាន់តែថា ការធ្វើទារុណកម្មនេះវាតិចឬច្រើន តែប៉ុណ្ណោះ។ គោលបំណងនៃការធ្វើទារុណកម្មនេះ គឺដើម្បីទទួលបានចម្លើយពីពួកគេ ហើយមិនមែនធ្វើដើម្បីជាការលេងសើចទេ។ ដូច្នេះត្រូវតែធ្វើឱ្យពួកគេ ឈឺចុកចាប់ អ៊ីចឹងពួកគេអាចឆ្លើយបានយ៉ាងឆាប់រហ័ស។” បញ្ចប់ការដកស្រង់។

[០៩:៥០:០៨]

នៅឯក្រាំងតាចាន់ លោក លោកស្រីចៅក្រម បានស្តាប់សក្ខីកម្មសាក្សីជាច្រើនមានឆ្នាំគុក មានអតីតអ្នកទោសហ្នឹងគឺថា ការសួរចម្លើយនេះគេសួរនៅក្នុងរោង<ចំហ>មួយជិតផ្ទះបាយ គឺថាគេអាចមើលឃើញតែម្តង។ ក្នុងនោះមានដំបង <ខ្សែតី ពូថៅ ដង្កៀប> មានចង្វាក់ -- មានច្រវាក់ ជាដើម។ល។<>ហើយ<គេអាចឮជាញឹកញាប់នូវសំឡេងស្រែកដោយការឈឺចាប់របស់>អ្នកទោស<ពេលគេសួរចម្លើយ>។ មាស សុខា បានរៀបរាប់ថា “អគារនោះទាំងមូលយើងស្តាប់ឮសូរសម្រែកហ្នឹងពេញអគារហ្នឹងតែម្តង។” ការប្រើប្រាស់ទារុណកម្មនេះត្រូវបានកម្មាភិបាលពីរ<នាក់មកពី>ក្រាំងតាចាន់ ដែលបានផ្តល់សក្ខីកម្មទទួលស្គាល់ គឺមួយឈ្មោះ សូត្រ សាំង ហើយ វ៉ាន់ សឿន។ អ្នកយាមឈ្មោះ សូត្រ សាំង ហ្នឹងបានទទួលស្គាល់ថា អ្នកទោសត្រូវបានសួរចម្លើយមែន។ សូមដកស្រង់៖ “អ្នកទោសត្រូវបានវាយដំ និងគ្របមុខទៅដោយស្បោងផ្លាស្ទិក។” ហើយ ឌុចធំ ដែលជាអតីតសមាជិកគណៈ

កម្មការក្រាំងតាចាន់ ហើយនិងប្រធានយុវជនស្រុកត្រាំកក់ បានទទួលសារភាពថា កិច្ចសម្ភាសន៍របស់គាត់ជាមួយនឹងសហចៅក្រមស៊ើបអង្កេតមុនពេលគាត់ស្លាប់ ថាគាត់បានចូលរួមនៅក្នុងការសួរចម្លើយទាំងនោះដែរ និងថាបើអ្នកទោសមិនឆ្លើយសារភាពទេ គឺថាពួកគេនឹងត្រូវទារុណកម្មហើយ។

លោក លោកស្រីក៏បានស្ដាប់ឮ គឺអតីតអ្នកទោសឈ្មោះ <វង> សារុន ថានៅថ្ងៃមួយនោះ គាត់ទៅធ្វើនៅជិតបន្ទប់អ្នកសួរចម្លើយ ហើយគាត់ស្ដាប់ឮលម្អិតអំពីការសួរចម្លើយអ្នកទោស<ដែលជាប្រជាជន>ថ្មីម្នាក់ ដែលមកពីភ្នំពេញ ដែលគាត់បានរៀបរាប់ដូចខាងក្រោម ខ្ញុំសូមដកស្រង់៖ "ខ្ញុំឮសួរសំឡេងវាយ<ដោយរំពាត់> គេសួរសំណួរជាថ្មីម្ដងទៀត ថាតើគាត់មានឋានន្តរស័ក្តិជាអនុសេនីយ៍ឯកឬក៏អត់ទេ ហើយគាត់និយាយដដែលៗ បុរសនេះគឺថាត្រូវបានគេវ៉ៃដំស្ទើរតែស្លាប់មុននឹងគាត់ឆ្លើយសារភាព ថាគាត់ពិតជាពាក់ស័ក្តិពាមែន ដើម្បីឈប់ឲ្យគេវ៉ៃគាត់តទៅទៀត។" <វង សារុន> ក៏បានរៀបរាប់ គាត់ឃើញមានស្នាកស្នាមនៅពេញរាងកាយរបស់មិត្តភក្តិរបស់គាត់ នៅពេលដែលអ្នកទោសរូបនោះត្រឡប់ចូលមកក្នុងបន្ទប់ឃុំឃាំងខ្លួនរបស់គាត់វិញ។ ហើយសំខាន់បំផុត សក្ខីកម្មរបស់សាក្សីទាំងនេះគឺវាស៊ីសង្វាក់គ្នាទៅនឹងកំណត់ត្រាដែលសល់ពីស្រុកត្រាំកក់ និងគុកក្រាំងតាចាន់ ដែលបានពិភាក្សាគ្នាយ៉ាងបើកចំហតែម្ដង អំពីការប្រើប្រាស់វិធីសាស្ត្រក្ដៅវិធីសាស្ត្រត្រជាក់ក្នុងការសួរចម្លើយនេះ។

[០៩:៥៣:១៣]

របាយការណ៍ថ្ងៃទី២៦ ធ្នូ ១៩៧៧ ពីមេគុកនៅក្រាំងតាចាន់ឈ្មោះ <អាន> បានរៀបរាប់អំពីការសួរចម្លើយអ្នកទោសស្រីម្នាក់ សូមដកស្រង់៖ "នៅពេលសមមិត្តរបស់យើងនៅក្នុងកងទ័ពសួរចម្លើយអ្នកទោសស្រីនោះ អ្នកទោសនោះក៏ថាចេះតែបន្លំស្រែកយំ ហើយមុខរបស់គាត់ឡើងខ្មៅ <ធ្វើពុត។> អ៊ីចឹងតាម<ពិនិត្យ>របស់ខ្ញុំ គឺថាត្រូវតែប្រើវិធីសាស្ត្រក្ដៅ ទើបអ្នកទោសនោះសារភាព។ នៅក្នុងកន្លែងកងទ័ពនៅអង្គតាសោម យើង<មិនមានកន្លែងសម្ងាត់សម្រាប់សួរចម្លើយអីទេ គឺយើង>បានសួរចម្លើយរហូត។ ដូច្នេះយើងខ្ញុំសូមបញ្ជូនរបាយការណ៍នេះទៅបក្សដើម្បីផ្ដល់មតិណែនាំ ថាតើបក្សសម្រេចយ៉ាងម៉េច <ខ្ញុំរង់ចាំការ>សម្រេច<នេះ>។" ហើយឯកសារមួយទៀតមកពីឃុំត្រពាំងធំត្បូងពាក់ព័ន្ធទៅនឹងការសួរចម្លើយអ្នក<ទោស>ម្នាក់ឈ្មោះ មឿង ស៊ុន ដែលឃុំបានរាយការណ៍ថា សូមដកស្រង់៖ "យើង<បាន>ប្រើប្រាស់វិធីសាស្ត្រសួរចម្លើយ<ត្រជាក់ផង> វិធីសាស្ត្រក្ដៅ<ផងក្នុងការសួរចម្លើយ> មឿង ស៊ុន គាត់បានឆ្លើយសារភាពថា គាត់ត្រូវបានចាត់តាំងដោយ អា<ពុង> នោះតាំង

ពីខែវិច្ឆិកា ឆ្នាំ១៩៧៦ ម្ល៉េះ។

លោក លោកស្រីចៅក្រម ការសំអាងទៅលើការប្រើប្រាស់វិធីសាស្ត្រក្តៅនិងត្រជាក់ ក្នុងការសួរចម្លើយនេះ គឺថាមានសារៈសំខាន់ណាស់។ យើងបានឃើញថា នៅក្នុងស្រុកគំរូរបស់បក្សកុម្មុយនីស្តមួយនេះ គឺការសួរចម្លើយត្រូវប្រើប្រាស់ជាប្រព័ន្ធនៅសម័យកម្ពុជាប្រជាធិបតេយ្យនៅក្នុងលក្ខណៈស្រដៀងៗតែគ្នាទៅនឹងវិធីសាស្ត្រសួរចម្លើយនៅស-២១ដែរ។

[០៩:៥៥:១៣]

នៅភ្នំក្រោលគឺយើងបានស្តាប់ឮទាហានមកពីកងពល<៩២០ ឈ្មោះ ស៊ុន វុធ> ដែលគាត់បានផ្តល់សក្ខីកម្មថា នៅពេលដែលគេសួរចម្លើយរបស់គាត់ គឺការសួរចម្លើយដែលមានរយៈពេលរាប់ខែហ្នឹង គេឆក់ខ្សែភ្លើងគាត់ គេវ៉ៃគាត់នឹងដំបងរហូតដល់សន្លប់។ ហើយគេប្រាប់គាត់ថា បើគាត់មិនឆ្លើយសារភាពទេ គេនឹងវ៉ៃគាត់ដល់ស្លាប់។ នៅអូរកន្សែងវិញ គឺមេគុក ហើយនិងអនុប្រធានគុកបានទទួលស្គាល់ថា មានការប្រើប្រាស់ទារុណកម្មក្នុងពេលចាំបាច់ ដើម្បីឲ្យអ្នកទោសឆ្លើយសារភាព។ ហើយដូចនឹងស-២១ដែរ វិធីសាស្ត្រនៃការធ្វើទារុណកម្មមួយ គឺការប្រើប្រាស់ខ្សែភ្លើងឆក់ <ដោយ>ប្រើប្រាស់ភ្លើងមកពីទូរស័ព្ទ។

លោក លោកស្រីចៅក្រម ភស្តុតាងបានបង្ហាញថា មិនត្រឹមតែ<ការ>ប្រើប្រាស់ទារុណកម្មនោះ<នៅ>មន្ទីរសន្តិសុខ<មានលក្ខណៈទូលំទូលាយ និងជាប្រព័ន្ធនោះទេ ការធ្វើទារុណកម្មនេះក៏គេដឹងឮជាទូទៅចាប់ពីគណៈឃុំត្រាំកក់រហូតដល់អ្នកដឹកនាំកំពូលរបស់បក្ស រួមទាំងជនជាប់ចោទផងដែរ។> វិធីសាស្ត្រ<មួយក្នុងចំណោមវិធីសាស្ត្រនានានៅ>ស-២១ គឺការប្រើប្រាស់ថង់ប្លាស្ទិកដើម្បីខ្ទប់ដង្ហើម<ដោយ>វន វ៉េត <ណែនាំដល់ ឌុច។ កាលនោះ វន វ៉េត ជាប្រធានភូមិភាគពិសេស ហើយក្រោយមកជាសមាជិកគណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា>។ ដូចដែល ឌុច បានផ្តល់សក្ខីកម្ម វន វ៉េត បានបញ្ជាគាត់ឲ្យគ្របក្បាលជាមួយថង់ប្លាស្ទិក។ ខ្ញុំសូមដកស្រង់៖ “សមមិត្តត្រូវតែមើលទៅករបស់វា មិនមែនមើលទៅលើជីពចរនៅកនោះទេ។ ប្រសិនបើកហ្នឹងវាញ័រខ្លាំង បានន័យថាវាហ្នឹងជាគិញសម្ងាត់ហើយ”។

[០៩:៥៧:២៤]

នៅក្នុងសវនាការនេះផងដែរ គឺយើងបានស្តាប់ឮសក្ខីកម្មរបស់ ឌុច អំពីការសួរចម្លើយ ឬក៏ការសង្កេបចម្លើយសារភាព ដែលគេរៀបចំឲ្យមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា <ជាប្រចាំ> ឌុច ផ្ញើជាទៀង

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

ទាត់<ដំបូង>ទៅ សុន សេន <បន្ទាប់មកទៅ> នួន ជា។ ចំណារនៅលើចម្លើយសារភាពទាំងអស់នោះ បាន<បង្ហាញ>ថាឯកសារនោះត្រូវបានបញ្ជូនទៅភូមិភាគ កងពល ហើយនិងមេដឹកនាំក្រសួងនៅក្នុង <ពេញទូទាំងប្រទេស>។ ហើយនៅក្នុងចម្លើយសារភាពដ៏សង្ខេប ដែលគេបញ្ជូនទៅមេដឹកនាំបក្ស កុម្មុយនីស្តកម្ពុជាជាញឹកញាប់ គឺមានការរៀបរាប់អំពីការប្រើប្រាស់ទារុណកម្ម ដើម្បីទទួលបានចម្លើយ ។ នេះគឺជាឧទាហរណ៍<នៅស-២១>នៃចម្លើយសារភាពរបស់ ញឹម <ស៊ឹម> ដែលនៅគម្របខាងលើ គឺមាន<ចំណារ>បញ្ជាក់ថា "ផ្ញើជូនបងនួន"។ ហើយប៉ុន្មានទំព័រខាងក្រោម គឺមានការ គឺជារបាយ-ការណ៍សង្ខេប<សរសេរដោយអ្នក>សួរចម្លើយ ហើយខ្ញុំសូមដកស្រង់៖ "ខ្ញុំធ្វើទារុណកម្មរហូតដល់វាឆ្លើយសារភាពថា វាជាគិញ ហើយនិងជាបណ្តាញ សេ.អ៊ី.អា"។ ហើយដោយទទួលស្គាល់អំពីការដឹងឮរបស់គាត់ ថាទារុណកម្មត្រូវបានគេប្រើប្រាស់នោះ នួន ជា បានប្រាប់ ថេត សម្បត្តិ នៅក្នុង<បទ>សម្ភាសន៍<មួយ>។ នួន ជា បាននិយាយ ខ្ញុំសូមដកស្រង់៖ "ជាទូទៅ ពួកគេឆ្លើយសារភាពនៅពេលដែលពួកគេត្រូវបានត្រូវបានវាយដោយធ្ងន់ធ្ងរ ហើយឈឺចាប់នោះ"។ ហើយនៅក្នុងកិច្ចសម្ភាសន៍ខែមករា ២០០៤ ជាមួយនឹង<ចៅក្រម> ឡឺម៉ុងដ៍ <លោក> ខៀវ សំផន បានទទួលស្គាល់ប្រាប់អ្នកសារព័ត៌មានដែលសម្ភាសគាត់ថា ខ្ញុំសូមដកស្រង់៖ "តាមពិតទៅ គឺមានស្ថាប័នរដ្ឋមួយដែលការធ្វើទារុណកម្ម ឧក្រិដ្ឋកម្មជាប្រព័ន្ធ និងការសម្លាប់ គឺជាគោលនយោបាយរបស់រដ្ឋ។" <លោក លោកស្រីចៅក្រម ក្នុងកិច្ចសម្ភាសន៍នោះ មាននៅក្នុង>ឯកសារ E3/4603។

[០៩:៥៩:៤៦]

ឥឡូវនេះ ខ្ញុំសូមនិយាយអំពីឧក្រិដ្ឋកម្មមនុស្សឃាត និងការសម្លាប់រង្គាល។ លោក លោកស្រីចៅក្រម ភស្តុតាងនៅចំពោះមុខលោក លោកស្រីចៅក្រម បានបង្ហាញថា ការសម្លាប់នៅមន្ទីរសន្តិសុខគឺធ្វើឡើងជាទ្រង់ទ្រាយធំ ហើយភស្តុតាងនៃការសម្លាប់ទាំងអស់នោះ គឺមិនអាច<ប្រកែក>បាន<>ឡើយ។ នៅអូរកន្សែង ប្រធាន និង អនុប្រធានគុក ហើយនិងអ្នកទោស ដែលនៅរស់រានមានជីវិតបានផ្តល់សក្ខីកម្មអំពីការសម្លាប់ជាទ្រង់ទ្រាយធំប្រហែលជា១០០ ទៅ២០០នាក់ទៅលើជនជាតិចារាយ មកពីវៀតណាម ហើយការសម្លាប់នេះធ្វើឡើងនៅមន្ទីរសន្តិសុខនោះតែម្តង។ ប្រធាន អនុប្រធានគុកក៏បានផ្តល់សក្ខីកម្មថា បញ្ជាឲ្យសម្លាប់អ្នកទោសទាំងអស់នោះ ត្រូវបានបញ្ជូនមកពីលេខាភូមិភាគ៨០១ ឈ្មោះ សារឿន ប៉ុន្តែអ្នកដែលបញ្ជាបន្តមក សារឿន ហ្នឹងគឺលេខាភូមិភាគ<ព្លិសាន>។ នៅក្នុងសារទូរលេខបន្ទាប់នេះ សារទូរលេខចុះថ្ងៃ១៥ មិថុនា ៧៧ គឺមិនមែនលេខា<កងពល៨០១>នោះទេ <ប៉ុន្តែ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ជា>លេខាភូមិភាគពួសានដែលរាយការណ៍<មកមជ្ឈិមបក្សថា កងពល៨០១ បានចាប់ខ្លួន>ជនជាតិចារាយ<ចំនួន២០៩នាក់>ដែលឆ្លងព្រំដែនមក<។ ហើយលេខាភូមិភាគពួសានបានស្វែងរកការណែនាំដើម្បីចាត់វិធានការបន្ទាប់។>

ខ្ញុំសូមបន្តទៅ*ស្លាយ*បន្ទាប់។ សារទូរលេខទាំងអស់នេះ ភាគច្រើនបញ្ជូនទៅភ្នំពេញ ហើយត្រូវបានចម្លងជូនអ៊ំ, អ៊ំនួន (គឺនួន ជា), មន្ទីរ៨៧០ ហើយ<បណ្ណសារ>មជ្ឈិម<។> នៅពេលដែលប្រធានគុកឈ្មោះ ឆោម សែ បានបង្ហាញនៅថ្ងៃ០៨ មេសា ២០១៣ នោះ គាត់បានអះអាងថា តាមការចងចាំរបស់គាត់ <ថានេះជាក្រុមមនុស្សតែមួយ ទោះបីថាតាមការចាំរបស់គាត់> មានមនុស្សតែ១០០នាក់ គឺមានជនជាតិចារាយតែ១០០នាក់ប៉ុណ្ណោះដែលត្រូវបានគេនាំមក<កម្ទេចនៅ>អូរកន្សែងនោះ។ អ្វីដែលច្បាស់នៅទីនេះ គឺថាមិនអាច<ប្រកែកបានទេ >ឬក៏ការសួរដេញដោលទៀតនោះឡើយ ដែលថា សាក្សីទាំងអស់បានបង្ហាញថា មានការសម្លាប់ជាទ្រង់ទ្រាយធំទៅលើជនជាតិចារាយ ហើយការសម្លាប់នេះ<ក៏ត្រូវ>រាយការណ៍ជូនទៅមេដឹកនាំនៅភ្នំពេញ ហើយទុកឱ្យមេដឹកនាំទាំងអស់នោះជាអ្នកសម្រេចទៅលើជោគវាសនារបស់ជនជាតិចារាយនេះ។

[១០:០៣:០៧]

ចំពោះក្រាំងតាចាន់វិញ <ជាថ្មីម្តងទៀត> ភស្តុតាងបានបង្ហាញយ៉ាងច្បាស់អំពីការសម្លាប់ជាទ្រង់ទ្រាយធំ។ ទាំងឆ្មាំគុក ក៏ដូចជាអ្នកទោសដែលនៅរស់រានមានជីវិតមួយចំនួនតូច បានឯកភាពថាមានករណីលើកលែងតិចតួចដែល -- មានករណីលើកលែងតិចតួចតែ ប៉ុន្តែមនុស្សដែលបញ្ជូនមក<មន្ទីរសន្តិសុខនោះ>សុទ្ធតែត្រូវបានគេសម្លាប់។ ឆ្មាំគុកឈ្មោះ ស្រី ថន ដែលគេហៅថា "ឌុចតូច" នោះបានទទួលស្គាល់ថា អ្នកទោស៩៩ភាគរយត្រូវបានគេកម្ទេច។ វ៉ាន់ សឿន ជាកម្មាភិបាលគុកមួយរូបផងដែរ បានយល់ស្របជាមួយ ឌុចតូច ថា ភាគច្រើនលើសលុបនៃអ្នកទោសត្រូវបានគេកម្ទេច។ ហើយឆ្មាំគុក សូត្រ សាំង ក៏ទទួលស្គាល់នៅក្នុងតុលាការនេះផងដែរថា <ខ្ញុំសូមដកស្រង់៖ ">ចំពោះអ្នកដែលនៅរស់រានមានជីវិតពីមន្ទីរសន្តិសុខហ្នឹង ខ្ញុំគិតថា មានចំនួនតិចតួចណាស់។"

នៅថ្ងៃអង្គារ <មេធាវី>ដើមបណ្តឹងរដ្ឋប្បវេណីបានចាក់នូវសក្ខីកម្មរបស់ សយ សែន ដែលរៀបរាប់អំពីការសម្លាប់អ្នកទោសនៅក្រាំងតាចាន់។ ក្រៅពីការឃើញដោយផ្ទាល់នូវការសម្លាប់នោះ សយ សែន ក៏ត្រូវបានគេចាត់តាំងជាញ៉ឹកញាប់ឱ្យជួយជីករណ្តៅ ហើយនិងជួយកប់សាកសពអ្នកទោសដែលស្លាប់។ អ្នកនៅរស់រានមានជីវិតដទៃទៀតមកពីគុកនេះ ក៏បានផ្តល់សក្ខីកម្មផងដែរអំពីការយកអ្នក

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ទោស<ដែលជាប់ឃុំ>ជាមួយពួកគាត់ហ្នឹងទៅសម្លាប់ចោល។ <វង> សារឿន បានរៀបរាប់ថា ឃើញ<អ្នកយាម>សំលៀងកាំបិត ហើយគេយកមនុស្សទៅសម្លាប់តែម្ដង ហើយពេជ្ឈឃាដត្រឡប់មកកន្លែងវិញ ដែលខ្លួនប្រឡាក់ទៅដោយឈាម។ ដូចគ្នានឹងស-២១ ដែរ សក្ខីកម្មរបស់សាក្សីទាំងអស់នេះ ទាក់ទងទៅនឹងការសម្លាប់គឺត្រូវបានគាំទ្រដោយឯកសារសហកាលគឺឯកសារមកពីក្រាំងតាចាន់ ហើយនិងត្រាំកក់។ ឯកសារមួយនេះគឺជារបាយការណ៍ប្រចាំខែ ដែលបញ្ជូនពីក្រាំងតាចាន់ដែលបញ្ជាក់ចំនួនមនុស្ស<សរុប>ដែលចូលក្រាំងតាចាន់ និងអ្នកដែលស្លាប់ ឬក៏ត្រូវបានសម្លាប់ ដែលបានស្លាប់ដោយសារជំងឺ ឬក៏ត្រូវបានសម្លាប់នៅក្នុងខែនេះ។ <យើងមើលទៅ>របាយការណ៍ខែវិច្ឆិកា ឆ្នាំ៧៧ គឺឯកសារ E3/2109 ដែលបញ្ជាក់ថាអ្នកទោសថ្មីដែលចូលនៅក្នុងខែនោះ គឺមាន៧៥នាក់ ហើយមានអ្នកទោស៩២នាក់ ត្រូវបានកម្ទេច ហើយប្រាំមួយនាក់ទៀត <>បានស្លាប់ដោយសារជំងឺ។ អ្នកទោស៩២នាក់ ត្រូវបានសម្លាប់ក្នុងរយៈពេលមួយខែ ក្នុងស្រុកតែមួយប៉ុណ្ណោះ។

[១០:០៦:១៨]

យើងក៏បានស្ដាប់សក្ខីកម្មរបស់អតីតកម្មាភិបាលរបស់អតីតលេខា និងឯកសារដែលនៅសេសសល់ ដែលថា<>បញ្ជាសម្លាប់ត្រូវបានបញ្ជូនមកពី<លេខា>តំបន់<១៣ ទៅកាន់ថ្នាក់ស្រុក> ហើយជាទូទៅរបាយការណ៍<សួរចម្លើយអ្នកទោស>ពីមន្ទីរសន្តិសុខតែងតែផ្ញើទៅតំបន់<វិញ>។ នៅក្នុងចម្លើយសារភាពនៅក្រាំងតាចាន់ គឺE3/2012 គឺមានចំណារ<ដោយដៃ>របស់លេខាតំបន់១៣ ឈ្មោះប្រាក់ ដែលខ្ញុំសូមដកស្រង់ "សម្រេចកម្ទេចចុះ"។

លោក លោកស្រីចៅក្រម នៅក្នុងពេលមួយដ៏សំខាន់បំផុតនៅក្នុង<ការជំនុំជម្រះ>នេះ អតីតលេខាស្រុកត្រាំកក់ ឈ្មោះ នាង អ៊ួច ហៅ តាសាន បានទទួលស្គាល់ថា គាត់បានសរសេរឯកសារនេះ។ គឺឯកសារដែលបានបញ្ជាក់ថា "ក្មេងៗធំៗ ដែលទៅកង<កុមារ ឬកង>ចល័ត<ហើយ ឲ្យពួកគេនៅហ្នឹងទៅ> ហើយយកតែម្ដាយទៅបានហើយ ប៉ុន្តែបើក្មេងៗមិនអាចបេះបានទេ គឺយកទៅតែម្ដង ប៉ុន្តែបើបេះមិនដាច់ពីម្ដាយទេ យកចុះសាកសួររឿងរ៉ាវ។ <ក្រោយពីសួររួចហើយ> បោសសម្អាតទាំងអស់ចុះ។" អតីតលេខាស្រុកត្រាំកក់ បានផ្ដល់សក្ខីកម្មការណែនាំអំពីការប្រព្រឹត្តចំពោះកុមារហ្នឹង គឺគាត់ទទួលបានមកពីលេខាតំបន់ ហើយគាត់ទទួលស្គាល់នៅក្នុងតុលាការនេះផងដែរ ថា "បោសសម្អាតចុះ" មានន័យថា "សម្លាប់" ហើយក្នុងករណីនេះ គឺបានន័យថា សម្លាប់ទាំងទារក និងកូនក្មេងតូចៗ។ ការទទួលស្គាល់ការសម្លាប់ក្មេងៗទាំងពីរនាក់ហ្នឹង ដែល សយ សែន បានឃើញនៅក្រាំងតាចាន់ ក៏ដូចជា

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

ការសម្លាប់ក្មេងៗ និងទារកដែល<អ្នកយាម> ស៊ូត្រ សាំង ហើយនិង ស្រី ថន បានទទួលស្គាល់ផងនោះ គឺ<មិនមែនជាសកម្មភាពទុច្ចរិតទេ តែគេ>អនុលោមទៅតាមគោលនយោបាយ និងការបញ្ជារបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា<ប៉ុណ្ណោះ>។

[១០:០៩:០២]

ដូចគ្នានឹងស-២១ដែរ អដ្ឋិធាតុដែលនៅសេសសល់ ត្រូវបានគេប្រមូលមកពីរណ្ដៅកប់សពរួម <នៅក្រាំងតាចាន់>។ ដូចគ្នានឹងស-២១ អដ្ឋិធាតុដែលនៅសេសសល់នោះ មិនត្រូវបានរក្សាទុកឲ្យបានត្រឹមត្រូវអស់រយៈពេលច្រើនឆ្នាំ ដូច្នេះប្រាកដណាស់ ថាវាមានការបាត់បង់អដ្ឋិធាតុយ៉ាងច្រើន។ វឿន វុទ្ធី ដែលបានធ្វើការសិក្សាស្រាវជ្រាវទៅលើលលាដ៍ក្បាលដែលនៅសេសសល់ប្រហែល១.៩០០នាក់ <នៅក្រាំងតាចាន់>នោះ បានបញ្ជាក់ថា មានស្លាកស្នាមនៃការវាយទង្គិចយ៉ាងខ្លាំងទៅលើលលាដ៍ក្បាល គឺដូចគ្នាទៅនឹងអ្វីដែលគាត់ឃើញនៅលើអដ្ឋិធាតុនៅជើងឯក<ដែរ>។

លោក លោកស្រីចៅក្រម ខ្ញុំនឹងត្រូវបន្តទៅប្រធានបទថ្មីមួយ ទាក់ទងទៅនឹងមន្ទីរសន្តិសុខ ស-២១។ តើខ្ញុំអាចបន្តទៅមុខទៀតបាន ឬមួយក៏លោកប្រធានចង់ឈប់សម្រាកនៅពេលនេះ?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសមស្របសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១០ នាទី ដល់ម៉ោង ១០:៣០ នាទី)*

[១០:៣០:៥២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្ដល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិ ដើម្បីបន្តធ្វើសេចក្ដីសន្និដ្ឋានរបស់ខ្លួន។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ឥឡូវនេះ ខ្ញុំសូមនិយាយសង្ខេបទេ អំពីភស្តុតាងស្តីអំពីការកាប់សម្លាប់នៅមន្ទីរសន្តិសុខ ស-២១ គឺការសម្លាប់ និងការធ្វើទុក្ខបុកម្នេញ គឺថាដែលបានបង្ហាញហួសពីវិមតិសង្ស័យហើយនៅក្នុងមន្ទីរសន្តិសុខមួយនេះ។ កម្មាភិបាលដែលធ្វើការនៅគុកនេះ បានទទួលស្គាល់រួមនោះមាន ឌុច ផងដែរ ដែលបានផ្តល់សក្ខីកម្មយ៉ាងស៊ីសង្វាក់គ្នា ជូនអង្គជំនុំជម្រះថា អ្នកដែលគេបញ្ជូនទៅ ស-២១ នោះគឺត្រូវគេកម្ទេចចោលហើយ។ ហើយលោក លោកស្រីចៅក្រម ក៏បានស្តាប់សក្ខីកម្មពីកម្មាភិបាលដែលបានអនុវត្តការសម្លាប់នេះ គឺកម្មាភិបាលហ្នឹង គាត់បានកត់ត្រាឈ្មោះអ្នកទោសដែលត្រូវបានយកទៅសម្លាប់ចោល គឺឈ្មោះ សួស ធី ដែលជាប្រធានអង្គភាពយាមកាមដែលមានភារកិច្ចត្រូវបញ្ជូនអ្នកទោសចេញពីបរិវេណគុកទួលស្លែងទៅជើងឯកគឺកម្មាភិបាលឈ្មោះ ហ៊ឹម ហ៊ុយ។ ហើយប្រធានអង្គភាពនៅឯជើងឯក<ឈ្មោះ តយ តេង បន្ទាប់មក>យកអ្នកទោសពី ហ៊ឹម ហ៊ុយ ហ្នឹងយកទៅរណ្តៅសាកសពរួមដែលត្រូវសម្លាប់ម្តងមួយ ម្តងមួយ រហូតទាល់តែអស់។ ហើយគ្មានអ្វីដែលគួរឲ្យសង្ស័យនោះទេ អំពីសក្ខីកម្មទាំងនេះ ដោយសារថា ឈ្មោះរបស់អ្នកទោសដែលគេត្រូវយកទៅសម្លាប់ចោលនោះ គឺត្រូវបានកត់ត្រាតាមវិធីសាស្ត្ររបស់គេនោះ នៅក្នុងបញ្ជីដែលបានយកមកបង្ហាញជាភស្តុតាងនៅក្នុងសវនាការនេះរួចទៅហើយ។ ហើយមានរូបថតរបស់អ្នកទោស ដែលគេត្រូវបានសម្លាប់ចោលនោះផងដែរ។ <មានផ្នែកខ្លះនៅជើងឯក >គេគាស់កាយរណ្តៅសាកសព<>ហ្នឹង គេបានរកឃើញអំពីចំណុចនេះ។

[១០:៣៣:៤៥]

ហើយនៅក្នុងសវនាការនេះ ក៏យើងមានសំណាងដែរ បានស្តាប់សក្ខីកម្មរបស់ វឿន វុទ្ធី ដែលគាត់បានធ្វើការគាស់កាយរណ្តៅសាកសព ដែលនៅសេសសល់នៅជើងឯក។ ការសិក្សាស្រាវជ្រាវរបស់គាត់បញ្ជាក់អំពីចំនួនលលាដ៍ក្បាល ដែលវាគឺថាស្ទើរតែខូចខាតច្រើនហើយតាំងពី<ការគាស់ដំបូងនៅក្នុងឆ្នាំ១៩៨១ រហូត>ឆ្នាំ១៩៨៣<>។ ហើយសំខាន់បំផុតនោះ វឿន វុទ្ធី គាត់បានផ្តល់សក្ខីកម្មថានៅពេលដែលក្រុមគាត់បានកាយរណ្តៅសាកសពម្តងមួយ ម្តងមួយ គឺគាត់មានបានឃើញលលាដ៍ក្បាលជាង៦.០០០លលាដ៍ក្បាល គឺថាមានតែលលាដ៍ក្បាលមួយ <គឺតែមួយ>គត់ ដែលអត់មានស្លាកស្នាមដោយសារការវាយដំណាមួយនោះ។

លោក លោកស្រី ចៅក្រម ខ្ញុំនឹងបង្ហាញជូនអំពីរូបថត<គួរឲ្យរន្ធត់>ខ្លះ នេះគឺជារូបថតជនរង

គ្រោះចុងក្រោយពីស-២១ ដែល ឌុច បានកំណត់អត្តសញ្ញាណថា ជាកម្មាភិបាល <Y-10 ជា> អ្នកពាក់ព័ន្ធជាមួយនឹងការសម្លាប់ ម៉ាល់ខុម ខាដវ៉ែល<។ ដូចលោក លោកស្រីចៅក្រមបានដឹងស្រាប់ហើយតាមសក្ខីកម្ម ឌុច> គឺនៅពេលដែលធ្វើការសម្លាប់នេះ អ្នកទោសស-២១ដទៃទៀតហ្នឹង គេត្រូវបានយកទៅសម្លាប់ចោលអស់ទៅហើយ ដោយអនុវត្តទៅតាមបញ្ជារបស់ នួន ជា។ <ប៉ុន្តែ កម្មាភិបាលមួយក្រុមតូច Y-10 ទាំងនេះ គេ>ទុកដើម្បីសួរចម្លើយតទៅទៀត។ នេះជា<សកម្មភាពចុងក្រោយបង្អស់>របស់កម្មាភិបាលស-២១ ដែលបានរត់ចេញពីគុក<ទួលស្លែង។ ពួកគេ>ត្រូវតែចាក់សម្លាប់<អ្នកទោស>ជាមួយនឹងចំពុះទុងនៅពេលដែលអ្នកទាំងនោះគឺថានៅជាប់ខ្នោះជើង<ក្នុងបន្ទប់ឃុំឃាំងរបស់ខ្លួន>នៅឡើយ។ ហើយអ្នកទោសម្នាក់ហ្នឹង ក៏ត្រូវ<គេ>កាត់ក្បាលចេញតែម្តង ដូចបានឃើញក្នុងរូបថតនេះស្រាប់ហើយ។

[១០:៣៦:១៨]

មានកំណត់ត្រាស្តីអំពីការកាប់សម្លាប់ជាច្រើនទៅលើអ្នកទោសពីស-២១ ហើយនៅលើអេក្រង់នេះ លោក លោកស្រីចៅក្រមឃើញហើយ <នេះគ្រាន់តែជា>ឧទាហរណ៍តិចតួចតែប៉ុណ្ណោះ។ នៅក្នុងសារណារបស់យើងខ្ញុំ បញ្ជី<នៅសេសសល់នោះ>រួមមាន គឺថាមានករណីចំនួន២៧ ពាក់ព័ន្ធទៅនឹងការកាប់សម្លាប់ទ្រង់ទ្រាយធំរៀងរាល់ថ្ងៃទៅលើអ្នកទោសជាង១០០នាក់ <ហើយភាគច្រើន> នៅពាក់កណ្តាលនៅឆ្នាំ១៩៧៧ និងនៅពាក់កណ្តាលឆ្នាំ៧៨ ការបោសសម្អាតចុងក្រោយនេះ។ បន្ថែមទៅលើការសម្លាប់យ៉ាងរង្គាលនៅខែឧសភា ឆ្នាំ១៩៧៨ ដែលខ្ញុំបានលើកយកពិភាក្សារួចមកហើយរួមទាំងពីម្សិលមិញផងដែរ។ បញ្ជីនៅសល់ពីសម័យនោះ គឺថាអ្នកទោសជាង១.០០០នាក់ ត្រូវគេសម្លាប់តែក្នុងរយៈពេលមួយខែ ពីខែកក្កដា ទី១ ទៅដល់ទី៣០<សីហា> ឆ្នាំ៧៧ ដោយ<ចាប់ផ្តើម>សម្លាប់ស្ត្រី១២៩នៅថ្ងៃទី១ ខែកក្កដា។ ហើយអ្នកទោសជាង<៨៥០>នាក់ គឺថាត្រូវបានគេសម្លាប់តែក្នុងរយៈពេលមួយសប្តាហ៍នៅក្នុងខែតុលា ឆ្នាំ១៩៧៧ រួមទាំងអ្នកទោស<៤១៨>នាក់ដែលសម្លាប់តែមួយថ្ងៃនៅថ្ងៃទី១៥ខែតុលា។

បាទ *ស្លាយ*បន្ទាប់ទៅទៀត គឺចំណុចលេខ១.៧<> នៅក្នុង<ឧបសម្ព័ន្ធ>សារណារបស់យើងខ្ញុំដែលបង្ហាញអំពីឯកសារនៃការកាប់សម្លាប់ក្នុងរយៈពេលមួយខែ ដែលឯកសារនេះគឺជាភស្តុតាងដែលបានផ្តល់ជូននៅក្នុង<ការជំនុំជម្រះក្តី>នេះ។ ពាក់ព័ន្ធទៅនឹងការចោទប្រកាន់អំពីការសម្លាប់រង្គាល គឺបញ្ជីសម្លាប់នេះ គឺបង្ហាញអំពីចេតនានៃការសម្លាប់ក្នុងទ្រង់ទ្រាយធំតែម្តង។

[១០:៣៨:៤៧]

បាទ ឥឡូវនេះប្រហែលជាពេលវេលាមួយសមស្របហើយដែលខ្ញុំលើកជូនអំពីចំនួនអ្នកទោសសរុបនៅស-២១ បញ្ជីថ្មីដែលយើងបានដាក់<បញ្ចូលទៅក្នុង>ឧបសម្ព័ន្ធភ្ជាប់ទៅនឹងសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់យើង។ ខ្ញុំសូមនិយាយអំពីសវនាការឆ្នាំ២០០៩ ដែលនៅពេលនោះ យើងមានបញ្ជីអ្នកទោសរួមមួយដែលមាន<ឈ្មោះសរុប>១២.៣០០នាក់។ ហើយនៅពេលដែលសួរទៅ ឌុច អំពីចំនួនអ្នកទោសសរុបនេះនៅក្នុងសវនាការ គឺសួរអំពីចំនួនអ្នកទោសសរុប ១២.៣០០នាក់នេះ<នៅមន្ទីរស-២១> ចម្លើយរបស់គាត់នោះគឺថា ចំនួនអ្នកទោសពិតប្រាកដនៅស-២១ អាចលើសពីនេះទៅទៀត។ ហើយខ្ញុំនៅចាំពេលនោះ <ខ្ញុំភ្ញាក់ផ្អើលនឹងចម្លើយនេះ> ពីព្រោះអ្នកដែលត្រូវទទួលការចោទប្រកាន់ការសម្លាប់អ្នកទោស១២.៣០០នាក់ ហើយគាត់ឆ្លើយថា ចំនួននេះអាចលើសនេះទៅទៀត មិនមែនត្រឹមតែលើសតិចតួចទេ គឺថាលើសច្រើនមែនទែន។ ដូច្នេះយើងបានឃើញនៅក្នុងបញ្ជីថ្មីដែល<ធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយដាក់ក្នុងសំណុំរឿងជាភស្តុតាង កាលពីឆ្នាំទៅ។ យើងក៏សូមអរគុណដែរ ដែលការងារទាំងនេះត្រូវបានបញ្ចប់រួចរាល់ដោយអ្នកវិភាគរបស់ ក.ស.ច.ស។> នេះគឺជាលើកដំបូងហើយ តាមដែលខ្ញុំដឹងថា គឺយើង<មានបុគ្គលិកម្នាក់>បានធ្វើបញ្ជីរួម<របស់>អ្នកទោសម្នាក់ៗនៅក្នុងបញ្ជីរួម<>គឺថាបានចងក្រងយ៉ាងត្រឹមត្រូវ<នូវប្រភពព័ត៌មានរបស់អ្នកទោសនីមួយៗ។ ឯកសារនេះសំខាន់ខ្លាំងណាស់ ហើយជាភស្តុតាងមានប្រយោជន៍ ដែលយើងមានសំណាងបានឯកសារនេះ។ តែទោះជាយ៉ាងណាក្តី ពេលវេលាក៏មានកំណត់សម្រាប់បុគ្គលិកធ្វើបញ្ជីនោះដែរ ហើយកិច្ចការមួយក្នុងចំណោមកិច្ចការនានាលើបញ្ជីរបស់ ក.ស.ច.ស គឺត្រូវបញ្ចូល និងពិនិត្យមើលរាល់បញ្ជីសម្លាប់ទាំងអស់។>

[១០:៤១:២៧]

ចំនួនបញ្ជី<របស់ ក.ស.ច.ស មាន>១៥.១០០នាក់នេះ <ដែលទទួលបានពីបញ្ជីចូល។ ដោយសារអ៊ីចឹងហើយ ទើបយើងរួមគ្នាបានបង្កើតក្រុមមួយ ជាជំហានចុងក្រោយ ដើម្បីពិនិត្យមើលកំណត់ត្រានៃការសម្លាប់ធ្វើជាភស្តុតាង។ យើងមិនបានរកមើលកំណត់ត្រាសម្លាប់បន្ថែមនៅខាងក្រៅនោះទេ។> យើងបានពិនិត្យមើលបញ្ជីនេះ ដើម្បីពិនិត្យមើលថាតើមានការបាត់បង់កាលបរិច្ឆេទនៃការសម្លាប់នោះ<ក្នុងបញ្ជី ក.ស.ច.ស យើងនឹងបំពេញបន្ថែម គឺត្រង់អ្នកទោសណាដែលមិនមាននៅក្នុងបញ្ជី។> ហេតុផលដែលយើងបានរកឃើញអ្នកទោសថ្មីនេះ គឺដោយសារថាទាំងបញ្ជីអ្នកទោសចូល ក៏

ដូចបញ្ជីសម្លាប់ គឺមានការបាត់កំណត់ត្រានេះទាំងពីរ។ អ៊ីចឹងបើយើង<គ្រាន់>មើលបញ្ជីអ្នកទោសចូល គឺដោយសារតែការបាត់បង់បញ្ជីនេះ គឺថាយើងមិនអាចដឹងពីចំនួនអ្នកទោសសរុបបានទេ។ អ៊ីចឹងយើងត្រូវពិនិត្យមើលទាំងបញ្ជីអ្នកទោសចូល និងបញ្ជីសម្លាប់។ ហើយនៅក្នុងឧបសម្ព័ន្ធដែលយើងខ្ញុំដាក់ជូនអង្គជំនុំជម្រះនោះ គឺយើងបានរកឃើញថាអ្នកទោស ត្រូវៗ រកទៅឃើញ<ឈ្មោះ>អ្នកទោស ១៨.០០០នាក់ដែលត្រូវបានឃុំខ្លួននៅស-២១។ ឯបញ្ជីដើមបំផុតរបស់<ក.ស.ច.ស> នោះគឺមានកាលបរិច្ឆេទបញ្ជាក់ការសម្លាប់អ្នកទោសជាង៥.០០០នាក់ ហើយយើងរកឃើញកាលបរិច្ឆេទសម្លាប់ហ្នឹង ៦.០០០នាក់ទៀត<>។ នេះគឺជាអ្វីដែលអង្គជំនុំជម្រះស្តាប់ឮពីលោកមេធាវី កូប៉េ <ម្តងហើយម្តងទៀត>ថាម៉េចបានតែមានអ្នកទោស<ក្នុង>បញ្ជី<សម្លាប់>នេះតែ<៥.១០០>នាក់<ជាបញ្ជី ក.ស.ច.ស>។ អ្វីដែលយើងស្តាប់ឮពីអ្នកវិភាគនេះ គឺថា<>គាត់មិនមានពេលវេលា<គ្រប់គ្រាន់ពិនិត្យឯកសារទាំងនោះទេ>។ ឥឡូវនេះយើងមានអ្នកទោសដែលត្រូវបានសម្លាប់ហ្នឹងជាង១១.០០០នាក់ <ដោយមានការបញ្ជាក់រួចហើយ>។

[១០:៤៤:០៣]

ឥឡូវនេះ ខ្ញុំសូមនិយាយអំពី<បញ្ហាសំខាន់ទាក់ទងនឹង>តួនាទីរបស់លោក នួន ជា នៅស-២១។ ភស្តុតាងដែលប្រឆាំងទៅនឹង នួន ជា នេះគឺចេញពីសម្តីរបស់ប្រធានមន្ទីរសន្តិសុខស-២១ <ឌុច>ដែលបានផ្តល់សក្ខីកម្មថា នៅពេលដែល សុន សេន ត្រូវបានចាត់តាំងឲ្យទៅសមរភូមិនៅ<បូព៌ា>ឆ្នាំ១៩៧៧ ដើម្បីបញ្ជាកងទ័ពកម្ពុជាប្រជាធិបតេយ្យនៅក្នុងជម្លោះជាមួយវៀតណាមនោះ ឌុច <ចាប់ផ្តើម>រាយការណ៍ដោយផ្ទាល់ទៅ នួន ជា។ ឌុច បានផ្តល់សក្ខីកម្មថា គាត់បានទទួលបញ្ជាពី នួន ជា ឲ្យសម្លាប់អ្នកទោសទាំងនោះ គឺការសម្លាប់យ៉ាងច្រើន អ្នកទោសមកពីភូមិភាគបូព៌ា នៅពាក់កណ្តាលឆ្នាំ១៩៧៨ និង<សម្លាប់អ្នកទោសនៅសេសសល់>នៅជិតចុងបញ្ចប់នៃរបបនោះ។ ហើយយើងបានបង្ហាញឯកសារនៃការសម្លាប់នេះ យ៉ាងទូលំទូលាយរួចទៅហើយជូនអង្គជំនុំជម្រះ។

ចំណុចសំខាន់នោះ គឺភាពស៊ីសង្វាក់គ្នារវាងសក្ខីកម្មរបស់ ឌុច ទាក់ទងទៅនឹងទំនាក់ទំនងរបស់គាត់ជាមួយនឹង នួន ជា អំពីស-២១ នេះ។ នេះគឺជាចំណុចមួយដែល ឌុច បានឆ្លើយបញ្ជាក់ ហើយយើងក៏បានដឹងផងដែរ ឯកសារពីអតីតកងទ័ពដែលបានផ្តល់សក្ខីកម្មថា ពិតហើយ សុន សេន បានទៅព្រំដែនខាងកើតដើម្បីបញ្ជាកងទ័ព។ នៅពេលសម្ភាសជាមួយ ស្ទីវ ហេដឌ័រ អៀង សារី បានបញ្ជាក់ថា នៅពេលដែល សុន សេន ទៅ<បូព៌ា>គឺថា ឌុច រាយការណ៍ផ្ទាល់ទៅ នួន ជា។ ហើយមានចម្លើយ

សារភាពពីស-២១ នៅខែកុម្ភៈ ឆ្នាំ១៩៧៨ ដែលមានកំណត់ត្រាសរសេរដោយដៃ<របស់>ឌុច ដែលនិយាយអំពីការណែនាំដែលគាត់ទទួលពីបងទី២ ដើម្បីឱ្យដក<>ឈ្មោះទាំងនោះចេញពីចម្លើយសារភាពនេះ។ ហើយលោក លោកស្រីចៅក្រម ក៏ស្ដាប់ឮសក្ខីកម្មពីនីរសារ និងអង្គរក្សរបស់ នួន ជា ឈ្មោះ សូត្រ ទៀង ដែលថា គាត់បានទទួលសំបុត្រផ្ទាល់ពីជនជាប់ចោទ យកទៅឱ្យ ឌុច ហើយក៏យកស្រោមសំបុត្រក្រាស់ៗ ដែលមានឯកសារក្នុងនោះពី ឌុច នេះយកមកឱ្យ នួន ជា។

ហើយមានចម្លើយសារភាពជាច្រើនពីស-២១ ដែលក្នុងនោះមានចំណារនៅទំព័រដំបូងដែលផ្ញើជូននៅ "បងនួន" ហើយក្នុងនោះក៏មានវីដេអូឃ្លីប ដែលជនជាប់ចោទសារភាពជាមួយ <ថេត សម្បត្តិ>ថាគាត់បានទទួលចម្លើយសារភាពជាច្រើន។ ដូច្នេះ ខ្ញុំសូមការអនុញ្ញាតចាក់បង្ហាញវីដេអូឃ្លីបលេខ១។

[១០:៤៧:១៦]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"អ៊ីតែងតែអានរបាយការណ៍សារភាពហ្នឹងបាទ របស់ ស-២១ ដើម្បីយកអាហ្នឹងទៅអប់រំកម្មាភិបាល ដើម្បីកុំឱ្យប្រព្រឹត្តតាមនោះបាទ។ តោះអ៊ី! សូមបញ្ជាក់បន្តិច តើអ៊ី គ្រាន់តែបញ្ជាក់ទេ តើអ៊ីបានអានរបាយការណ៍នេះយ៉ាងម៉េច? ហើយតើយកទៅអប់រំកម្មាភិបាលថ្នាក់ក្រោមយ៉ាងណា បាទ? របាយការណ៍នេះ គ្រាន់តែថាដើម្បី ខ្ញុំមិនដែលបានមើលទាំងអស់ទេ ពីព្រោះវាច្រើនពេក ហើយមិនមែនជាភារកិច្ចរបស់ខ្ញុំមើលណ៎ា។ អាហ្នឹងគេយកអាអ៊ីចឹងៗ ទៅអប់រំឱ្យយល់ សំខាន់វាវ៉ៃយើងខាងសម្ភារៈ។"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១០:៤៨:០៦]

លោក លោកស្រីចៅក្រម ច្បាស់ហើយថា គឺថាមានភស្តុតាងមួយគឺថាមិនអាចប្រកែកបាន គឺថាបើអ៊ីចឹងយើងនិយាយអំពី<ចម្លើយសារភាពនៅ>ស-២១ គឺថា នួន ជា នេះដើរតួនាទីសំខាន់ណាស់ពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខនោះ។

ឥឡូវខ្ញុំសូមលើកឡើងនូវមតិមួយចំនួនពាក់ព័ន្ធទៅនឹង ខៀវ សំផន ដូចបានលើកឡើងនៅក្នុងសារណាររបស់យើងខ្ញុំរួចមកហើយ ខៀវ សំផន មិនមានតួនាទីដូច នួន ជា ទេពាក់ព័ន្ធទៅនឹងស-២១ នេះ <ហើយគ្មាននរណាម្នាក់នៅក្នុងក្រុមរបស់ខ្ញុំជំទាស់រឿងនេះទេ> ប៉ុន្តែ ខៀវ សំផន បានដឹងយ៉ាងច្បាស់ ហើយគាត់គឺថាពិតជាចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួមនេះយ៉ាងច្បាស់ហើយ។ នេះគឺជាមូល

ដ្ឋានរបស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធទៅនឹង ខៀវ សំផន។ ហើយអ្វីដែលយើងឃើញនោះ គឺថាការទទួលខុសត្រូវរបស់ ខៀវ សំផន ពាក់ព័ន្ធទៅនឹងអ្នកទោសនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ជាពិសេសពាក់ព័ន្ធទៅនឹងអតីតព្រះបរមកោដ្ឋ<នរោត្តម សីហនុ>។ ហើយបើសិនណាជាយើងមើលទៅកំណត់កិច្ចប្រជុំ<របស់គណៈអចិន្ត្រៃយ៍ចុះថ្ងៃទី១១> ខែមីនា ៧៦ នៅពេលសម្តេច សីហនុ នេះ លាលែងពីប្រមុខរដ្ឋ<រដ្ឋាភិបាលរួបរួមជាតិកម្ពុជា> គឺថា ខៀវ សំផន គាត់បានយកបញ្ហាមករាយការណ៍ជូនគណៈអចិន្ត្រៃយ៍ <ហើយចូលរួម>ពិចារណា ថាតើព្រះបរមកោដនេះត្រូវបានអនុញ្ញាតឲ្យលាលែង ឬក៏ថា បក្សកុម្មុយនីស្តកម្ពុជានេះ ត្រូវតែប្រហារជីវិតព្រះអង្គចោល។ អ៊ីចឹងនៅក្នុងកិច្ចប្រជុំនេះ គឺមានការសម្រេចថា ព្រះបរមកោដ្ឋមិន<ត្រូវ>អនុញ្ញាតឲ្យចាកចេញទៅក្រៅប្រទេសទេ។ <យើងក៏ដឹងដែរថា បន្ទាប់មក គេ>ទុកឲ្យព្រះអង្គរស់រានមានជីវិត ហើយ<ឃុំ>ទុកព្រះអង្គនៅក្នុងព្រះបរមរាជវាំងនេះចុះ។ ហើយនៅពេលដែលព្រះអង្គមានជីវិត រស់រានមានជីវិតបែបនេះ គឺថាព្រះអង្គមិនបានជំទាស់តវ៉ាអ្វីនោះទេ។ <នៅ*ស្លាយ*បន្ទាប់ទៀត ក៏វាសំខាន់ដែរ។> នៅក្នុងកិច្ចប្រជុំនេះ ដែលគណៈអចិន្ត្រៃយ៍បានសម្រេចនោះ គឺត្រូវធ្វើលិខិត<>ទៅឲ្យកូនចៅរបស់ព្រះអង្គដើម្បីឲ្យត្រឡប់ចូលមក<ប្រទេសកម្ពុជា> ចូលរួមពិធីបុណ្យ<ចូលឆ្នាំថ្មី>ឯករាជ្យ។ <ប៉ុន្តែ តាមកំណត់កិច្ចប្រជុំនោះ បានបញ្ជាក់ថា ហេតុផលពិតប្រាកដ គឺគេត្រូវ>ដោះស្រាយ<បញ្ហាឲ្យ>ជ្រះស្រឡះ<>។ <ដូចយើងដឹងស្រាប់ហើយ> កូនចៅក៏ដូចជាញាតិសន្តានរបស់ព្រះអង្គ គឺថាត្រូវបានសម្លាប់ចោលយ៉ាងច្រើននៅក្នុងរបបនោះ ហើយព្រះអង្គក៏បានលើកឡើងអំពីចំណុចនេះផងដែរ។

នៅដើមដំបូងនៃសារណាររបស់ខ្ញុំ ការលើកឡើងរបស់ខ្ញុំពីម្សិលមិញនេះគឺ ខៀវ សំផន បាននិយាយ និងបានចូលរួមយ៉ាងច្រើននៅក្នុងកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ពាក់ព័ន្ធទៅនឹងការចាប់ខ្លួន និងបញ្ហាសន្តិសុខ។ ហើយនៅក្នុងវីដេអូ ដែលលោក លោកស្រីចៅក្រមនឹងឃើញនេះ គឺជនជាប់ចោទបានបង្ហាញអំពីការដឹងឮរបស់គាត់ដោយផ្ទាល់ នៅក្នុងកិច្ចប្រជុំរបស់ថ្នាក់ដឹកនាំដែលបានធ្វើសេចក្តីសម្រេចនេះ ថាតើត្រូវចាប់ចងកម្មាភិបាលរបស់បក្សកុម្មុយនីស្តកម្ពុជានេះបន្តទៅទៀត ឬយ៉ាងណានោះ<។ សូមចាក់ឃ្លីបលេខ២!>

[១០:៥១:៥៥]

*(ការបង្ហាញឯកសារសំឡេង-រូបភាព)*

*"ការចាប់ចងនោះ វាជាប់នឹងការឃុំឃាំង ដាក់គុក ហើយវាជាប់នឹងការស្លាប់អីហ្នឹងហើយ។*

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

*លើបញ្ហានេះ ខ្ញុំយល់ឃើញថា ត្រូវបែងចែកការចាប់ចង ដោយលោក សាឡុត ស ដោយលោក ប៉ុល ពត បានរួមផ្ទាល់ជាមួយគណៈអចិន្ត្រៃយ៍សម្រេច និងការចាប់ចងដែលកន្លែងផ្សេងៗ គេបានធ្វើដោយខ្លួនគេ នៅតាមភូមិភាគ នៅតាមតំបន់របស់គេ។ ហើយគេចាប់ចងហើយ គេដាក់គុកនៅកន្លែងគេ ឬមួយក៏បញ្ជូនមកស-២១អី វា អាហ្នឹងវាជារឿងផ្សេង វារឿងល្អិតទេ។ ដូច្នេះ លោក ប៉ុល ពត តាំងក្នុងឋានៈលោកដឹកនាំ លោកគិតគូរចាប់ចងតែកម្មាភិបាលណាដែលប្រព្រឹត្តខុស។ ដូច្នេះ ជាចំនួនតិចទេ ដោយប្រៀបធៀបនឹងការចាប់ចងទូទៅប្រទេស។ សូមជម្រាបថា មានការចាប់ចងពីរ គឺការចាប់ចងលោក ចាន់ ចក្រី ដំបូងបង្អស់ ដែលជាប្រធានកងពលលេខ១៧០ ខាងបូព៌ា និងការចាប់ចងលោក ឈូក ដែលជាលេខាតំបន់២៤ គឺកំពង់ត្របែក ខាងបូព៌ាដែរ។ ការចាប់ចងកម្មាភិបាលទាំងពីរនេះ នាំឲ្យរាលដាលទៅចាប់ចងកម្មាភិបាល ដែលគេហៅថា ជំនាន់សង្គ្រាម៩ឆ្នាំ រួមជាមួយវៀតមិញ រឺបារាំង។ ផ្តាច់យល់ របៀបរបបធ្វើការរបស់លោក ប៉ុល ពត លើបញ្ហាអ្វីក៏ដោយ គាត់ត្រូវការតែប្រមូលឯកសារឲ្យច្រើន ប្រមូលព័ត៌មាន ប្រមូលសភាពការណ៍ឲ្យបានច្រើនមែនទែន មុននឹងសម្រេច។ នេះការទម្លាប់របស់គាត់។”*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១០:៥៥:១៦]

ខៀវ សំផន បានរៀបរាប់អំពីសេចក្តីសម្រេចឲ្យចាប់ខ្លួននៅក្នុងវិដេអូឃ្លីបនេះ គឺថាបានរៀបរាប់លម្អិតតែម្តង។ <គាត់បានប្រាប់ថា គាត់ដឹងអំពីរបៀបធ្វើការជាមួយ> ប៉ុល ពត<។> លោកលោកស្រីថៅក្រម នៅខែដំបូងនៃឆ្នាំ១៩៧៧ <មានមេដឹកនាំពីរនាក់>ដែល<តែងតែ>ចូលរួមក្នុងគណៈអចិន្ត្រៃយ៍<ជាមួយ> ខៀវ សំផន និង នួន ជា <គឺ>មាន កុយ ធួន <និង>សឿ វ៉ាស៊ី ហៅ ឌឿន <> ត្រូវ<ចាប់>បញ្ជូនទៅ<មន្ទីរស-២១> ហើយ<មានសមាជិកដទៃ>ដែលធ្វើការ<ជាមួយ ខៀវ សំផន >នៅមន្ទីរ<គណៈនយោបាយ> ៨៧០ <ផងដែរ>។ ហើយនៅថ្ងៃទី១០ មេសា ឆ្នាំ១៩៧៧ <មិត្តដ៏យូរអង្វែងរបស់ ខៀវ សំផន ហើយជា>ខ្មោចទាំងបី គឺរដ្ឋមន្ត្រីក្រសួងព័ត៌មាន ហ៊ូ នឹម នេះក៏ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅ ស-២១ ដែរ។ ក្រៅពីការចាប់ខ្លួន សហការីរបស់គាត់នេះ គឺថា ខៀវ សំផន បានបន្តគាំទ្រ អស់ពីចិត្ត ពីថ្លើម និងបានជួយអនុវត្តគោលនយោបាយចំពោះខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជានេះ។ ហើយនៅក្នុងសុន្ទរកថា<ថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៧ >តែប៉ុន្មានថ្ងៃ<ក្រោយ>ពេលការចាប់ខ្លួន ហ៊ូ នឹម, ខៀវ សំផន បាននិយាយថា “យើងត្រូវតែបោសសម្អាតខ្មាំង ហើយ<អនុវត្ត>តាម<>

គោលនយោបាយជាតិ និងគោលនយោបាយអន្តរជាតិ <និងគោលនយោបាយយោធា>។ អ្វីៗទាំងអស់ហ្នឹង គ្រប់យ៉ាង ត្រូវធ្វើឲ្យបានស្អាត និងឲ្យបានជ្រះស្រឡះ។”

លោក លោកស្រីចៅក្រម ក៏បានស្តាប់សក្ខីកម្មពី ស្ទីវ ហេដឌ័រ នៅក្នុងសវនាការទី១<។ >នៅក្នុងឆ្នាំ១៩៨០ មុនពេលដែល ខៀវ សំផន អាចអានសៀវភៅណាមួយ<ដែល>និយាយអំពីរបបនោះបាននេះ។ អ៊ីចឹង ខៀវ សំផន បានបង្ហាញនៅក្នុងកិច្ចសម្ភាសន៍នេះ ប្រាប់ ស្ទីវ ហេដឌ័រ យ៉ាងទូលំទូលាយអំពីថា ខ្មែរដែលលាក់ខ្លួន និងធ្វើជាភ្នាក់ងាររបស់យួន <ចូលបង្កប់ខ្លួនជា>កម្មាភិបាលថ្នាក់ខ្ពស់នៅថ្នាក់ភូមិភាគ និងក៏នៅក្នុងចំណោមគណៈអចិន្ត្រៃយ៍ក៏ដូចគណៈមជ្ឈិមផងដែរ។ ហើយគាត់ក៏បាន<ប្រាប់ ហេដឌ័រ ដែរ> សូមដកស្រង់៖ “នៅក្នុងឆ្នាំ១៩៧៧, ៧៨ គឺថាយើង<អាច>ដោះស្រាយជាមួយអ្នកទាំងអស់នោះ ឲ្យបានចប់សព្វគ្រប់ទាំងស្រុងតែម្តង។” បញ្ចប់ការដកស្រង់។ លោក លោកស្រីចៅក្រម ភស្តុតាងដែលយើងបានស្តាប់លោក ខៀវ សំផន នេះ<ច្រានចោលពាក្យកុហក ដែលយើងបានស្តាប់ពីគាត់ -- គាត់និយាយប្រាប់ ក.ស.ច.ស -- ថាគាត់មិនដឹងថា> មានការចាប់ខ្លួនណាម្នាក់ទេក្នុងរបបកម្ពុជាប្រជាធិបតេយ្យទាំងមូលនោះ។

[១០:៥៨:២២]

លោក លោកស្រីចៅក្រមបានស្តាប់ឮ<ក្នុងការជំនុំជម្រះវគ្គ២>អំពីការអប់រំនយោបាយ<ដោយជនជាប់ចោទទាំងពីររូប រួមគ្នាតែម្តង។> ហើយលោក លោកស្រីចៅក្រមបានស្តាប់ឮសក្ខីកម្មរបស់អ្នកដែលបញ្ជាក់ថា នួន ជា និង ខៀវ សំផន បាននិយាយអំពីមេដឹកនាំដទៃទៀតដែលក្បត់បក្ស ដូចជា កុយ ធួន ហើយសាក្សី ដូចជា អែម អឿន, តាហែម, រស់ ស៊ុយ ទាំងអស់នេះ សុទ្ធតែបានផ្តល់សក្ខីកម្មអំពីការប្រជុំនយោបាយ។ រស់ ស៊ុយ បាន<ចាំច្បាស់>អំពី នួន ជា ចាក់ខ្សែអាត់ចម្លើយសារភាពរបស់ កុយ ធួន។ ហើយនៅចុងសវនាការនេះ គឺយើងបានស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី <ព្រាប ឈុន>ដែលបាននិយាយអំពីសុន្ទរកថារបស់ ខៀវ សំផន ថ្លែងទៅកាន់ប្រជាជន<មកពីភូមិភាគ>បូព៌ា<ហើយខ្ញុំនឹងចាក់នៅពេលបន្តិចទៀតនេះ>។ ហើយខ្ញុំគិតថា នៅពេលនោះគឺមានការបង្ហាញផងដែរ ហើយនៅក្នុងវីដេអូនោះគឺ ខៀវ សំផន បានបញ្ជាដល់ប្រជាជនមិនឲ្យក្បត់បក្ស ប្រសិនបើក្បត់បក្ស នឹងត្រូវសម្លាប់ចោល។

<>ខ្ញុំសូម<បញ្ចប់ ដោយត្រឡប់មកនិយាយ>ជាលើកចុងក្រោយសម្រាប់ខ្ញុំនៅទីនេះ គឺនិយាយអំពីការសម្ភាសរបស់ ថេត សម្បត្តិ ជាមួយនឹង នួន ជា។ ហើយយើងបានឃើញរួចមកហើយដែលថា

ក្នុងការសម្ភាសនេះ ជនជាប់ចោទបានបញ្ជាក់យ៉ាងច្បាស់ថា គាត់គាំទ្រដល់ការសម្លាប់ជនក្បត់នៅក្នុងរបបនោះ។ ហើយខ្ញុំសូមអនុញ្ញាតចាក់បញ្ចាំងខ្សែវីដេអូ<*ឃ្លីប*>៣។

[១១:០០:១៨]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"អ៊ីការចំពោះកម្មាភិបាលដូចពួកក្បត់ៗហ្នឹង អ៊ីៗពួកហ្នឹងសមទទួលនឹងការស្លាប់អ៊ីចឹងទេយ៉ាងណាបាទ? អ៊ឹបញ្ជាក់ចំណុចហ្នឹងបន្តិច។ ទេ ខ្ញុំមិនប៉ាននថាទេ ពីព្រោះបើថាទៅ គេថាឯងឃោរឃៅ ប៉ុនបើយើងមើល ត្រូវមើលអ៊ីចេះសម មិនសម គ្រោះថ្នាក់របស់ជាតិប៉ុនណា កុំឲ្យមើលជាបុគ្គលប៉ុណ្ណឹងទៅ បើពួកហ្នឹងនៅ។ វាប់សតវត្សរ៍ណា កូនចៅយើងជំនាន់ក្រោយ វាទៅជាស្អី រូបភាពជាខ្មែរ ប៉ុន្តែខ្លឹមសារវាជាស្អី អាហ្នឹងយើងត្រូវថ្លឹងមើលអាហ្នឹង បានប៉ាននវិនិច្ឆ័យថាការដោះស្រាយហ្នឹងត្រូវ។ ប៉ុន្តែបើថាមិនមើលឲ្យទូលាយណា មើលឃើញតែចង្អៀតណា ឃើញពីរឿងអាណិតអាសូរគ្នាអីគ្នាហ្នឹង អាហ្នឹងអត់ទេ ប្រទេសជាតិទៅហើយ ទៅហើយ។ ឯខ្យល់ខ្លួនទុកដោយឡែកសិន ដោះស្រាយសិនទៅ។ អ៊ីចឹងអ៊ឹមានការសោកស្តាយចំពោះពួកនោះទេបាទ? ខ្ញុំដូចគ្មានការសោកស្តាយទេ។ អ្នកប្រព្រឹត្តឃោរឃៅហ្នឹង យើងដោះស្រាយយ៉ាងម៉េចអ៊ឹបាទ? សម្លាប់ កម្ទេចហ្នឹង ទុកធ្វើអី ពីព្រោះទុកទៅ វានាំប៉ះពាល់ដល់មាគ៌ា ធ្វើបាបប្រជាជន វាធ្វើបាបប្រជាជន។ អ៊ីចឹងដែល ប៉ុល ពត សម្រេចសម្លាប់អ្នកទាំងអស់ហ្នឹងបាន តើអ៊ឹយល់ឃើញយ៉ាងណាដែរបាទ? ចំពោះខ្ញុំមិនឃើញយ៉ាងណាទេ ពេលនោះក៏អត់យល់ឃើញយ៉ាងណាទេ យល់ឃើញដោះស្រាយទៅ ឲ្យវាស្រឡះទៅ ឲ្យត្រូវ យល់ដោះស្រាយត្រូវ។"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១១:០២:០១]

**លោក ឌេល លីសាក់៖**

លោក លោកស្រីចៅក្រម ថេត សម្បត្តិ គាត់បានសួរសំណួរយ៉ាងល្អទៅលោក នួន ជា ទៅលើចំណុចនេះ។ នៅពេលដែល ថេត សម្បត្តិ សួរគាត់ថាហេតុអ្វីបានជាមេដឹកនាំបក្សកុម្មុយនីស្តត្រូវសម្លាប់ជនក្បត់<ដែលជាប់ចោទ>ទាំងនោះ? ហេតុអ្វីមិនឃុំខ្លួនមួយជីវិតទៅ? នួន ជា បានឆ្លើយតបនូវចម្លើយដែលគួរឲ្យចាប់អារម្មណ៍មួយ ហើយខ្ញុំសូមដកស្រង់៖ "សំណួរហ្នឹងស្រួលសួរ ប៉ុន្តែពិបាកឆ្លើយ។ នៅពេលហ្នឹង យើងគ្មានគុកត្រឹមត្រូវនោះទេ បើសិនបើយើងទុកវាៗនឹងបែកខ្ញែក កើតកូនកើតចៅ ហើយពេលហ្នឹង ប្រាកដជាត្រូវសម្លាប់ច្រើនឡើងថែមទៀត។" សូមបញ្ចប់ការដកស្រង់។ ការអះអាងដែលថា

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ពួក<គេ>មិនមានគុកហ្នឹង គឺបង្ហាញយ៉ាងច្បាស់ថាវាជា<ពាក្យ>កុហក ប៉ុន្តែអ្វីដែលគួរឲ្យរន្ធត់ញាប់ញ័រយ៉ាងខ្លាំង គឺដូចតទៅនេះ "ប្រសិនបើយើងទុកពួកវា១នឹងបែកខ្ញែក បង្កើតកូនបង្កើតចៅតទៅទៀត។" ការពិតនេះ នេះគ្រាន់តែជាការដោះសារទៅដល់ការសម្លាប់តែប៉ុណ្ណោះ ហើយយើងឃើញថា <> ចម្លើយរបស់ នួន ជា ហើយគាត់យល់ស្របជាមួយនឹងការអនុវត្តរបស់បក្ស<កុម្មុយនីស្ត>កម្ពុជា ដែលយើងបានស្តាប់ឮយ៉ាង<វែងអំពីការចាប់ខ្លួន និង>ការសម្លាប់ ដែលមិនមែនសម្លាប់ត្រឹមតែអ្នកដែលត្រូវបានគេចោទប្រកាន់ថាក្បត់ មិនស្មោះត្រង់នោះទេ ប៉ុន្តែសម្លាប់ដល់កូនចៅ ប្រពន្ធកូន ដល់ប្រពន្ធកូនថែមទៀតផង <ដូចដែលគាត់និយាយថា៖ ">ប្រសិនបើយើងទុក វានឹងបែកខ្ញែកកើតកូនកើតចៅ។"

ឥឡូវនេះ ខ្ញុំសូមប្រគល់វេទិកាជូនលោក គូមជែន ដែលជាសហព្រះរាជអាជ្ញាអន្តរជាតិ <គាត់លើកឡើងអំពីបញ្ហាប្រល័យពូជសាសន៍។>សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រមដែលបានផ្តល់ឱកាសដល់យើងខ្ញុំ។

[១១:០៤:៣០]

**លោក នីកូឡាស គូមជែន៖**

ខ្ញុំសូមទោស ដោយសារខ្ញុំមានបញ្ហាជាមួយនឹង កាសរបស់ខ្ញុំ សូមអនុញ្ញាតឲ្យមន្ត្រីតុលាការជួយសម្រួលទៅលើកាសរបស់ខ្ញុំផង។

សូមជម្រាបសួរ លោកប្រធាន លោក លោកស្រីចៅក្រម។ ខ្ញុំសូមចាប់ផ្តើមថ្លែងអំពីឧក្រិដ្ឋកម្មទៅលើជនជាតិវៀតណាម និងជនជាតិចាម ហើយ<ជាពិសេស>ខ្ញុំ<ចង់>និយាយអំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ប្រឆាំងទៅលើជនជាតិចាម និងវៀតណាម។ ហើយខ្ញុំនឹងនិយាយ<ខ្លះៗ>អំពីច្បាប់នៃអំពើប្រល័យពូជសាសន៍ ព្រោះនេះគឺជាផ្នែកសំខាន់មួយនៃយុត្តិសាស្ត្រអន្តរជាតិ ដែលកំពុងតែ<បង្កើត> ហើយមនុស្សមួយចំនួនមិនយល់អំពីធាតុផ្សំនៃអំពើប្រល័យពូជសាសន៍នោះឡើយ។

<លោក លោកស្រីចៅក្រមជាទីគោរព!> អំពើប្រល័យពូជសាសន៍គឺជាឧក្រិដ្ឋកម្មទៅលើក្រុមមួយ។ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មិនអាស្រ័យទៅលើចំនួនមនុស្សដែលត្រូវសម្លាប់នោះឡើយ គឺមិនគិតអំពីចំនួនមនុស្ស ដូចឧក្រិដ្ឋកម្មសម្លាប់រង្គាលនោះឡើយ គឺយើងមានបទចោទសម្លាប់រង្គាលដែរ នៅក្នុងសំណុំរឿង ហើយមានការចោទប្រកាន់ជាច្រើនទាក់ទងទៅលើការសម្លាប់រង្គាល ដែលតម្រូវឲ្យមានការសម្លាប់ជាទ្រង់ទ្រាយធំ<>ដូចជាការសម្លាប់នៅ<តាម>សហករណ៍ នៅការដ្ឋានសហករណ៍ ឬក៏នៅ<មន្ទីរសន្តិសុខនានា។ តាមទ្រឹស្តី> អំពើប្រល័យពូជសាសន៍ សូម្បីតែសម្លាប់មនុស្សម្នាក់ក៏អាចចាត់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ទុកថាជាប្រល័យពូជសាសន៍បានដែរ ឲ្យតែមានចេតនាបំផ្លាញក្រុម<មនុស្សណា>មួយ<>ហើយក្រុមហ្នឹងអាចជាក្រុមពូជសាសន៍ ជាតិសាសន៍ ឬក៏ជាតិពន្ធុណាមួយ <ឬក្រុមសាសនាណាមួយ>។ ហើយនៅក្នុងករណីជាក់ស្ដែងនេះ គឺយើងមានបទចោទប្រល័យពូជសាសន៍ទៅលើក្រុមពីរ គឺទី១ ក្រុមជនជាតិវៀតណាមនៅកម្ពុជា និងក្រុមជនជាតិចាមនៅក្នុងប្រទេសកម្ពុជា។

នៅក្នុងឆ្នាំ<១៩៤៦ ភ្លាមៗក្រោយពីសង្គ្រាមលោកលើកទី២> មហាសន្និបាតអង្គការសហប្រជាជាតិបានចេញសេចក្ដីសម្រេចទៅលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ <ដោយ>នៅពេលនោះមិនទាន់មាន<ពាក្យនេះនៅឡើយ>ទេ។ នៅក្នុងថ្ងៃ១១ ធ្នូ ៤៦ គឺបានបញ្ជាក់ថា អំពើប្រល័យពូជសាសន៍គឺជាការបដិសេធសិទ្ធិមានអាទិភាពរបស់ក្រុមមនុស្សមួយក្រុម ហើយវាជាអំពើមនុស្សឃាត ដែលជាការបដិសេធសិទ្ធិក្នុងការរស់នៅរបស់បុគ្គលណាម្នាក់។ ការបដិសេធសិទ្ធិក្នុងការមានអាទិភាពបែបនេះ ធ្វើឲ្យមានផលប៉ះពាល់ទៅដល់មនសិការប្រជាជនរបស់មនុស្សជាតិ ហើយបណ្ដាឲ្យមានការបាត់បង់ធ្ងន់ធ្ងរដល់មនុស្សជាតិជាងក្នុងលក្ខណៈ<ជា>វប្បធម៌ <និងវិភាគទានដែលតំណាងឲ្យក្រុមមនុស្សជាតិទាំងនេះ> ហើយវាផ្ទុយទៅនឹងច្បាប់គុណធម៌ផងដែរ។

[១១:០៧:៤៤]

<និយមន័យពាក្យអំពើប្រល័យពូជសាសន៍> ដែលខ្ញុំសូមបង្ហាញនៅលើអេក្រង់ផងដែរ <លោកលោកស្រីចៅក្រមដឹងស្រាប់ហើយ ខ្ញុំគ្រាន់តែរំឮកអ្នកទាំងអស់គ្នាប៉ុណ្ណោះ គឺ>វាតម្រូវឲ្យមានសកម្មភាពចំនួនប្រាំ ដែលធ្វើឡើងដោយមានចេតនាបំផ្លាញជារួម ឬក៏ដោយផ្នែក។ គឺជាចំណុចសំខាន់មួយ ជារួម ឬក៏ដោយផ្នែកទៅលើក្រុមជាតិសាសន៍ ពូជសាសន៍ ជាតិពន្ធុ ឬក៏ក្រុមសាសនា។ ហើយខ្ញុំសូមនិយាយអំពីពាក្យទាំងអស់នេះ។ សកម្មភាព<ទាំងប្រាំគឺជាការសម្លាប់សមាជិកក្រុម។>ទី១<>គឺជាអ្វីដែលយើងចោទប្រកាន់នៅក្នុងដីកា<ដំណោះស្រាយ>នេះ គឺការសម្លាប់ទៅក្រុមជនជាតិវៀតណាមនិងចាមនៅក្នុងប្រទេសកម្ពុជា ដែលធ្វើឡើង<ដោយផ្នែក ដោយ>សម្លាប់<សមាជិកក្រុមនេះ>។ ប៉ុន្តែអ្វីដែលសំខាន់បំផុត ដែលយើងត្រូវយល់អំពីឧក្រិដ្ឋប្រល័យពូជសាសន៍ គឺយើងមើលទៅលើប្រភេទ ថាតើគេធ្វើឡើងដោយមានចេតនាកម្ទេចក្រុមនោះដែរឬអត់។ សកម្មភាពទី២ បង្កឲ្យមានព្យសនកម្មផ្លូវកាយ ឬក៏ផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរទៅលើសមាជិកក្រុម។ ហើយទី៣ គឺធ្វើឲ្យមានស្ថានភាពរស់នៅមួយដែលអាចបណ្ដាលឲ្យមានការបំផ្លិចបំផ្លាញផ្នែករូបរាងកាយ។ ៤) គឺការដាក់វិធានការដើម្បីការពារមិនឲ្យមានកំណើត និងទី៥ គឺការជម្លៀសដោយបង្ខំទៅលើក្មេងៗរបស់ក្រុម<មួយ>ទៅនៅក្រុមផ្សេង<>

ទៀត។

ឥឡូវនេះ ខ្ញុំចង់លើកយកនូវចំណុចសំខាន់មួយ <តែដំបូង ខ្ញុំសូមលើកចំណុចមួយ>ដែលមេធាវីការពារក្តីបានលើកឡើង<>នៅក្នុងសារណារបស់<ខ្លួន ជាពិសេស សារណារបស់មេធាវីលោក នួន ជា ដដែលជាដដែល ដែលមេធាវីការពារបានលើកឡើងខុស>ចេតនាដែលទាក់ទងទៅនឹងសហឧក្រិដ្ឋកម្មរួមនោះទេ។ នៅក្នុងសារណានោះ គឺថាក្រុម នួន ជា បានលើកឡើងដូចតទៅនេះថា ចារីផ្ទាល់នៃអំពើនោះ ត្រូវតែមាន<ការចូលរួម>ចេតនាជាក់លាក់សម្រាប់ឧក្រិដ្ឋកម្មនោះជាមួយនឹងសមាជិករបស់សហឧក្រិដ្ឋកម្មរួម។ ពួកគេបានដកស្រង់នូវសាលក្រមរបស់ ប៊ែនចាមិន កថាខណ្ឌ៧០៨។ <ឥឡូវ > ពួកគេលើកឡើងត្រឹមត្រូវដែរ<អំពី>សាលក្រមរបស់ ប៊ែនចាមិន<នោះ។ តាមពិត បញ្ហាចោទនៅក្នុងការជំនុំជម្រះដែលពួកគេលើកឡើងមាននៅក្នុងកថាខណ្ឌនោះឯង គឺថា តើ>ចារីផ្ទាល់ហ្នឹង ត្រូវតែជាសមាជិកនៃសហឧក្រិដ្ឋកម្មរួមនោះ<មែន ឬអត់? ចំពោះរឿងនេះ អង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្តីសម្រេចថា មែន> ប៉ុន្តែដោយសារតែអ៊ីចឹងហើយទើបមានការប្តឹងសាទុក្ខនៅក្នុងនៅក្នុងរឿងនោះដែរ ព្រោះនៅពេលនុ៎ង អង្គជំនុំជម្រះតុលាការកំពូលបានពិនិត្យទៅលើបញ្ហាទាំងអស់នេះ ទៅលើយុត្តិសាស្ត្រទាំងអស់ ហើយបានទទួលស្គាល់ថា ចារីផ្ទាល់នុ៎ង អាចជាសមាជិករបស់ក្រុម<ដែលបានប្រព្រឹត្ត>ឧក្រិដ្ឋកម្ម<។> ឧទាហរណ៍ ប្រសិនបើសន្តិសុខជើងឯកមាន គឺសម្លាប់ជនជាតិចាម ឬវៀត-ណាមដោយចបកាប់អាហ្នឹង គឺវាមិនសំខាន់ទេ ព្រោះសំខាន់គឺគេធ្វើតាមបញ្ជា<។ ដូចគ្នាដែរ ក្នុងករណី *ស្រេប្រេនីកា* ដែលបានបាញ់សម្លាប់មនុស្ស ១២.០០០ រួមទាំងកូនក្មេងផង ត្រូវបានកំណត់ថា ជាអំពើប្រល័យពូជសាសន៍។> ដូច្នេះវាមិនចាំបាច់ ថាតើអ្នកដែលសម្លាប់ហ្នឹង មានចេតនាសម្លាប់ក្រុមនោះឬក៏អត់នោះទេ ប៉ុន្តែអ្វីដែលសំខាន់ គឺថាពួកគេត្រូវបានប្រើប្រាស់ដោយសមាជិករបស់សហឧក្រិដ្ឋកម្មរួមក្នុងការប្រព្រឹត្តអំពើទាំងអស់នោះ។ នៅក្នុងសាលដីការបស់ ប៊ែនចាមិន កថាខណ្ឌ៤១០ <អង្គអំនុំជម្រះបណ្តឹងសាទុក្ខបានសម្រេចថា> អ្វីដែលសំខាន់នៅក្នុងក្រុមសហឧក្រិដ្ឋកម្មរួម ទី១ គឺមិនសំខាន់ថាតើអ្នក<ណា>ដែលធ្វើអំពើសត្យានុម័តនោះទេ ប៉ុន្តែសំខាន់ ថាតើឧក្រិដ្ឋកម្មដែលជាបញ្ហាហ្នឹង កើតមកពីផ្នែកមួយនៃគោលបំណងរួម ឬក៏អត់នោះ? ហើយនិងក្នុង កា<រ៉ា>ស៊ីក គឺក្នុងសេចក្តីសម្រេច ការ៉ាស៊ីក ៩៨ស្ទួន កថាខណ្ឌ៧៩ <តុលាការឧទ្ធរណ៍> គឺបានបញ្ជាក់បន្ថែម<យ៉ាងច្បាស់>តទៅទៀត គឺតុលាការ<>បានបញ្ជាក់ថា “វាមិនអាចសម្រេចបានថា តើសមាជិកមិនមែនសហឧក្រិដ្ឋកម្មរួមមានធាតុផ្សំអត្តនោម័តិរបស់សមាជិកសហឧក្រិដ្ឋកម្ម ឬក៏អត់ ឬក៏ថាអ្នកមិនមែនជាសមាជិក ជេ.ស៊ី.អ៊ី

ហ្នឹងដឹងពីអត្ថិភាពរបស់ ជេ.ស៊ី.អ៊ី ឬក៏អត់នោះទេ ការពិតវា គឺជាចេតនាប្រល័យពូជសាសន៍របស់កាវ៉ាស៊ីក ហើយនិងសមាជិកដទៃទៀត មិនមែនជាចេតនារបស់ចារីផ្ទាល់ដែលប្រព្រឹត្តអំពើប្រល័យពូជសាសន៍នោះទេ។ ដូច្នេះគឺទាំងអស់នេះ គឺជាគោលដៅសម្រាប់ការសម្រេចទៅលើសហឧក្រិដ្ឋកម្មរួម <>។”

[១១:១២:៤២]

យើងមានសៀវភៅ<មួយក្បាលនៅក្នុង>បណ្ណាល័យ<តូច> របស់ អ.វ.ត.ក <យើងនេះ មានចំណងជើងថា “ទ្រឹស្តីរួមនៃចេតនាប្រល័យពូជសាសន៍” ខ្ញុំគិតថា នៅក្នុងទំព័រ២២១ លើកឡើងពីបញ្ហានេះយ៉ាងច្បាស់ ដោយ>អ្នកនិពន្ធនិយាយថា “អ្នកប្រព្រឹត្ត<ថ្នាក់ក្រោម ជាអ្នកបាញ់ប្រហារ ជាពេជ្ឈឃាដនៅជើងឯក ដោយប្រើចបកាប់ និងកាំបិត ពួកគេមិនមែនកាន់កាប់តួនាទីអ្វី ដែលអាច>បំផ្លាញក្រុមជារួមនោះទេ ដូច្នេះពួកគេមិនអាចបង្កើតបានជាចេតនាបែបនោះឡើយ។ ដូច្នេះទោះបីថា ចារីផ្ទាល់នៅថ្នាក់<ក្រោម>នៃសហឧក្រិដ្ឋកម្មរួមប្រល័យពូជសាសន៍ មានចេតនាប្រល័យពូជសាសន៍ ឬក៏អត់ គឺវាមិនសំខាន់នោះទេ។ គឺវាមិនសំខាន់សម្រាប់ការទទួលខុសត្រូវផ្ទាល់ទៅលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នោះឡើយ។

ឥឡូវនេះ ខ្ញុំសូមបន្តទៅនិយាយអំពីឧក្រិដ្ឋកម្មប្រឆាំងជនជាតិវៀតណាម ជាពិសេស គឺប្រល័យពូជសាសន៍ទៅលើជនវៀតណាម។ ភស្តុតាងនៅក្នុងរឿងក្តីនេះ បានបង្ហាញថា មានចេតនាដែលត្រូវធ្វើចំពោះជនជាតិវៀតណាមនៅពេលនោះ។ នៅពេលដើមដំបូងរបបហ្នឹង គឺថារបបកម្ពុជាប្រជាធិបតេយ្យនេះ អាចថាមុននេះផង គឺចាប់តាំងពីឆ្នាំ<១៩៧៣>មក គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាគឺមានចេតនាបណ្តេញជនជាតិវៀតណាមចេញពីកម្ពុជា គឺបណ្តេញចេញ<ឲ្យវិលត្រឡប់ទៅប្រទេសវៀតណាមវិញ>។ ចេតនានេះវាប្រែប្រួលទៅតាមពេលវេលា ហើយយើងឃើញនៅពេលក្រោយបន្ទាប់មកនៅក្នុងរបបនោះគឺមានចេតនាសម្លាប់ជនជាតិវៀតណាមទាំងអស់ដែលមាននៅក្នុងប្រទេសកម្ពុជា ទាំងជនជាតិវៀតណាម ទាំងអ្នកដែលពួកគេគិតថា ជាវៀតណាម អាចថាជាវៀតណាមសុទ្ធ ឬក៏កូនកាត់វៀតណាម ឬក៏ដែលមានប្រវត្តិជាវៀតណាមនោះ។ នេះមិនមែនជារឿងចម្លែកនោះទេ ប្រសិនបើយើងដឹងអំពីប្រវត្តិនៃសេចក្តីសម្រេចចុងក្រោយរបស់ ហ៊ីត្លែរ <ដោយ>មានចេតនាបណ្តេញជនជាតិជ្វីសចេញពីគ្រប់តំបន់ដែលគ្រប់គ្រងដោយអាល្លឺម៉ង់ ហើយ<ដាក់>ផែនការហ្នឹង គឺនាំទៅដល់ការសម្លាប់ជនជាតិជ្វីសទាំងអស់នៅក្នុងតំបន់ដែលគ្រប់គ្រងដោយអាល្លឺម៉ង់។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១១:១៥:០៨]

ការបញ្ជូនបុគ្គលណាម្នាក់មិនមែនជាអំពើប្រល័យពូជសាសន៍នោះទេ។ ការនិរទេសមិនមែនជាអំពើប្រល័យពូជសាសន៍នោះទេ។ ប៉ុន្តែ<វាក៏សំខាន់ដែរ ដែល>យើងត្រូវពិនិត្យមើលទៅលើយុត្តិសាស្ត្រ ហើយយុត្តិសាស្ត្របង្ហាញថា ការបញ្ជូនមនុស្សណាម្នាក់ហ្នឹង អាចជាភស្តុតាងសំខាន់នៃចេតនាក្នុងការកម្ទេចក្រុម ហើយក្នុងករណីយើងនេះ គឺកម្ទេចវៀតណាមនៅក្នុងប្រទេសកម្ពុជា។ នៅក្នុងស្ថានភាពប្រហែលគ្នាដែរ នៅក្នុងតុលាការ<ឧទ្ធរណ៍ *ក្រីស្ទីក*> គឺគេបានរកឃើញយ៉ាងច្រើនថា កងកម្លាំង ស៊ែបបានប្រមូលផ្ដុំ ឬក៏កេណ្ឌ<បុរសៗ និង>ក្មេងៗជាច្រើន<ដែលមានអាយុជិតចូលកងទ័ព យកទៅសម្លាប់> ហើយបានបញ្ជូនទាំងស្ត្រី ទាំងកុមារចេញ។ ដូច្នេះ <តុលាការឧទ្ធរណ៍ *ក្រីស្ទីក* បានសម្រេចក្ដី>ថា<>ការបញ្ជូនក្មេងៗ ស្ត្រី និងមនុស្សចាស់<ចេញពីលំនៅដ្ឋានរបស់គេ គឺជាមធ្យោបាយបន្ថែមមួយ ដែល>ធានាឲ្យមានការកម្ទេច<>ផ្នែករូបរាងកាយទៅលើ<សហគមន៍>ជនជាតិប៊ូស្នី មូស្លីមទាំងអស់នោះ។ ដូច្នេះវាអាចថា វាមានលទ្ធភាពមួយ ដែលថាសហគមន៍មូស្លីមនៅក្នុងតំបន់នុំង មិនអាចបង្កើតឡើងវិញនៅពេលក្រោយបាន។

នៅក្នុង<ការជំនុំជម្រះនេះ>ផងដែរ យើងមានលេខាតំបន់<ស្វយ័ត>១០៥ គឺសៅ សារុន បានមកផ្ដល់សក្ខីកម្ម ហើយគេសួរគាត់ថា គឺនៅថ្ងៃ០៦ មិថុនា ២០១២ គេសួរថា៖ "តើគេមាននិយាយអំពីការបណ្ដេញយួនចេញពីកម្ពុជាទេ? គាត់ឆ្លើយថា៖ គេមាននិយាយ ហើយអ្នកនិយាយហ្នឹង គឺប៉ុលពត។" ប្រសិនបើយើងមើលទៅទស្សនាវដ្ដីទង់បដិវត្ត ខែមេសា ៧៦ បានរៀបរាប់អំពីការនិរទេស។ គឺឯកសារ E3/759 គេបាននិយាយថា៖ "មានជនបរទេសជាច្រើន រាប់សែននាក់ ហើយមានប្រភេទជនបរទេស<មួយប្រភេទ>ដែលពិសពុលខ្លាំងបំផុត ហើយជាគ្រោះបំផុតចំពោះប្រជាជនយើង។ ពួកវាមកប្រមាញ់យើង ហើយមកអង្គាមយើង មកលេបយើង មកកម្ទេច មកលួចអ្វីៗទាំងអស់ មកបង្កគ្រោះថ្នាក់ដល់ប្រទេសជាតិ និងប្រជាជនយើង។" គឺទស្សនាវដ្ដីនេះ បានសរសេរតទៅ<កាន់កម្មាភិបាលខ្លួន>ថា៖ "ក្នុងរយៈពេល២០ឆ្នាំ ពួកបរទេសទាំងអស់នេះ នឹងកើនទៅដល់១០លាននាក់ ប៉ុន្តែបដិវត្តរបស់យើង ជាពិសេសគឺនៅថ្ងៃ១៧ មេសា ៧៥ បានដោះស្រាយបញ្ហានេះយ៉ាងស្អាត ហើយដោះស្រាយបានទាំងស្រុង។ បដិវត្តប្រជាធិបតេយ្យបានបោសសម្អាតជនបរទេសទាំងអស់នេះ រាប់សែននាក់ចេញពីប្រទេស ហើយបណ្ដេញចេញពីប្រទេសរបស់យើងថែមទៀតផង។"

ភស្តុតាងបានបង្ហាញថា គោលនយោបាយមួយនេះ គឺគោលនយោបាយក្នុងការដកវៀតណាម

ចេញ គឺបញ្ជូនវៀតណាមទៅប្រទេសវិញ គឺបានផ្លាស់ប្តូរ។ ហើយយើងដឹងថា ភស្តុតាងបានបង្ហាញអំពីការសម្លាប់ដែលកើតឡើង។ ហើយយើងក៏ឃើញផងដែរ នៅក្នុងសក្ខីកម្មរបស់កម្មាភិបាលឃោធាជាន់ខ្ពស់ឈ្មោះ មាស វឿន។ ហើយយើងជឿជាក់ថា នេះគឺជាការ<បង្ហាញ>ដ៏សំខាន់សម្រាប់ការជំនុំជម្រះទៅលើគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យចំពោះវៀតណាម ហើយនិងការប្រែប្រួលផ្លាស់ប្តូររបស់គោលនយោបាយនេះ។ ឥឡូវនេះ ខ្ញុំសូមអនុញ្ញាតបញ្ចាំងខ្សែវីដេអូ គឺខ្សែវីដេអូនៃសក្ខីកម្មរបស់ មាស វឿន ថ្ងៃទី០២ ខែកុម្ភៈ ២០១៦។

[១១:១៩:១០]

*(ការបង្ហាញឯកសាសំឡេង-រូបភាព)*

*"រឿងវៀតណាមនៅក្នុងស្រុកខ្មែរ ពីព្រោះអីវៀតណាមដែលនៅក្នុងស្រុកខ្មែរហ្នឹង មិនមែននៅដើម្បីរកស៊ីទេ នៅដើម្បីបង្ករឿងហេតុឲ្យប្រជាជនកម្ពុជាលំបាក។ អ៊ីចឹងបានន័យថា ជាៗការងារដែលត្រូវកម្ទេចហ្នឹង ឲ្យប្រជាជន គេឲ្យទៅតាមសម្រួល។ កាលមុន គេឲ្យទៅតាមសម្រួល ដោយតាំងពីឆ្នាំ ៧០ណោះ។ រឿងវៀតណាម ថ្នាក់ដឹកនាំខ្មែរយើងឲ្យទៅតាំងពីឆ្នាំ១៩៧០ រហូតមក៧៥ ក៏ឲ្យទៅដែរ។ តែគេអត់ព្រមទៅ អាហ្នឹងគេមានទិសដៅ ឬផែនការអ៊ីចឹង តាមអង្គភាពអ៊ីចឹង ជនជាតិវៀតណាមត្រូវកម្ទេចអ៊ីចឹង។ អាហ្នឹង ខ្ញុំឆ្លើយត្រង់អ៊ីចឹង។ បើកាលណា គេឲ្យទៅហើយ យើងមិនព្រមទៅ។"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១១:២០:០៨]

**លោក នីកូឡាស គូមជែន៖**

នៅពេលក្រោយមក គឺគេបញ្ជាឲ្យយើងកម្ទេចវៀតណាមដោយសារពួកគេមិនត្រឡប់ទៅប្រទេស។ នេះគឺ ជាការផ្លាស់ប្តូររបស់គោលនយោបាយ។ ហើយគោលនយោបាយនេះ ត្រូវបានផ្សព្វផ្សាយទៅដល់កម្មាភិបាល <ទៅប្រជាពលរដ្ឋ> ដោយមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ រួមទាំងជនជាប់ចោទពីររូបនេះផងដែរ <តាមមធ្យោបាយនានា ក្នុង>ចេតនាក្នុងការញុះញង់ឲ្យមានការស្អប់ខ្ពើម និង<មានការសម្លាប់មក>លើជនជាតិវៀតណាម។ នៅថ្ងៃទី០៣ ខែកញ្ញា ៧៨ នួន ជា បានកោតសរសើរចំពោះកងទ័ពសម្រាប់កម្ទេច ដែលបានបំផ្លាញយុទ្ធសាស្ត្ររបស់វៀតណាម ក្នុងការ<សម្លាប់>ខ្មែរ គឺឯកសារ E3/199។ នេះគឺជាធាតុផ្សំ<ទូទៅក្នុងការ>ប្រល័យពូជសាសន៍គឺថា មេដឹកនាំដែលញុះញង់ឲ្យមានការស្អប់ខ្ពើម និងការខ្លាច។ គឺថា ពួកគេបានព្យាយាមលាបពណ៌ជនរងគ្រោះ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ថា ជាគ្រោះថ្នាក់ ហើយពួកគេញុះញង់ឲ្យប្រជាជនទូទៅ រៀបចំផែនការប្រល័យពូជសាសន៍។

<១២ថ្ងៃក្រោយមក គឺថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ>៧៨ នួន ជា <បានថ្លែងសុន្ទរកថា ខ្ញុំសូមដកស្រង់ ៖ ">វៀតណាមមិនដែលបោះបង់ចោលមហិច្ឆតាក្នុងការកម្ទេចពូជសាសន៍កម្ពុជានោះឡើយ។" <នៅខែមេសា ឆ្នាំ១៩៧៨ ប៉ុល ពត បានប្រាប់កម្មាភិបាលខ្លួនថា ខ្ញុំសូមដកស្រង់ "បើសិនណាវៀតណាមកាន់កាប់ប្រទេសកម្ពុជា>ពូជសាសន៍កម្ពុជានឹងបាត់ក្នុងរយៈពេល៣០ឆ្នាំ។" <ដូច្នេះ ប្រហែលនៅឆ្នាំ ២០០៨ > ប៉ុល ពត បានប៉ាន់ស្មានបែបនេះ<គឺថា មិនមានជាតិសាសន៍ខ្មែរទៀតទេ>។ ខៀវ សំផន បានហៅវៀតណាមថាជា <ដកស្រង់៖> "ខ្មាំងស៊ីសាច់ហុតឈាមរបស់យើង"។ ហើយនិយាយថា <ប្រជាជន>កម្ពុជាត្រូវតែរួបរួមគ្នាដើម្បីកម្ទេចអំពើឈ្លានពាន <ពង្រីកទឹកដី>ហើយនិង<ប្រឆាំងការ>ប្រល័យពូជសាសន៍<មកលើ>ជនជាតិកម្ពុជាដោយវៀតណាម<>។

[១១:២២:២០]

ហើយពួកគេបានហៅថា វៀតណាមហ្នឹងគឺជាឧក្រិដ្ឋជនអាក្រក់បំផុត កាចសាហាវបំផុត គឺ <ទាំងអស់នេះមាននៅក្នុង>ឯកសារ E3/296។ ខៀវ សំផន បានហៅពួកគេថា ជាបិសាច គឺឯកសារ E3/8304 ថ្ងៃ៣១ ធ្នូ ៧៣។ ហើយគេហៅថា ជាពួកព្រៃ និងកាចសាហាវ ហើយនិយាយថាវៀតណាមហ្នឹងដូចជា ហ៊ីត្លែរ <ខ្ញុំសូមដកស្រង់> "គឺគ្មានសីលធម៌អ្វីទាល់តែសោះ"។ ហើយគាត់អះអាងផងដែរថា វៀតណាមហ្នឹងគឺចូលរួមនៅក្នុងការឈ្លានពាន ប្រល័យពូជសាសន៍។ គឺនៅក្នុងឯកសារដដែលគឺ ខែធ្នូ ៧៧ ខៀវ សំផន បាននិយាយថា "ខ្មាំងវៀតណាមបានរំលោភសម្លាប់ស្ត្រីកម្ពុជា ហើយពួកគេចង់ឲ្យប្រជាជនកម្ពុជាទៅជាទាសករ ហើយធ្វើឲ្យពួកយើងទៅជាជនជាតិវៀតណាម។" ទស្សនាវដ្តីទង់បដិវត្តដែលយើងដឹងច្បាស់ថា ជាទស្សនាវដ្តីរបស់កម្ពុជាប្រជាធិបតេយ្យនៅក្នុងខែកក្កដា ៧៨ បាននិយាយថា ភារកិច្ចជាតិរបស់យើងគឺ វាយប្រយុទ្ធ ជាមួយនឹងខ្មាំងយួន ប្រល័យពូជសាសន៍ លេបទឹកដីឈ្លានពាននិយម និងចក្រពត្តិនិយម។ ពាក្យទាំងអស់ និងការញុះញង់ទាំងអស់នេះ គឺជាគោលនយោបាយប្រល័យពូជសាសន៍។

សម្តេចព្រះវររាជបិតា ក៏បានរំឭកដល់ ខៀវ សំផន ផងដែរ នៅក្នុងឯកសារ E3/1819 គឺជាការសន្ទនាជាមួយ ខៀវ សំផន ហើយខៀវ សំផន បានប្រាប់សម្តេចថា <ដកស្រង់ "ដើម្បីបង្រួបបង្រួមប្រជាជន >អ្វីដែលយើងអាចធ្វើបានគឺជំរុញឲ្យប្រជាជនស្អប់យួនខ្លាំងឡើង ខ្លាំងឡើងជារៀងរាល់ថ្ងៃ។" ដូច្នេះនេះគឺជា មិនមែនត្រឹមតែចេតនានោះទេ ប៉ុន្តែជាកត្តាជំរុញ<អំពើប្រល័យពូជសាសន៍ផងដែរ

ស្រដៀងគ្នានឹងអំពើប្រល័យពូជសាសន៍នានា>ផងដែរ។ <>មេដឹកនាំកម្ពុជាប្រជាធិបតេយ្យចង់<បិទបាំងបរាជ័យរបបរបស់ខ្លួន ជារបបដែលនាំតែទុក្ខវេទនា និងភាពឈឺចាប់ដល់ប្រជាពលរដ្ឋខ្លួនឯង ពួកគេបានស្វែងរក>ខ្មាំងបរទេស ហើយបន្ទោសទៅលើខ្មាំងបរទេស <ដើម្បី>ព្យាយាម<បង្រួបបង្រួម> ប្រជាជន< ហើយប្រាប់ថា> ការឈឺចាប់<ទាំងអស់នេះ គឺ>បណ្ដាលមកពីខ្មាំងទាំងអស់នោះ។ នៅក្នុងខែមករា ៧៨ មន្ទីរ៨៧០ បានចេញការណែនាំមួយដោយសង្កត់ធ្ងន់ថា <ខ្ញុំសូមដកស្រង់៖“>ជារឿងមិនអាចជៀសវាងបានដែលត្រូវបង្កកំហឹងវណ្ណៈ និងកំហឹងជាតិសាសន៍ប្រឆាំងខ្មាំងឈ្លានពានយួន។” នេះគឺធ្វើឡើងដោយមន្ទីរ<៨៧០>ដែល ខៀវ សំផន ជាសមាជិកគណៈតែមួយគត់នៅពេលដែល ខៀវ <ជាសហសមាជិករបស់គាត់> ត្រូវបានគេចាប់ខ្លួន។ នេះគឺជាការផ្សព្វផ្សាយដែលបញ្ជូនពីថ្នាក់លើទៅដល់កម្មាភិបាល<ថ្នាក់ក្រោម> និងទៅដល់ប្រជាជនសាមញ្ញ សូម្បីតែកម្មាភិបាលធម្មតាឈ្មោះ ប៉ាក់ សុខ ដែលជាសមាជិកកងពលធំនាវាចរនៅកំពង់សោម <បានផ្ដល់សក្ខីកម្មនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ អំពីការហ្វឹកហ្វឺនដែលគាត់បានទទួល ថាត្រូវប្រព្រឹត្តនឹងជនជាតិ>វៀតណាមយ៉ាង<ណា>។ ឥឡូវនេះ ខ្ញុំអនុញ្ញាតចាក់ខ្សែវីដេអូទី២ដែលជាសក្ខីកម្មរបស់ ប៉ាក់ សុខ។

[១១:២៦:០១]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*“បាទ ជាការពិតណាស់ សត្រូវស្ទួពូជនេះគឺថាសម្លាប់អត់មានទុក សូម្បីតែកូនង៉ែតមួយ ក៏អត់ឲ្យមានដែរ ព្រោះនេះជាសត្រូវស្ទួពូជអ៊ីចឹង គឺសម្លាប់ចោលតែម្តង ព្រោះទំនាស់បដិបក្ខបាទ។ នេះជាអង្គសិក្ខាសាលានៅក្នុងមន្ទីរនៃវរសេនាតូចនីមួយៗ ទទួលផែនការច្បាស់លាស់តែម្ដង។ បាទអរគុណ។”*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១១:២៦:៣២]

ខ្ញុំឃើញថាខ្សែវីដេអូហ្នឹងមិនបានសួរដាក់សំណួរ ប៉ុន្តែសួរថាតើគ្រូណែនាំហ្នឹងនិយាយយ៉ាងម៉េចដែរអំពីខ្មាំងយួនហ្នឹង? <គាត់ឆ្លើយថា៖>គេថាយើងត្រូវបានគេបញ្ជាឲ្យសម្លាប់សូម្បីតែកូនង៉ែត ព្រោះវាជាខ្មាំងស្ទួពូជ។ ដូច្នេះចេតនា គឺកម្ទេចជនជាតិវៀតណាមទាំងអស់<ឬ?> ឥឡូវនេះ ខ្ញុំសូមបង្ហាញនូវសុន្ទរកថារបស់ ប៉ុល ពត គឺ E3/4604 ខ្ញុំសូមអនុញ្ញាតបង្ហាញ*ស្លាយ*ទី២នេះ គឺជាទស្សនាវដ្តីទង់បដិវត្តដែលជាទស្សនាវដ្តីបង្ហាញអំពីសុន្ទរកថារបស់ ប៉ុល ពត។ <សូមដាក់បញ្ចាំងនៅលើស្រ្គីន។> គាត់បាននិយាយថា៖ “មកដល់បច្ចុប្បន្ននេះ យើងបានអនុវត្តយុទ្ធសាស្រ្ត មួយទល់៣០។ បានន័យថា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

យើងបាត់បង់ខ្មែរម្នាក់ យួនត្រូវបាត់បង់៣០នាក់។” <គាត់និយាយបន្តទៀតថា៖ “>អ៊ីចឹងបានន័យថា ប្រសិនបើយើងមាន២លាននាក់ ពួកវាត្រូវការ៦០លាននាក់ ដូច្នេះបើសិននៅពេលដែលយើងមាន២លាននាក់រួចហើយហ្នឹង យើងអាចសល់មនុស្ស ព្រោះឥឡូវហ្នឹងយួនមានតែ៥០លានប៉ុណ្ណោះ យើងមិនចាំបាច់ត្រូវប្រើប្រាស់ដល់ទៅ៨លាននោះទេ យើងប្រើប្រាស់កម្លាំងតែ២លាននាក់ យើងអាចវាយកម្ទេចយួនបាន ហើយយើងនឹងសល់ប្រជាជន៦លាននាក់ទៀត។” នេះគឺជាសុន្ទរកថាដ៏អស្ចារ្យមួយ។ ប៉ុល ពត <ប៉ាន់ប្រមាណ>ថា កម្ពុជាមានប្រជាជន៨លាន ហើយគាត់សុខចិត្តលះបង់២លាន បានន័យថា ២លាននាក់សុខចិត្តស្លាប់ចុះដើម្បីកម្ទេចជនជាតិវៀតណាមទាំងអស់ ដែលមានប្រហែលជា៥០លាន។ អ៊ីចឹងបានន័យថា យើងអាចសម្លាប់ជនជាតិវៀតណាមបានទាំងអស់ <ដោយប្រើចំនួនតែ២លាននាក់ប៉ុណ្ណោះ>។ <វាមិនមែនកើតឡើងញឹកញាប់ទេ ក្នុងការជំនុំជម្រះអំពើប្រល័យពូជសាសន៍ដោយមានសុន្ទរកថាដ៏ច្បាស់ក្រឡែតបែប>នេះ<ដោយបញ្ជាក់អំពី>ចេតនាប្រល័យពូជសាសន៍។

លោកប្រធាន ខ្ញុំត្រូវបន្តទៅប្រធានបទថ្មី ថាតើខ្ញុំគួរតែផ្អាកនៅពេលនេះ ឬក៏បន្តទៅទៀត?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាដែលបានកំណត់នេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:២៩ នាទី ដល់ម៉ោង ១៣:៣០ នាទី)*

[១៣:៣០:២០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាអន្តរជាតិដើម្បីបន្តធ្វើការ ធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួន។

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន។ នៅពេលដែលយើង មុនឈប់សម្រាកនេះ ខ្ញុំបាននិយាយអំពីសុន្ទរកថារបស់ ប៉ុល ពត អំពីការនិយាយ ការសម្លាប់ប្រជាជនវៀតណាម៥០លាននាក់ ហើយថាតើការនិយាយនេះ គេត្រូវបានផ្សព្វផ្សាយនៅលើវិទ្យុដោយរបៀបណា។ បញ្ហាមួយដែលជាក់ស្តែងនោះ គឺដែលចេញពីគោលនយោបាយ និងការញុះញង់នេះ គឺថាយើងឃើញស្តែងចេញពីសកម្មភាពរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យផ្ទាល់ នៅពេលដែលពួកគេចូល<>ឆ្លងកាត់ព្រំដែនចូលទៅ<វាយប្រហារ> ប្រទេសវៀតណាម។ <>ការវាយប្រហារនៅខាងក្រៅបូរណភាពដែនដីនៃប្រទេសកម្ពុជា <មិនមែនជាផ្នែកនៃការចោទប្រកាន់នៅក្នុងសំណុំរឿងនៃទំហំ>សវនាការនេះទេ។ ប៉ុន្តែអ្វីដែលវាពាក់ព័ន្ធ<នោះ វាបង្ហាញយ៉ាងច្បាស់ពី>ចេតនា <និងការញុះញង់ ប្រឆាំងនឹងជនជាតិវៀតណាម។ >

[១៣:៣១:៥៦]

<ដូច្នេះ បើសិន>ខ្ញុំ<យល់ពី>ជំហររបស់មេធាវីការពារក្តី<គឺ>ថា <ការ>វាយប្រហារនេះគឺមិនបានកើតឡើងទេ។ ប៉ុន្តែបញ្ហានេះ <ត្រូវបានបង្ហាញនៅក្នុងសវនាការ ដោយមាន>សក្ខីកម្មរបស់អ្នកជំនាញគឺ ស្ទីវហ្វិន ម័ររីស <ដែលខាងមេធាវីការពារក្តីបានស្នើសុំផងដែរ។> សាស្ត្រាចារ្យ ម័ររីស បានផ្តល់សក្ខីកម្មថា នៅថ្ងៃទី៣០ ខែមេសា គឺនៅក្នុងសៀវភៅរបស់គាត់ទំព័រ៨៩៖ “នៅថ្ងៃ៣០ មេសា ១៩៧៧ អង្គភាពខ្មែរក្រហមបានវាយប្រហារទៅលើភូមិមួយចំនួន និងក្រុងមួយចំនួននៅក្នុង<>ខេត្តអាងយ៉ាង <និងខេត្ត>ចូវដុក <ក្នុងទឹកដីវៀតណាមខាងត្បូង> ដោយដុតផ្ទះរាប់រយខ្នង និងសម្លាប់ប្រជាជនស៊ីវិលរាប់រយនាក់។” អ្នកជំនាញ ណាយ៉ាន់ ចាន់ដា ក៏បានផ្តល់សក្ខីកម្មនៅក្នុងសវនាការនេះផងដែរ ហើយសក្ខីកម្មរបស់គាត់ ក៏ដូចសៀវភៅរបស់គាត់ និយាយថា “សត្រូវជាបងប្អូនឯង” គឺទំព័រ៩៩ ដល់ ទំព័រ១០០ គាត់និយាយអំពីអ្នកកាសែតជនជាតិហុងគ្រី ឈ្មោះ កុនដូ ឌូវ៉ា ដែលគេបានបញ្ជូនគាត់ទៅព្រំដែនវៀតណាមនៅខេត្តតៃនិញ។ <លោក ចាន់ដា បានបង្ហាញថា> ឌូវ៉ា <>បានឃើញ <មានការបំផ្លិចបំផ្លាញអគារ >ប្រជាជន<>ជាច្រើន<ត្រូវបានដុតសម្លាប់ ភាគច្រើនគឺ>ស្ត្រី និងកុមារ។ គាត់<រាយការណ៍>ថា <មាន>ភូមិមួយចំនួន<ត្រូវបានកម្ទេច ហើយប្រជាជនស៊ីវិលបានស្លាប់> ឡើងរហូតដល់រាប់រយនាក់ឯណោះ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៣:៣៣:២៧]

នៅពេលដែល ណាយ៉ាន់ ចាន់ដា បានមកផ្តល់សក្ខីកម្មនៅឆ្នាំ២០០៩ គាត់និយាយអំពីដំណើរទស្សនកិច្ចរបស់គាត់ទៅតំបន់ដែលវាយប្រហារដោយកងទ័ពខ្មែរក្រហមនៅ<ជិត>ព្រំដែន។ គាត់បាននិយាយ<នៅ> ទី២៥ ឧសភា ២០០៩ <ដូចតទៅ៖ ">ភូមិ<ដែលខ្ញុំបានទៅដល់ មើលទៅហាក់ដូចជា> បំផ្លិចបំផ្លាញឡើងដោយព្យុះអឺចឹង។ <ផ្ទះសម្បែងត្រូវបានកម្ទេច ហើយកម្ទេចកម្ទីនៅរាយប៉ាយនៅលើដីនៅឡើយ។> ខ្ញុំបានជួបអ្នករស់រានមានជីវិតដែលប្រាប់ខ្ញុំអំពីអ្វីដែលបានកើតឡើង។ ខ្ញុំអាចនិយាយបានថា នេះ <ខ្ញុំរន្ធត់ចិត្តណាស់ដោយឃើញសភាពព្រៃផ្សៃបែបនេះ ដែលគេ>បានប្រព្រឹត្តក្នុងពេលវាយប្រហារ<>។ ខ្ញុំមិនដែលឮអំពីភាពសាហាវព្រៃផ្សៃ<បែបនេះទេ ដែលប្រព្រឹត្ត>ទៅលើកុមារ ស្ត្រី និងប្រជាជនគ្មានទោសពៃរ៍<>។" គាត់បានបន្តនិយាយថា "នេះគឺជាដំណើរទស្សនកិច្ចមួយដែលធ្វើឲ្យខ្ញុំមានការចងចាំទាំងស្រុង ហើយខ្ញុំនៅតែផ្ទាល់ខ្លួនហ្នឹង នៅតែមានសុបិនអាក្រក់តាមរយៈដំណើរទស្សនកិច្ចរបស់ខ្ញុំនេះ។ ដោយសារខ្ញុំឃើញជនស៊ីវិលជាច្រើនហ្នឹង សម្លាប់យ៉ាងព្រៃផ្សៃ ហើយទុកចោលនៅទីនោះ។ ហើយការវាយប្រហារ<ដ៏មិនប្រណី>នេះ ជា<រឿងមួយគួរឲ្យតក់ស្លុតបំផុត ធ្វើឲ្យខ្ញុំឆ្ងល់ថា>ថាតើ<គេប្រព្រឹត្តការកាប់សម្លាប់របៀបនឹងដើម្បីគុណសម្បត្តិអ្វី>។" ហើយភស្តុតាងនេះក៏ត្រូវបាន ខៀវ សំផន លើកយកមកសរសេរនៅក្នុងសៀវភៅរបស់គាត់អំពីប្រវត្តិសាស្ត្រកម្ពុជានាពេលថ្មីៗ នេះគឺឯកសារ E3/18។ គាត់<សរសេរថា ">ប្រព្រឹត្តិការណ៍កើតឡើងដែល<រៀបរាប់ដោយលោក ចាន់ដា គឺ>មិនអាចប្រកែកបាន ហើយគ្មានអ្វីគួរឲ្យសង្ស័យនោះទេ គឺថាខ្មែរក្រហមបានចូលទៅក្នុងភូមិវៀតណាមនៅតាមព្រំដែន ប្រព្រឹត្តនូវអំពើសាហាវព្រៃផ្សៃប្រឆាំងទៅលើជនស៊ីវិលវៀត-ណាម។"

[១៣:៣៥:២៧]

លោក លោកស្រីចៅក្រម ពិតហើយ ខៀវ សំផន និង នួន ជា ដឹងអំពីមូលហេតុនេះ ពីព្រោះពួកគាត់គឺជាមនុស្សដែលនៅចំណុចកណ្តាល ឬក៏ដូចជាថាជាអ្នកគ្រប់គ្រងទៅលើមជ្ឈិមបក្សដែរ<ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ>។ <នៅមានរបាយការណ៍សេសសល់អំពីសមរភូមិនេះចេញពីកងកម្លាំងរបស់កងទ័ពកម្ពុជាប្រជាធិបតេយ្យផ្ញើជូនមជ្ឈិម។ ក្នុងឯកសារទាំងហ្នឹងគឺជា>សារទូរលេខ<ក្នុង>ឯកសារ <E3/243> ដែលផ្ញើជូនមជ្ឈិម ចុះថ្ងៃទី១៩ មករា ១៩៧៨។ គឺជាសារទូរលេខមកពី សោ ភឹម ហៅ <ឆុន ផ្ញើជូនបង ប៉ុល ហើយថតចម្លងជូន ពូ នួន ជា បង វ៉ាន់ បង វន និងមន្ទីរ។ មិនបាច់ឆ្ងល់ទេ មន្ទីរ

នោះសំដៅទៅមន្ទីរ៨៧០ នេះឯង ដែលលោក ខៀវ សំផន នៅពេលនោះជាសមាជិកតែម្នាក់ប៉ុណ្ណោះ។ នៅក្នុងកថាខណ្ឌទី១ ក្នុងរបាយការណ៍ សោ ភឹម រាយការណ៍ថា “យើងបាន>--

*(គ្មានការបកប្រែ)*

[១៣:៣៦:០០]

**ប្រធានអង្គជំនុំ៖**

ផ្អាក! ផ្អាកបន្តិចសិន! មានបញ្ហាការបកប្រែភាសាខ្មែរ។

*(មានបញ្ហាបច្ចេកទេស)*

បាទ សូមអញ្ជើញ! អញ្ជើញបន្ត ហើយចុងក្រោយអំមិញ និយាយសាឡើងវិញ លោកសហព្រះរាជអាជ្ញា។

**លោក នីកូឡាស គូមជែន៖**

បាទ សូមអរគុណលោកប្រធាន។ នៅក្នុងសារទូរលេខ E3/243 ដែលបញ្ជូនមកពី សោ ភឹម បានផ្ញើបញ្ជូនមក ប៉ុល ពត, នួន ជា ក៏ដូចជាមន្ទីរ៨៧០៖ “<>យើងបាន<វាយល្អប ក្នុងដីវាឃ្លាតពីព្រំដែនយើង>២គីឡូម៉ែត្រ<>។ ជាលទ្ធផល គឺថាយើងបាន<កម្ទេចផ្ទះឃោធាខ្មាំង ចំនួន>៣០<ខ្នង> ហើយនិងដុតផ្ទះជនស៊ីវិល<មួយចំនួនទៀត។>យើងកម្ទេចកាណូតរបស់ខ្មាំង<បាន>ពីរគ្រឿង ហើយក្នុងកាណូតនោះ គឺសុទ្ធតែប្រជាជនវានៅ ធ្វើឲ្យប្រជាជនវានៅក្នុងកាណូតខ្ទេចខ្ទីអស់។” ហើយគាត់ក៏បានរបាយការណ៍ផងដែរថា “នៅម៉ោងបីព្រឹកហ្នឹង ក៏បាញ់គ្រាប់រ៉ុកក្កែត១០៧ ចូលទៅផ្សារហុក<ដីយើងក្តាប់មិនបានទេ តែឃើញឆេះ”> ។ សារទូរលេខមួយទៀត គឺE3/1076 ចុះថ្ងៃទី០៨ មេសា ៧៨ ដែល សុន សេន ជាអ្នកផ្ញើមក គឺគាត់ហៅថា បង៤៧។ នៅក្នុងសារទូរលេខនេះ គាត់រាយការណ៍ថា៖ “យើង<បានវាយ>ចូលទៅតំបន់ទីប្រជុំជនដុងថាប់ នៅនឹងផ្សារនៅភាគត្បូងនៃត្រពាំងព្រាម និងតាន់ចាវ។ យើងសម្លាប់ និងធ្វើឲ្យរបួសពួកវារាប់រយនាក់ ដុតផ្ទះសម្បែងរាប់រយខ្នង។ ហើយយើងបន្តបាញ់គ្រាប់១៧០ និងគ្រាប់ដេកា៧៥ ចូលទៅតាំងចូវ”។

[១៣:៣៩:១១]

សម្តេចព្រះបរមកោដ្ឋ នរោត្តម សីហនុ ហ្នឹងបានរំឭកឡើងវិញ អំពីប៉ុល ពត បានប្រាប់មកព្រះ<អង្គ> សូមដកស្រង់៖ “ចំពោះកម្ពុជាក្រោម គឺជាមួយបេសកកម្ម យើងបានសម្លាប់មនុស្សទាំងប្រុសទាំងស្រី ក្មេង តាមដែលអាចធ្វើបាន ចំពោះជនជាតិដែលប្រៀបបានដូចព្រាយបិសាចនេះ។” ដូច្នេះ អ្វី

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដែលយើងបានឃើញនៅមុំឆ្នាំ៧៧ ហាក់បីដូចជាមានសេចក្តីសម្រេចមួយ ថាមិនមានចេតនាបញ្ជូនជនវៀតណាមដែលនៅសេសសល់នោះទេ គឺថាសម្លាប់ចោលតែម្តង។ ព្រំ សារុន ដែលមកពីស្រុកបាណន់ ភូមិភាគពាយ័ព្យ <បានផ្តល់សក្ខីកម្មនៅទីនេះកាលថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៥។> គាត់<ប្រាប់ថា មេបញ្ជាការវរសេនាតូច បានបញ្ជាគាត់>រាយការណ៍អំពីថាតើពួកវៀតណាមមួយចំនួនត្រូវបានបញ្ជូនទៅស្រុក ហើយបានសម្លាប់ចោល។ ហេង ឡៃហ៊ាង គាត់មកពី<ខេត្ត>ក្រចេះ តំបន់៥០៥ បានផ្តល់សក្ខីកម្មនៅថ្ងៃទី១៩ កញ្ញា ២០១៦។ ឪពុកមារបស់គាត់<ជាជនជាតិខ្មែរ តែ>ប្រពន្ធរបស់ឪពុកមារបស់គាត់ជាជនជាតិវៀតណាម និងកូនៗ<មិន>ចេះនិយាយ<វៀតណាមទេ ពួកគេចេះតែភាសាខ្មែរប៉ុណ្ណោះ> ប៉ុន្តែទាំងអស់ត្រូវបានគេប្រមូលយកទៅបាត់ សូមដកស្រង់៖ "នេះដោយសារតែ<គេដាក់>គោលនយោបាយ <ដែលថា>អ្នកដែលពាក់ព័ន្ធទៅនឹងខ្សែវៀតណាម បណ្តាញវៀតណាម និងទំនាក់ទំនងជាមួយវៀតណាម គឺមិនទុកឲ្យរស់រានមានជីវិតទេ។"

លោក លោកស្រីចៅក្រម ខ្ញុំក៏បានរៀបចំនូវវីដេអូឃ្លីបមួយខ្លី ដែលជាសក្ខីកម្មដែលយើងស្តាប់មកពី<សាក្សី និង>ដើមបណ្តឹងរដ្ឋប្បវេណីមួយរូបគឺ ប្រាក់ ខឿន <នៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៥ ហើយ និង>ជឿង យ៉ាំងចែត នៅ<ថ្ងៃទី៧> ខែធ្នូ ឆ្នាំ២០១២, អ៊ុច ស៊ុនឡាយ នៅថ្ងៃទី០២ មីនា ២០១៦ ហើយនៅថ្ងៃទី០១ មីនា ហេង ឡៃហ៊ាង នេះតែម្តងនៅថ្ងៃទី១៩ កញ្ញា ២០១៥, ស៊ុន <ជិម> នៅថ្ងៃទី១៤ កញ្ញា ២០១៥ ហើយចុងក្រោយនេះគឺ ប្រាក់ សុខ នៅថ្ងៃទី១៦ ខែធ្នូ <២០១៥>។ ដូច្នេះសុំការអនុញ្ញាតដើម្បីថាតើចាក់បញ្ចាំងវីដេអូឃ្លីប ដើម្បីបង្ហាញថាតើគេប្រព្រឹត្តយ៉ាងដូចម្តេច?

[១៣:៤១:៤៨]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"តាហ៊ីម ប្រធានកងខ្ញុំបាទ គឺថាបានបញ្ជាក់ គឺថាព្រឹកឡើង បានប្រាប់ខ្ញុំថា ពូ តាំងស្មារតីទៅព្រោះប្រពន្ធកូន អត់មានកើតមកវិញទៀតទេ។ អង្គការបានកម្ទេចហើយ ហើយក៏បានបន្ទោសពាក្យខ្ញុំមួយម៉ាត់ថា ចុះពូឯងពីដើមឡើយក៏មិនយកប្រពន្ធខ្មែរ ម៉េចបានពូឯងទៅយកប្រពន្ធវៀតណាម។ គេយកទៅដល់ ជិតគោលដៅរណ្តៅគេសម្លាប់ចោលហ្នឹង គេចងនៅព្រៃប្រហែល១០០ ចងម្តុំហ្នឹងតែម្តង។ យកពុកខ្ញុំចេញមក រណ្តៅហ្នឹងវ៉ៃ ខ្ញុំអត់ឃើញវ៉ៃគេងាប់ទេ ប៉ុន្តែដល់ខ្ញុំទៅដល់រណ្តៅ ឃើញម៉ែឪខ្ញុំនៅរណ្តៅទាំងអស់ ទាំងបង បងប្រុស បងស្រីខ្ញុំនៅរណ្តៅទាំងអស់។ ខ្ញុំបាទហ្នឹងដឹងច្បាស់ហើយថា ប្រពន្ធនិងកូនជាវៀតណាម។ ដូច្នេះ កូនហ្នឹងគឺជាចៅកាត់វៀតណាម ពីព្រោះទ្រឹស្តីរបស់មេដឹកនាំជាន់ខ្ពស់ និង*

អ្នកទទួលខុសត្រូវខ្ពស់បំផុតនៃរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង បានផ្សព្វផ្សាយទៅដល់ថ្នាក់ក្រោមទាំងអស់ ថាជីកស្មៅ ត្រូវជីកទាំងឫស។ បានន័យថា បើយកប្រពន្ធនិងកូន ដែលជាចៅកាត់វៀតណាម អាចៅខ្វួត ចៅល្អិត ចៅអីក៏ដោយ ក៏ជាវៀតណាម ជាខ្មែរ កា.ហ្វេ.បេ ទាំងអស់ដែរ។ បាទ នេះគឺដឹងច្បាស់ យល់ច្បាស់ ដោយមើលឃើញ និងការតាមដាននៅពេលដែលគេសម្លាប់កូនក្មេងនោះ។ កូនខ្ញុំបាទហ្នឹងមានបីនាក់ គឺប្រុសពីរនាក់ ស្រីមួយនាក។ កូនច្បង ឈ្មោះ សុផារ៉ា អាយុ៨ឆ្នាំ កើតឆ្នាំ៧០ មកទល់នឹង៧៨។ កូនបន្ទាប់ឈ្មោះ សុធីរៈ កើតឆ្នាំ១៩៧៥។ រីឯកូនប្អូន ឈ្មោះ សុធីតា ប្រហែលជា ជាង១ខួបប៉ុណ្ណោះទេបាទ ជាស្រី។ មិនតែប៉ុណ្ណោះ ក្អកក្អួលជាងហ្នឹងថែមទៀត នោះគឺពួកវាយកសម្លាប់បំពាក់ដែលអ្នកស្លាប់ទាំងអស់ហ្នឹង មកចែកនៅក្នុងសហករណ៍ទៀត ប្រាប់ថាគឺជាជយភណ្ឌ។ ហើយ មីងឡាំមីងដទៃទៀតថា ទេឃើញសំពត់អាវស្បៃ ខោខ្លី ក្រមា អាវយឺតហ្នឹងគឺរបស់ប្រពន្ធកូន អ៊ុច ស៊ុនឡាយហ្នឹង របស់ សា គឹមនី។ អានេះកូន សា គឹមនី អានេះគឺគេធ្លាប់ឃើញ គេដឹងច្បាស់ថា ពិតជាស្លាប់នៅក្បាលកោះទ្រង់ហ្នឹងប្រាកដមែន។ ហើយយកថាជារបស់ជយភណ្ឌ។ គួរឲ្យសង្វេគខ្លាំងណាស់។ ខ្ញុំបាទហ្នឹងកាន់តែ ហៅថា បាយក៏មិនបាន ទឹកក៏មិនបាន ដើរល្ហោកមុខគ្រប់ទីកន្លែង ហើយគេចខ្លួនមិនចង់ឲ្យជួបនឹងអ្នកណាទេ ព្រោះបក្សនៅហាមថា ទោះបីលះបង់យ៉ាងម៉េច គឺមិនឲ្យយំ មិនឲ្យខឹងមុខ មិនឲ្យហៅថា ឲ្យគេដឹងថាយើងមិនលះបង់ អ៊ីចឹងទេ។ បក្សវណ្ណៈអធន បក្សកុម្មុយនីស្តកម្ពុជា គឺខ្លាំងក្លាណាស់ គេថា មានជោគជ័យធំសម្បើមណាស់។

[១៣:៣៣:៤២]

លុក វៀតណាមចូលមកលុកលុយហ្នឹង ក៏មានវិធានការទប់ទល់ជាមួយវៀតណាម។ ដូច្នេះវិធានការអ្នកខាងក្រោយដែលគេអប់រំហ្នឹង គេថា អ្នកដែលកាត់យួន អ្នកដែលមានសញ្ជាតិជាអ្នកកាត់យួន គឺត្រូវតែកម្ទេចចោល បើមិនអ៊ីចឹងទេ នែ៎! យួនចូលមកហ្នឹងច្បាស់ជាអ្នកទាំងអស់ហ្នឹងទៅរួមកម្លាំងឲ្យវាកាន់តែច្រើនទៀត អ៊ីចឹងអ្ន។ នេះជាគោលការណ៍របស់គេ គេលើកអ៊ីចឹង។ មាន ចោលប្រពន្ធ១យួន យកទៅវៃចោល យកទាំងកូនទាំងប្រពន្ធយកទៅវៃចោល។ ប្ដីនៅខិបនឹងទ្រូង បេះអ្លែងយកទៅបាត់។ បានថាខ្ញុំវាដូចជាហួសពេក បើទុកកូនឲ្យនៅអត់អីទេ ដល់យកទាំងអស់។ ប្រសិនណាជាប្ដីប្រពន្ធណារៀបការប្ដីវៀតណាម ឬប្រពន្ធវៀតណាម បើប្រពន្ធជាវៀតណាម ហើយប្រពន្ធហ្នឹងត្រូវគេយកចេញទៅបាត់ ថាតើមានអ្វីកើតឡើងទៅដល់កូន១? កូន១យកទៅអស់រលីង គេមិនទុកផងគេថានាំជាប់សាសន៍។ តើប្រជាជនវៀតណាមប៉ុន្មាននាក់នៅក្នុងឃុំរបស់លោកស្រី ដែលត្រូវគេយកទៅ

*សម្លាប់ចោល? គេយកទៅបាត់នុំងប្អូនគ្រួសារ។ បាទ បើតាមចម្លើយសួរទៅជនជាតិវៀតណាមនៅលើទូកនោះ បាទអ្នកពិការដៃនោះគឺជាទាហាន ក្រៅពីនោះជាប្រជាជន។ តែសួរវាថាទៅណា? វាថាទៅ រត់ទៅប្រទេសថៃតែម្តង។ ក្រោយមកបានយើងឃើញយើងចាប់នៅចន្លោះកោះពូលូវៃ និងកោះតាង បាទចាប់យកមកផែអូរឈើទាលហ្នឹង បានជួបនឹងផ្ទាល់។ តើពួកគេមានអាវុធ ឬក៏មានបំណងចង់តដៃអីដែរឬទេ? បាទ គ្មានទេ, គ្មានអាវុធទេ។ តើលោកដឹងថានៅក្នុងចំណោមអ្នកទាំងនោះហ្នឹងមានក្មេងៗដែរឬទេ? បាទ ខ្ញុំចាំ។ ក្នុងនុំងពេលយកទៅដល់ផែអូរឈើទាលនោះ ឃើញថាក្មេងនោះមានការយំស្រែកយ៉ាងខ្លាំង ដោយម្តាយវាចាប់ចង ក្រោយមកវាក្មេងនោះក៏ហេវអឹម។ ក្រោយមកក៏ឃើញយោធាចាប់កូនក្មេងនោះ បោះទម្លាក់ទឹកចោលតែម្តង។”*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៣:៤៨:២៧]

លោក លោកស្រីចៅក្រម មាស វឿន នេះដែលជាអនុបញ្ជាការកងពលបានផ្តល់សក្ខីកម្មថា គាត់បានបញ្ជូនជនជាតិវៀតណាមដែលគាត់ចាប់មកហ្នឹងទៅកងពលជើងទឹក១៦៤។ ហើយ ប្រាក់ សុខ <គឺជាកម្មាភិបាលថ្នាក់ក្រោមម្នាក់ >មកពីកងពល<១៦៤។> គាត់និយាយអំពីការសម្លាប់ប្រជាជន១១នាក់ផ្សេងទៀត ជាមួយនឹងទារកផងដែរ។ <គាត់ក៏និយាយអំពីគ្រួសារមួយ>ដែលចាប់បាននៅតាមផ្ទៃសមុទ្រនោះ <មានឪពុក ម្តាយ និងកូនតូចមួយ>។ ហើយអ្នកទាំងអស់ហ្នឹងគឺថា ត្រូវបានសម្លាប់ចោល ហើយយកទម្លាក់ចូលទៅក្នុងរណ្តៅតែម្តង។

<ជាថ្មីម្តងទៀត> យើងក៏មានឯកសារផ្សេងទៀតដែរ សូមបញ្ចាំងនូវ*ស្លាយ*លេខ៣ ដែល*ស្លាយ*លេខ៣នេះ គឺបង្ហាញអំពីការសម្លាប់នេះថា បានរាយការណ៍ជូនមកមជ្ឈិម។ <ខ្ញុំគិតថា យើងឃើញផ្នែកខ្លះនៃ>សារទូរលេខ<នៅថ្ងៃនេះរួចមកហើយ ប៉ុន្តែនៅផ្នែកខាងដើម សារទូរលេខនៅចុះ>ថ្ងៃទី០៤ សីហា ៧៨ <ក្នុងឯកសារ E3/1094 ចេញ>ពីភូមិភាគបស្ចិម គឺថាបានអនុវត្តនូវគោលនយោបាយរបស់បក្ស <ត្រូវ>បោសសម្អាត ចម្រាញ់ និងបោសសម្អាតទាំងស្រុង ពួកអាខ្មាំងទាំងអស់នោះ ជាពិសេសគឺបានបោសសម្អាតពួកយួននេះតែម្តង។ ហើយជាលទ្ធផលនៃការចម្រាញ់នេះ គឺយើងបាន <ឃើញ> សូមដកស្រង់៖ “កម្ទេចយួន១០០ក្បាល រួមទាំងក្មេងៗពេញវ័យតូចៗ ហើយនិងកុមារតូចៗផងដែរ។” បញ្ចប់ការដកស្រង់។

លោក លោកស្រីចៅក្រម <ទីបញ្ចប់> ការប្រព្រឹត្តមកសហគមន៍វៀតណាមនេះ គឺថាត្រូវបាន

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ប្រព្រឹត្តរហូតមកដល់ដំណាច់នៃរបបនេះតែម្តង គឺនៅដំណាច់ឆ្នាំ<១៩៧៧->១៩៧៨ <ត្រូវបានបង្ហាញនៅក្នុងកំណត់ត្រារបស់មន្ទីរសន្តិសុខផ្ទាល់របស់មជ្ឈិម គឺមន្ទីរ>ស-២១ ដែលស្ថិតនៅក្រោមការបញ្ជារបស់ នួន ជា។ ហើយយើងក៏មាន*ស្លាយ*លេខ៤ផងដែរ ដែលដកស្រង់ចេញពីសារណា<ចុងក្រោយរបស់យើង ក្នុងឧបសម្ព័ន្ធ F-2។ >ដែលបញ្ជាក់ថា មានជនជាតិវៀតណាមត្រូវបានចាប់ខ្លួន<តាមខែ> និងបញ្ជូនមកស-២១<។ ដូចយើងបានឃើញស្រាប់ហើយ នៅដើម>ឆ្នាំ១៩៧៨ <គេបាននាំជនជាតិវៀតណាមចូលយ៉ាងច្រើន។ សូមបន្តទៅស្លាយទី៤។ ក្នុងស្លាយនេះ មានបង្ហាញអាជ្ញាធរនៅស-២១ នោះ បានពិពណ៌នាអ្នកទោសជនជាតិវៀតណាមថាយ៉ាងម៉េច។ នេះជាកំណត់ត្រាចំនួនសរុប ដែលបង្ហាញអត្តសញ្ញាណបុគ្គលចំនួន៧២៨នាក់ ថាជាជនជាតិវៀតណាម ប្រហែល>៣៤,៩ភាគរយ<ត្រូវចាត់ជាចំណាត់ថ្នាក់ជា>ទាហានវៀតណាម <ហើយ៤៩ភាគរយជាចំនួនជនស៊ីវិល ដែលមានចំនួនច្រើនជាងហ្នឹង>។ ប្រាក់ ខន <ដូចយើងនៅចាំហើយ> ជាអ្នកសួរចម្លើយម្នាក់នៅស-២១។ គាត់នៅចងចាំ គាត់បានផ្តល់សក្ខីកម្មកាលពីឆ្នាំទៅនេះ នៅក្នុងព្រឹត្តិការណ៍មួយដែលគេយកជនជាតិវៀតណាមម្នាក់មកហើយគាត់ជាអ្នកសួរចម្លើយ។ បាទ<សូម>ចាក់<>វីដេអូឃ្លីបលេខ៤។

[១៣:៥១:៥៣]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"អ៊ីចឹងផ្ទះ កន្លែងហ្នឹងមានផ្ទះមួយមានពីរជាន់។ ពេលហ្នឹង គេដាក់ការិយាល័យគេនៅកន្លែងហ្នឹងមួយសម្រាប់ទទួលអ្នកទោស។ ពេលមកដល់ហ្នឹង ខ្ញុំក៏នៅខាងក្រោមនៅយាមការពារហ្នឹង ដល់ពេលយកអ្នកទោសមក គឺអ្នកទោសវៀតណាម មកទាំងប្តីទាំងប្រពន្ធ ទាំងកូនស្រីមួយអាយុប្រហែលជាជាងមួយខួប ចេះដើរតិចតួច។ ដល់ពេលយកទៅ អាកូនហ្នឹងវាទៅតាមម៉ែ តាមឪវាហ្នឹង ហើយដល់អ៊ីចឹងឈ្មោះ ដែក ប៊ូ ហើយនិងដួច ទុយ ក៏បានទាញកូនហ្នឹងចេញពីម្តាយឪពុកហ្នឹង នាំម្តាយឪពុកហ្នឹងចូលទៅក្នុងប៉ុស្ត៍ ក្នុងការិយាល័យដែលសម្រាប់កត់ឈ្មោះហ្នឹង ទាញចេញមកក្រៅហើយ បិទទ្វារជិតទៅ ក៏ចេញមកខាងក្រោមកយ៉បង្កាន់ដៃមុខហ្នឹង ទម្លាក់កូនហ្នឹងមកដី ខ្ញុំនៅពីក្រោមហ្នឹងក៏ឃើញធ្លាក់មក ក៏វាស្លាប់ទៅ ហើយបញ្ជាឲ្យខ្ញុំ បក់ដៃឲ្យខ្ញុំយកទៅកប់ចោលនៅខាងត្បូងហ្នឹងទៅ។"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៣:៥៣:២៩]

លោក លោកស្រីចៅក្រម ចំណុចមួយដែល<យើងដឹង>ចេញពីសក្ខីកម្មរបស់កម្មាភិបាល

ស-២១រូបនេះ គឺថាក្មេងៗតាមធម្មតា គឺថាគេមិនថតរូបក្មេងៗទាំងនោះ គេមិនចុះឈ្មោះក្មេងៗទាំងនោះក្នុងបញ្ជីទេ នៅពេលដែលគេយកក្មេងៗទាំងនោះមកស-២១។ អ៊ីចឹងកំណត់ហេតុដែលនៅសល់នោះ គឺ <មិនបានឆ្លុះបញ្ចាំងពី>ចំនួន<ជាក់លាក់>ក្មេងៗដែលគេសម្លាប់នៅស-២១នៅជុំវិញបរិវេណស-២១នេះ<ទេ>។ <ប៉ុន្តែ មានរបាយការណ៍សេសសល់ចំនួន>ក្មេងៗ<ជា>ជនជាតិវៀតណាម។ <យើងបញ្ចាំងស្លាយបន្ទាប់។> សហការីរបស់ខ្ញុំ ក៏បានបង្ហាញពីចំណុចនេះហើយ ដោយសារថាមិនមានរូបថតពីក្មេងៗនោះ<ច្រើន>ទេ។ នេះគឺកុមារីវៀតណាមអាយុ<១៣>ឆ្នាំដែល<មកពីខេត្តស្វាយរៀងចូលមកមន្ទីរស-២១ >នៅខែឧសភា ៧៨ <រួមទាំង>ប្អូន<ប្រុសរបស់នាង អាយុតិចជាងនាងប្រាំឆ្នាំ។ កាលនោះ ក្មេងប្រុសនេះ>មានអាយុតែ៨ឆ្នាំ<ប៉ុណ្ណោះ> ហើយឪពុករបស់នាងក៏មានចុះក្នុងបញ្ជីស-២១ដែរ "ធ្វើស្រែ" នៅខេត្តស្វាយរៀង។ កុមារីតូចនេះ <ឈ្មោះ វិញ ធីង៉ុក> ជាក្មេងស្រីម្នាក់ក្នុងចំណោមក្មេងស្រីជនជាតិវៀតណាម១៦នាក់<អាយុចន្លោះ ១៣ ដល់១៥ឆ្នាំ មានឈ្មោះនៅក្នុងកំណត់>ត្រានៅក្នុងស-២១ <ជាកំណត់ត្រានៅសេសសល់ពីសម័យហ្នឹង>។

បាទ សូមចូលទៅ*ស្លាយ*បន្ទាប់ <ក្នុង*ស្លាយ*លេខ៧>។ នៅក្នុងកំណត់ត្រាស-២១ មានក្មេងៗប្រាំពីរនាក់ អាយុចន្លោះពី១០ទៅ១១ឆ្នាំដែលជាជនជាតិវៀតណាម។ នេះគឺ លី យ៉ាំងវើ ជាកុមារាជនជាតិវៀតណាម<ក្នុងលេខរៀង៦១០ -- សុំទោស -- លេខរៀងគាត់គឺ១២.៥៩០ ក្នុង>បញ្ជី<របស់> ក.ស.ច.ស ហើយរូបថត<ក្មេងនោះមានដាក់លេខ៦១០ ជារូបថតប្រមូលបានថ្មីៗពី>មជ្ឈមណ្ឌលឯកសារកម្ពុជា <ដែលបានផ្តល់ជូនយើងដែរ។> ក្មេងនេះមកពីភូមិភាគនិរតី ហើយចូលមកស-២១ នៅថ្ងៃទី១២ តុលា ១៩៧៨។ ក្មេងៗដទៃទៀតដែលយើងខ្ញុំបានបង្ហាញនូវលេខជើងទំព័រ២.៣០៣ <ក្នុងសារណាបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់យើង។ ក្នុងចំណោមពួកគេនោះ> គឺមានកុមារីអាយុ៨ឆ្នាំ <ម្នាក់ ឈ្មោះ ឡឺ ធីមីភឿន> មានលេខរៀង១២.៦៩៧ នៅលើបញ្ជីរបស់ ក.ស.ច.ស ហើយក៏មានកុមារាអាយុ<៧>ឆ្នាំ<ពីរនាក់ទៀត មានក្នុងបញ្ជីហ្នឹងដែរ>។ យើងអត់មានរូបថតរបស់គេទេ ប៉ុន្តែក្មេង<ម្នាក់ក្នុងចំណោមក្មេងទាំងពីរ>នេះ <ឈ្មោះ ទ្រឹង> យ៉ាំង<ហ្វាក> គឺអាយុ៧ឆ្នាំ បានចូលមកស-២១ នៅថ្ងៃទី០៣ <ខែតុលា>១៩៧៨<។ នៅថ្ងៃបន្ទាប់ ក្មេងនោះត្រូវបានសម្លាប់។ មន្ទីរស-២១បានពិពណ៌នាថាក្មេងដែលមានអាយុទើបតែ៧ឆ្នាំនេះ ថាជាគិញវៀតណាម។ មានក្មេងប្រុសអាយុ៧ម្នាក់ទៀត> លេខរៀង ១២.៦៦០ <ឈ្មោះ ទ្រឹង យ៉ាំងង៉ុក ក្នុងបញ្ជី ក.ស.ច.ស>។

[១៣:៥៦:៥២]

បាទ សូមចូលទៅ*ស្លាយ*បន្ទាប់ គឺឯកសារ E3/4604<។ នេះជាឯកសារថតចម្លង ចេញពីទស្សនាវដ្ដីទង់បដិវត្ត ខែមេសា ឆ្នាំ១៩៧៨ ដែលលើកឡើងអំពីជ័យជម្នះគោលនយោបាយបោសសម្អាតជនជាតិវៀតណាម។ ទស្សនាវដ្ដីនេះសរសេរថា៖ "ចុះឥឡូវនេះអំពីយួន? គឺថាយួនលែងមាននៅក្នុងទឹកដីកម្ពុជាទៀតហើយ ពីមុននោះមានយួនជិត១លាននាក់ ឥឡូវនេះ គឺថាតែមួយគ្រាប់រកមិនឃើញផង។" នៅពេលដែលជនជាតិវៀតណាមភាគច្រើន បញ្ជូនទៅវៀតណាមវិញនៅដើមនៃរបបនេះ ក្រោយមកក៏មានគោលនយោបាយសម្លាប់អ្នកដែលនៅសេសសល់ មិនបានបញ្ជូន ហើយក៏ដូចជាការសម្លាប់អ្នកដែលមានជាប់សាច់ឈាមជាមួយវៀតណាម ឬក៏រៀបការជាមួយវៀតណាម ក្នុងគោលបំណងដើម្បីសម្លាប់ជនជាតិវៀតណាមនៅក្នុងប្រទេសកម្ពុជានេះ ឲ្យអស់តែម្ដង។

ឥឡូវនេះ ខ្ញុំសូមចូលទៅនិយាយអំពីប្រជាជនចាមវិញម្ដង។ រឿងរ៉ាវដែលកើតឡើងទៅលើជនជាតិចាមនេះ គឺខុសពីអ្វីដែលកើតឡើងទៅលើជនជាតិវៀតណាម។ <វាខុសគ្នាច្រើនទៀតផង។> យើងអាចត្រឡប់ទៅពិនិត្យមើលនិយមន័យនៃអំពើប្រល័យពូជាសាសន៍ឡើងវិញ។ បាទ សូមបញ្ចាំង*ស្លាយ* ពាក់ព័ន្ធទៅនឹង អំពើប្រល័យពូជសាសន៍ <ម្ដងទៀត>។ អំពើប្រល័យពូជសាសន៍ ត្រូវបានកំណត់និយមន័យមួយថា ជា<ចេតនា>ការសម្លាប់ទាំងស្រុង ឬក៏មួយផ្នែកនៃក្រុមសាសនា ឬជនជាតិភាគតិចណាមួយ។ បញ្ហាមួយដែលកំពុងតែ<កើតឡើង>ក្នុងការពិចារណាច្បាប់អន្តរជាតិនៅឡើយនោះ<។ ខ្ញុំគិតថា នៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះ និងត្រិះរិះបន្ថែមទៅលើវិវឌ្ឍនភាពនៃច្បាប់អន្តរជាតិនេះលើផ្នែកអំពើ>ប្រល័យពូជសាសន៍។ <ហើយពាក្យហ្នឹង វាមានន័យយ៉ាងម៉េច?> នេះ គឺជាគោល-ការណ៍មូលដ្ឋាននៅ<>សម្រាប់ការបកស្រាយច្បាប់ណាមួយដែលថា ពាក្យពេចន៍ទាំងអស់នៅក្នុងច្បាប់នេះ គឺថាត្រូវតែមានអត្ថន័យច្បាស់លាស់ មិនមែនចេះតែដាក់ពាក្យពេចន៍ទាំងនេះ ចូលដោយមិនមាន<ន័យ>អ្វីនោះទេ។ ឥឡូវ <តើវាមានន័យយ៉ាងណា -- និយាយអំពីក្រុមសាសនាវិញ -- >ការបំផ្លិចបំផ្លាញក្រុមសាសនាណាមួយបែបនោះ។ អ៊ីចឹងពាក្យថា "ដូចជា" យ៉ាងៗម៉េច" ពាក្យថា "ដូចជា" ឧទាហរណ៍មានប្រជាជនមួយក្រុមគាត់មានជំនឿសាសនាណាមួយ គាត់ប្រកាន់ជំនឿសាសនាណាមួយ គាត់អនុវត្តប្រតិបត្តិសាសនាណាមួយរួមគ្នាគាត់។ បើយើងបញ្ឈប់ប្រជាជននេះ ក្រុមនេះ មិនឲ្យគាត់គោរពប្រតិបត្តិសាសនានេះតទៅទៀត អ៊ីចឹងក្រុមនេះលែងមានតទៅទៀតហើយ។ <សមាជិកក្រុមម្នាក់ៗ>អាចនៅរស់ ប៉ុន្តែសាសនាដែលគេជឿនោះ គឺថាលែងមានតទៅទៀតហើយ។ <គេមានវិធីជាច្រើនសម្រាប់ធ្វើបែបហ្នឹង។ មាន>ខ្លះអាច<បណ្ដាលឲ្យមានអំពើប្រល័យពូជសាសន៍ ឯខ្លះទៀតមិន

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បណ្ដាលឲ្យមានរឿងហ្នឹងកើតឡើងទេ។ ឧទាហរណ៍> បើសិនណាជាបិទសាលារៀន វាអាចគ្រាន់ <តែ>ថាធ្វើទុក្ខបុកម្នេញ <ប៉ុន្ដែ>មិនមែនជាអំពើប្រល័យពូជសាសន៍ទេ។ ប៉ុន្ដែបើផ្នែកមួយនៃគោល-នយោបាយសម្លាប់<សមាជិកក្រុមណាមួយ នោះវាស្ថិតក្នុងវង្វង់ចំណុចទាំងប្រាំ អ៊ីចឹង គេរាប់ថាជាអំពើប្រល័យពូជសាសន៍ហើយ។> បើយើងសម្លាប់សមាជិកក្រុមណាក្នុងគោលបំណងបំផ្លិចបំផ្លាញក្រុម<>នោះ<ទាំង>ស្រុង ឬតែមួយផ្នែក នេះវាស្ថិតនៅក្នុងវង្វង់និយមន័យអំពើប្រល័យពូជសាសន៍ហើយ។

[១៤:០០:៣៥]

<គេប្រើភាសាមួយចំនួនក្នុងការសិក្សា ហើយសូម្បីតែពាក្យ>នៅករណី<មុន ដែល>គេបានបកស្រាយថា ពាក្យ< "អ៊ីចឹង" យើងគិតថា វាមិនត្រឹមត្រូវទេ។ គេថា យើងសម្លាប់> ដោយសារតែគេជាជនជាតិចាម ឧទាហរណ៍។ ប៉ុន្ដែ<នេះមានន័យថា ការប្រើប្រាស់ពាក្យនោះ វាមានភាពលើសលប់ទៅហើយ ពីព្រោះបញ្ញត្តិបានកំណត់រួចហើយថា>បើសិនណាមិនមានចេតនាសម្លាប់ក្រុមនោះ មួយផ្នែក ឬទាំងស្រុង វាមិនមែនជាអំពើប្រល័យពូជសាសន៍ទេ។ <អ៊ីចឹង តើវាមានន័យយ៉ាងណាវិញ ពាក្យថា "បំផ្លាញក្រុមហ្នឹង"? ជាថ្មីម្ដងទៀត នេះមានន័យថា ក្នុងខណៈបុគ្គលខ្លះក្នុងក្រុមនោះនៅរស់ ប៉ុន្ដែក្រុមទាំងមូលបានរលាយទៅហើយ។ ក្រុមនេះចង់សំដៅទៅលើជាតិសាសន៍មួយ ឬជាតិពន្ធុមួយ។ បើយើងរើសយកក្រុមសាសនាមួយមក ប្រាប់គេឲ្យប្ដូរសាសនា បើមិនប្ដូរទេ យើងនឹងសម្លាប់។ នេះមានន័យថា យើងសម្លាប់អ្នកមិនព្រមប្ដូរសាសនា។> អ៊ីចឹងបើយើងសម្លាប់ក្រុមទាំងនោះទាំងមូល ហើយប៉ុន្ដែអ្នកមិនបានសម្លាប់នោះ ក៏យើងបានបំបិទសាសនាគេទាំងស្រុងដែរ។ ហើយយើងឃើញថា វាមានការកើតឡើងនូវផ្នែកដទៃទៀត នៅក្នុងពិភពលោកផងដែរ។ នេះគឺជាចំណុចសំខាន់ ព្រោះថាជនជាតិចាម គឺជាករណីមួយដែលពាក់ព័ន្ធទៅនឹងគោលនយោបាយផងដែរ <ហើយប្រែប្រួលតាមកាល>។ <យើងមានភស្ដុតាងខ្លះ នៅក្នុងសំណុំរឿងរបស់យើង។ គេមានចេតនាដាក់បញ្ចូលចាម ហើយ>រារាំងមិនឲ្យទាំងអនុវត្តសាសនា មិនឲ្យនិយាយភាសាចាម មិនឲ្យគោរពទៅតាមជំនឿ ឬក៏<ស្លៀកពាក់តាម>ប្រពៃណីរបស់ចាម។ គឺគេធ្វើឡើង តាំងពី<ដើមរបបនេះ>មុនឆ្នាំ៧៥ គឺតាំងពីឆ្នាំ<ដើមឆ្នាំ> ៧៣ មកម្ល៉េះ<។ ការធ្វើទុក្ខបុកម្នេញនេះបានចាប់ផ្ដើមឡើងក្នុងវិធី>ព្យាយាមលុបបំបាត់ជនជាតិចាម។ ហើយ<មន្ទាប់មក >គោលនយោបាយនេះ មានការប្រែប្រួលកាន់តែខ្លាំងឡើង នៅពេលដែលមានការបះបោរនៅកោះផល និង<ភូមិស្វាយឃ្លាំង>។ នៅពេលដែលប្រជាជនចាម នៅក្នុងភូមិនុំង<មិនព្រម

លះបង់សាសនារបស់ខ្លួន ហើយពួកគាត់>បះបោរឡើង យកកាំបិត យកដំបង <ដាវ>ដើម្បីវ៉ៃជាមួយពួកខ្មែរក្រហម <ដែលកាន់សុទ្ធតែកាំភ្លើង និងអាវុធធន់ធ្ងន់>។ ដូច្នេះហើយ ពេលនោះ<របបនោះ> ចាប់ផ្ដើម<សង្ស័យកាន់តែខ្លាំងឡើងមកលើ>ក្រុមជនជាតិចាមហ្នឹង។ <គេគិតថា> "<ក្រុមមួយនេះ> លែងនៅក្រោមការគ្រប់គ្រង<យើងហើយ">។ <គោលនយោបាយបន្ទាប់ បន្ថែមលើការសម្លាប់នោះ គឺ>ពួកគេព្យាយាមបំបែកជនជាតិចាម ជាពិសេសគេបញ្ជូនពួកជនជាតិចាមទាំងអស់នោះ ទៅនៅកន្លែងផ្សេងៗគ្នា គឺគេបំបែកចេញពីតំបន់ដែលជនជាតិចាមធ្លាប់រស់នៅ<ផ្តុំគ្នា>នៅតាមដងទន្លេមេគង្គ នៅក្នុងខេត្តកំពង់ចាម ឲ្យទៅនៅកន្លែងផ្សេងៗទៀត ជាពិសេសនៅក្នុងស្រុក<បីគឺ>កំពង់សៀម ក្រូចឆ្មារ និងស្រុកកងមាស ជាដើម។ គឺនៅក្នុងស្រុកទាំងបីនោះ ដែលមានជនជាតិចាមច្រើន គេបំបែកចេញ។

[១៤:០៣:៣៩]

វិធីសាស្ត្រមួយដែលពួក<អាជ្ញាធរ>ព្យាយាមកម្ទេចក្រុមមួយនេះ គឺហាមឃាត់ការអនុវត្តសាសនា។ មេធាវីការពារក្តីនៅក្នុងសារណាដែលដាក់ដោយខាង នួន ជា បាន<លើកយក>សេចក្តីសម្រេចមួយចំនួន<ដែលនិយាយអំពី>ការហាមឃាត់ ទៅលើការអនុវត្តសាសនា<ថាមិនបាន>រំលោភទៅលើច្បាប់អន្តរជាតិទេ ឧទាហរណ៍ ដូចថា មិនមែនជាការខុសច្បាប់ទេ ដែលហាមមិនឲ្យបួងសួងទៅតាមផ្លូវថ្នល់ជាដើមនោះ។ ប៉ុន្តែយ៉ាងណាក៏ដោយ <ឧទាហរណ៍ នៅក្នុងរឿងក្តីមួយក្នុងចំណោមរឿងក្តីទាំងឡាយ គេបានលើកសំណុំរឿងមួយ *S.A.S v. France* ដែលបង្ហាញយ៉ាងច្បាស់>នៅក្នុងកថាខណ្ឌ ១២៥ <ដោយច្បាប់អន្តរជាតិទទួលស្គាល់ថា វាជាសិទ្ធិមនុស្ស ក្នុងការបង្ហាញជំនឿសាសនារបស់ខ្លួន។ អ្វីដែល>កថាខណ្ឌ១២៥ បានបញ្ជាក់ច្បាស់ <ខ្ញុំសូមដកស្រង់៖ "ក្នុងខណៈ:>សេរីភាពសាសនា គឺជា<រឿង>របស់បុគ្គល ប៉ុន្តែក៏មានន័យថា ជាសេរីភាពក្នុងការបង្ហាញសាសនានៅក្នុងសហគមន៍ ឬក៏ជាឯកជន អាចថានៅក្នុងសាធារណៈ ឬក៏នៅក្នុងក្រុមរបស់អ្នកដែលមានជំនឿដូចគ្នា។" ប៉ុន្តែអានេះ មិនមែនជាអ្វីដែលខ្មែរក្រហមបាន<អនុញ្ញាត>នោះទេ<សម្រាប់មូស្លីម ក៏ដូចជាពុទ្ធសាសនិក។ ពួកគេហាមមិនឲ្យមានការគោរពសាសនាតែម្តង>។ ពួកគេបានហាមឃាត់មិនឲ្យបង្រៀនសាសនាដល់ក្មេងៗ ហើយភាសា និងប្រពៃណីទំនៀមទម្លាប់<ចាម>ត្រូវបានគេដាក់ឲ្យនៅក្រៅច្បាប់ជាដើម។ គឺគេព្យាយាមបំបែកជនជាតិចាមចេញពីគ្នា បញ្ជូនទៅតាមតំបន់ផ្សេងៗគ្នានៅទូទាំងប្រទេសកម្ពុជា។ សូម្បីតែ<បាន សៀក និង ឱ ហូ> ដែលជាលេខាស្រុកក្រូចឆ្មារ<នៅចុងរបបនោះ >ដែលបានមកផ្តល់សក្ខីកម្មនៅទីនេះ ក៏បាននិយាយថា គឺគាត់មកថ្ងៃ០៥ តុលា ២០១៥។ <ជាក់ស្តែង គាត់មិនបានសារភាពអី

ច្រើនទេ តែ>គាត់បាននិយាយ<ពិសេស>អំពីតួនាទីរបស់គាត់ អំពីការសម្លាប់ជនជាតិចាម ហើយគាត់ក៏បានទទួលស្គាល់ផងដែរថា ជនជាតិចាម ត្រូវបានគេហាមឃាត់មិនឲ្យគោរពប្រតិបត្តិទៅតាមជំនឿសាសនា។ សាក្សីមួយទៀត ឈ្មោះ ឱ ហួ គឺជាមេភូមិនៅក្នុងខេត្តកំពង់ធំ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យបាននិយាយថា<> តំណាងអង្គការថ្នាក់លើបានប្រាប់គាត់ថា <ខ្ញុំសូមដកស្រង់៖ “> នៅកម្ពុជាគឺមានប្រជាជនតែមួយគត់គឺខ្មែរ គ្មានចាមនោះទេ។” គឺគាត់ផ្តល់សក្ខីកម្ម ថ្ងៃ២០ ឧសភា ២០១៥ ម៉ោង ១៤:០២។ ឱ ហួ ក៏បានផ្តល់សក្ខីកម្មផងដែរថា ប្រជាជនចាមមិនត្រូវអនុញ្ញាតឲ្យស្នាក់នៅក្នុងភូមិ គឺពួកគេត្រូវបញ្ជូនទៅកន្លែងនេះបន្តិច ទៅកន្លែងនោះបន្តិច។ គាត់ផ្តល់សក្ខីកម្មថា៖ “ចំពោះសាសនា<គឺយើងក៏អាចនិយាយថា ដូចតែព្រះពុទ្ធសាសនាដែរ គឺរាល់សាសនាត្រូវលុបបំបាត់ទាំងអស់> គឺមិនឲ្យមានការបួងសួង ថ្វាយបង្គំអ្វីទៀតនោះឡើយ។” ហ៊ឹម ម៉ាន ក៏ជាជនជាតិចាម មកពីស្រុកកងមាស ខេត្តកំពង់ចាម គាត់បានប្រាប់តុលាការថា <>ក្រោយថ្ងៃ១៧ មេសា គឺក្រោយពេលជ័យជម្នះរបស់ខ្មែរក្រហមនៅក្នុងរដូវប្រាំង ជនជាតិចាមជាច្រើន ត្រូវបានគេបញ្ជូនដោយបង្ខំទៅកន្លែង ផ្សេងៗទៀត សូម្បីតែ ហាគីម ក៏ត្រូវបានគេបញ្ជូនចេញដែរ គឺជាមេដឹកនាំសាសនាក្នុងភូមិ។ គ្រួសាររបស់គាត់ គឺជាគ្រួសារមួយក្នុងចំណោមគ្រួសារ តែ៣០គ្រួសារដែលត្រូវបានគេអនុញ្ញាតឲ្យនៅ។ គាត់បាននិយាយថា ខ្មែរក្រហម ផ្សព្វផ្សាយការប្រកាសដូចតទៅនេះ។ ឥឡូវនេះ គឺមិនមានចាមទៀតទេ មិនមានខ្មែរទៀតទេ យើងគឺជាជាតិសាសន៍តែមួយគឺ ជាតិខ្មែរ។ គាត់និយាយថា នៅក្នុងរដូវប្រាំងឆ្នាំ៧៥ ហ្នឹង ជនជាតិចាមដែលនៅសេសសល់ត្រូវបានគេហៅឲ្យមកចូលប្រជុំ ហើយមេភូមិបានប្រាប់ពួកគេថា <ខ្ញុំសូមដកស្រង់>៖ “អ្វីៗទាំងអស់ទាក់ទងនឹងសាសនាអ៊ីស្លាម គឺត្រូវហាមឃាត់មិនឲ្យអនុវត្តសាសនា”។ ហើយនៅពេលនោះ គេប្រាប់យើងថា៖ “កង់ប្រវត្តិសាស្ត្រកំពុងតែវិលហើយ ប្រសិនបើលូកដៃដាច់ដៃ លូកជើងដាច់ជើង”។ គឺគាត់បានផ្តល់សក្ខីកម្មនៅ<ថ្ងៃ១៧> ឧសភា ២០១៥។

[១៤:០៨:១៧]

អ៊ិត សេន ក៏បានប្រាប់ខាង ក.ស.ច.ស ថា នៅក្នុងភូមិអំពិល នៅខេត្តកំពង់ចាម នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្ញុំសូមដកស្រង់៖ “យើងមិនអនុញ្ញាតឲ្យគោរពសាសនាចាម មិនឲ្យនិយាយភាសាចាមឡើយ។ នារីៗ ត្រូវកាត់សក់ខ្លី។ យើងត្រូវបានគេបង្ខំឲ្យហូបអាហាររួមគ្នា ឲ្យហូបសាច់ជ្រូក។ ខ្មែរក្រហម មិនបានពន្យល់ថា ហេតុអ្វីនោះទេ។ ហើយអ្នកដែលមិនធ្វើតាមនឹងត្រូវបានគេយកទៅសម្លាប់ចោល។” <មិន>មានជនជាតិចាមនៅក្នុងភូមិភាគពាយ័ព្យជាច្រើន <ប៉ុន្តែ មានព្រឹត្តិការណ៍

មួយមាននៅក្នុង>ក្នុងរបាយការណ៍<ប្រចាំសប្ដាហ៍>របស់ខាងតំបន់៥ គឺរបាយការណ៍ E3/178 <អាជ្ញាធរមូលដ្ឋាន>បាន<រាយការណ៍ទៅកាន់មជ្ឈិម គឺអង្គការ>ថា ជនជាតិចាម នៅខាងពាយ័ព្យគឺ និយាយ គឺផ្អែកទៅលើ<រដ្ឋធម្មនុញ្ញស្ដីពីសិទ្ធិសេរីភាព>ជំនឿសាសនា។ <ពួក>គេ<បាន>តវ៉ាអំពីអាហារ<ដែលផ្ដល់ ហើយគេបានប្រាប់ថា អាហារទាំងនេះ> វាខុសនឹងសាសនា។ <តាម>របាយ-ការណ៍របស់<គណៈ>តំបន់៥ បាន<លើកឡើង>ថា៖ “<ដើម្បីដោះស្រាយស្ថានភាពនេះ> យើងចាត់វិធានការពិសេសដើម្បីស្វែងរក<ខ្សែបណ្ដាញ គឺស្វែងរកមេដឹកនាំចលនារបស់ពួកវា ដើម្បី>បោសសម្អាតចោល។” វិធីសាស្ត្រមួយទៀត គឺថាយើងចង់កម្ទេចក្រុមមួយ គឺយើងផ្ដោតគោលដៅទៅលើ<ចំណុចសំខាន់រួមរបស់>ក្រុម<នោះ ដែលជាចំណុចរស់ ឬស្លាប់នៃក្រុមហ្នឹង។>

[១៤:១០:00]

នៅក្នុងកថាខណ្ឌ១២ នៃសាលដីការបស់ គ្រីស្ទីក បាននិយាយថា “បន្ថែមទៅលើទំហំនៃផ្នែក<ជា>គោលដៅ <ជាចំណុច>សំខាន់<នៅក្នុងក្រុម អាចមានប្រយោជន៍សម្រាប់>ការពិចារណា<ផងដែរ។ បើសិនណាផ្នែកជាក់លាក់ណាមួយក្នុងក្រុមស្រដៀងគ្នាដូចក្រុមទាំងមូល ឬជាផ្នែកសំខាន់សម្រាប់អាយុជីវិតក្រុម គាំទ្រដល់របកគំហើញថាផ្នែកនេះមានគុណប្រយោជន៍ជាផ្នែកស្នូល>នៅក្នុងអត្ថន័យនៃអនុសញ្ញារបស់ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។” <យើងចាំបានថា គេព្យាយាមបំផ្លាញ “ដោយផ្នែក” គឺត្រូវតែជា>ផ្នែកសំខាន់<ដែលអាចប៉ះពាល់ទៅដល់ក្រុមទាំងមូល។> បញ្ហានេះកើតឡើងនៅក្នុងជនជាតិចាម ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ <ដែលចំនួន>ហាគីមដែលជាមេភូមិចាម<ធ្លាក់ចុះពីចំនួន១១៣នាក់ ចុះទៅ២០នាក់>។

ផ្អែកទៅតាម អ៊ីសា ឧស្មាន នៅក្នុងសៀវភៅរបស់គាត់បាននិយាយថា ចំពោះចំនួនតួន <ជាគ្រូបង្រៀនសាសនាអ៊ីស្លាម>គឺមានប្រហែលជា៣០០នាក់ជាង <ធ្លាក់មកត្រឹមតែ៣៨នាក់។>។ អ៊ីសា ឧស្មាន បានផ្ដល់សក្ខីកម្មកាលពីថ្ងៃ១០ កុម្ភៈ ២០១៦ បានថានៅដើមរបបកម្ពុជាប្រជាធិបតេយ្យ គឺឆ្នាំ ៧៥, ៧៦ ការសម្លាប់មិនផ្ដោតទៅលើជនជាតិចាម<តែមួយមុខ>ទេ ប៉ុន្តែផ្ដោតទៅអ្នកដែលមិន<ព្រមលះបង់សាសនា ទំនៀមទម្លាប់ និងភាសារបស់ខ្លួនតាមការ>ណែនាំរបស់អង្គការ។ ប៉ុន្តែ <គ្រាន់តែបង្ខំគេឱ្យលះបង់សាសនា ទំនៀមទម្លាប់ និងភាសារបស់ក្រុមមួយ វាគ្រប់គ្រាន់ណាស់ហើយ បង្កើតបានជាអំពើប្រល័យពូជសាសន៍។ បើសិនណាគេបំផ្លាញធាតុទាំងបីនេះ គឺមានន័យថា គេបំផ្លាញក្រុមទាំងមូលហើយ។ ប៉ុន្តែ លោក អ៊ីសា ឧស្មាន បន្តនិយាយថា >គោលនយោបាយហ្នឹងបានផ្លាស់ប្ដូរ<នៅចុងរបប

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

នៅពេលដែលមេដឹកនាំរបបនោះកាន់តែកើតជំងឺត្រដេវរិច ភាពអន្តរាយកាន់តែកើតឡើងខ្លាំងដែរ។>

[១៤:១១:៥៧]

ខ្ញុំសូមបង្ហាញនូវ*ស្លាយ*លេខ៨ ដែលនិយាយអំពីចំណុចស្នូលរបស់ជនជាតិចាម។ <យើងមានសក្ខីកម្មជាច្រើនរួចមកហើយ ចេញពីស្រុកបី> គឺនៅកំពង់សៀម ក្រូចឆ្មារ ហើយនិងកងមាស។ នេះគឺជាផ្នែកសំខាន់របស់សហគមន៍ចាមនៅក្នុងប្រទេសកម្ពុជា ហើយខ្ញុំសូមបញ្ជាក់ថា គឺជាផ្នែកដ៏សំខាន់ដែលធានាដល់ការរស់រានមានជីវិតនៃក្រុមជនជាតិចាមនៅក្នុងប្រទេសកម្ពុជាទាំងមូលតែម្តង។ នៅក្នុងរយៈពេលដំបូងនៃរបបកម្ពុជាប្រជាធិបតេយ្យ <គេបានបំបែកជនជាតិចាម ជាពិសេសនៅតាមច្រាំងទន្លេ។ ក្នុង>*ស្លាយ* បន្ទាប់គឺតេឡេក្រាម<១៥ >របស់ខាងភូមិភាគដែល<សោ ភឹម>ផ្ញើទៅមជ្ឈិម<ក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៥> គឺនិយាយអំពីការជម្លៀសជនជាតិចាម<។ គាត់សរសេរថា៖ "យើងបានជម្លៀសចាម>នៅតាមទន្លេ ហើយនៅតាមព្រំដែន។ <ជា>គោលការណ៍នៃការជម្លៀសហ្នឹងគឺដើម្បីបំបែកជនជាតិចាម ផ្អែកទៅលើការពិភាក្សាកន្លងមក។" <ពិតណាស់ សោ ភឹម ជាសមាជិកម្នាក់ក្នុងគណៈអចិន្ត្រៃយ៍ ជាអង្គការកំពូលសម្រាប់ចេញគោលនយោបាយរបស់ខ្មែរក្រហម ទោះបីជាគាត់មិនសូវចូលប្រជុំដោយរវល់ទៅឆ្ងាយក៏ដោយ។>

ឥឡូវនេះខ្ញុំសូមនិយាយអំពីសក្ខីកម្មរបស់អតីតលេខា<>ស្រុកកំពង់សៀមវិញម្តង ជាសាក្សីដ៏សំខាន់។ នៅក្នុងសារណារបស់មេធាវីការពារក្តី នួន ជា ពួកគាត់បានទទួលស្គាល់ថា សក្ខីកម្មរបស់បុគ្គលរូបនេះ គឺវាមានឥទ្ធិពលខ្លាំងណាស់ ទាក់ទងទៅនឹងគោលនយោបាយប្រល័យពូជសាសន៍ទៅលើជនជាតិចាម។ <ក្រុមមេធាវី>នួន ជា បានលើកឡើងនូវការជំទាស់ដែលខ្ញុំសូមហៅថា <ទ្រឹស្តីផ្សំគំនិតដ៏លីលា>មួយ<-- ម៉េចបានជាខាងព្រះរាជអាជ្ញាដឹងមុនថា> ប្រាក់ យុត <មកធ្វើសក្ខីកម្មអំពីសវនាការ>ផ្នែកជនជាតិចាមនេះ។ លោក លោកស្រីចៅក្រម អ្នកដែលដឹងសំណុំរឿងទាំងអស់ហ្នឹង ប្រាកដជាចង់ស្តាប់<សក្ខីកម្ម>លេខាស្រុកកំពង់សៀម លេខាស្រុកកងមាស និងលេខាស្រុកក្រូចឆ្មារ។ យើងបានលើកពី បាន សៀក អំពី ហ្វូ ដែលជាលេខាស្រុក<ក្រូចឆ្មា ចូលមកធ្វើសក្ខីកម្ម។ បើទោះបីជាគាត់បន្តកុហកអំពីការចូលរួមរបស់គាត់ក្នុងអំពើសម្លាប់រង្គាលហ្នឹងក៏ដោយ ក៏សក្ខីកម្មរបស់គាត់មានប្រយោជន៍ដែរ។> ព្រោះគាត់ជាលេខាស្រុកក្រូចឆ្មារ លេខាស្រុកដែលជាអ្នកគ្រប់គ្រងនៅពេលដែលមានការសម្លាប់ហ្នឹងកើតឡើងច្រើន។

[១៤:១៥:០០]

<ដូចគ្នាដែរចំពោះ ប្រាក់ យុត ជាកម្មាភិបាលនិរតីម្នាក់ បញ្ជូនពីមជ្ឈិមមកភូមិភាគកណ្ដាល មកបំពេញការងារគោលនយោបាយប្រល័យពូជសាសន៍។ >ដូចដែលខ្ញុំបានបញ្ជាក់ អ្នកដែលដឹងរឿង ដែលដឹងសំណុំរឿងប្រាកដជាចង់ស្ដាប់លេខាស្រុក។ មិនត្រឹមតែអ្នកដែលដឹងសំណុំរឿងទេ សូម្បីតែអ្នក ដែលចង់ស្វែងរកការពិត ក៏ប្រាកដជាចង់ស្ដាប់សក្ខីកម្មរបស់លេខាស្រុកកំពង់សៀមនេះដែរ។ <ក្នុង សំណុំរឿង មានព័ត៌មានជាច្រើនចំពោះព្រឹត្តិការណ៍ដែលកើតឡើងនៅក្នុងស្រុកនោះ។ ឧទាហរណ៍> អាឡិចសាន់ដឺ ហ៊ីនតុន នៅក្នុងសៀវភៅរបស់គាត់ដែលមានចំណងជើងថា"ហេតុអ្វីបានជាគេសម្លាប់?" ក៏គាត់បាននិយាយពីចំណុចនេះដែរ។ គាត់បាន<សរសេរថា ">ការសម្លាប់នេះធ្ងន់ធ្ងរនៅស្រុកកំពង់ សៀម។ ឯកសារពីរបានបង្ហាញថា សឹងតែគ្រប់ជនជាតិចាមនៅក្នុងស្រុកនោះត្រូវបានគេសម្លាប់ <ចោលអស់> គឺថាសមាជិកគ្រួសារដែលមានប្រហែលជា<២.០០០ ទៅ>២០.០០០នាក់ជាងត្រូវបាន កម្ទេចចោល។"

<លោក លោកស្រីចៅក្រម> អ៊ីសា ឧស្មាន នៅក្នុងសៀវភៅរបស់គាត់នៅក្នុងសៀវភៅរបស់ គាត់ដែលមានចំណងជើងថា "ការបះបោររបស់ចាម" គាត់រៀបរាប់អំពីភូមិ<ចាម>ចំនួន១០ដែលកាល ពីមុនជាភូមិជនជាតិចាម ប៉ុន្តែនៅពេលចុងក្រោយគឺមិនមានជនជាតិចាមទាល់តែសោះ បានន័យថា ជន ជាតិចាមត្រូវបានគេបោសសម្អាតទាំងស្រុកតែម្ដង។ ហើយប្រាំភូមិនៅក្នុងស្រុក នៅក្នុងភូមិទាំង១០ហ្នឹង គឺមកពីស្រុកកំពង់សៀម។ នៅពេលដែលយើងស្នើសុំសាក្សីនៅឆ្នាំ២០១៤ហ្នឹង គឺនៅពេលហ្នឹងគឺ យូ វ៉ាន់ ដែលជាមេឃុំហ្នឹង ក៏បាន<ឆ្លើយដាក់ ប្រាក់ យុត>អំពីការសម្លាប់ជនជាតិចាម។ គឺថាដូច្នេះយើង គួរតែដឹងថាតើសក្ខីកម្មរបស់លេខាស្រុកហ្នឹងវាមានឥទ្ធិពលយ៉ាងណា ហើយវាបានធ្វើឱ្យប៉ះពាល់ខ្លាំង យ៉ាងណាទៅដល់<ខាង>ការពារក្ដី <ពីព្រោះគាត់បានបង្ហាញរួចហើយថា មានគោលនយោបាយមួយ គឺកម្ទេចចាមនៅក្នុងស្រុកនោះ>។ ខ្ញុំសូមបង្ហាញនូវសក្ខីកម្មនេះ។

[១៤:១៧:១៤]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"មកពីតំបន់អ៊ីចឹង ថាឱ្យរៀបចំការបោសសម្អាតចាម អ៊ីចឹងខ្ញុំក៏ចាប់អារម្មណ៍ដែរថា យ៉ាងម៉េច បានជាបោសសម្អាតចាម? ឆ្ងល់ ហើយខ្ញុំក៏មិនបានទាន់បានធ្វើសេចក្ដីរាយការណ៍នៅក្នុងស្រុកហ្នឹងឱ្យ ដឹងច្បាស់ជនជាតិចាមប៉ុន្មាន គឺខ្ញុំអត់ច្បាស់ដែរ។ អ៊ីចឹងទៅការបោសសម្អាត ខ្ញុំចេះតែរាយការណ៍បន្ត ដូចថា ខ្ញុំអត់ទាន់បានក្ដាប់បានទេចំពោះប្រជាជនចាមនៅស្រុកកំពង់សៀម មិនដឹងគាត់មានប៉ុន្មាន អ៊ី*

*ប៉ុន្មាននាក់ទេ អ៊ីចឹងសូមឲ្យពូចាប់អារម្មណ៍បញ្ហានេះផង ព្រោះខ្ញុំវាយការណ៍មិនទាន់កើត។ នេះខ្ញុំសូមជម្រាបអង្គជំនុំអ៊ីចឹង គឺខ្ញុំមិនក្លាប់មិនបាន។ ហើយចាមនេះ ក៏ខ្ញុំមានការចាប់អារម្មណ៍ដែរ ឆ្ងល់ដែរ ហេតុអីបានជាចេះតែយកឈ្មោះចាមហ្នឹងទៅធ្វើ យកទៅ មានការបោសសម្អាតអ៊ីចឹង ខ្ញុំឆ្ងល់ដែរ ខ្លួនឯង ព្រោះខ្ញុំចាប់អារម្មណ៍ដែរតើបញ្ហាហ្នឹង។ តែផែនការនេះដាក់មកពីលើ ខ្ញុំក៏ចេះតែអនុវត្តតាមផែនការទៅនេះ។"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៤:១៨:៣០]

ប្រាក់ យុត ក៏បានការពារតួនាទីរបស់គាត់<ក្នុងអំឡុងពេលធ្វើសក្ខីកម្ម។> ប្រាកដណាស់ <> គាត់<បានទទួលបញ្ជាឲ្យ>បោសសម្អាតជនជាតិចាម ប៉ុន្តែគាត់ក៏បានផ្តល់ចម្លើយ<មុន>ដូចគ្នាទៅនឹងអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ហើយក៏និយាយថា "ក្នុងពេលបោសសម្អាតហ្នឹង -- <" សុំទោស> ខ្ញុំគ្រាន់តែដឹងថានេះគឺជាសក្ខីកម្មរបស់គាត់ថ្ងៃ១៨ មករា ២០១៦។ "<នៅអំឡុងពេលបោសសម្អាត > ខ្ញុំគ្រាន់តែដឹងថាជនជាតិចាមត្រូវបានគេយកទៅសម្លាប់ លេខាតំបន់បានប្រាប់ខ្ញុំ។ គឺមេរបស់គាត់បានប្រាប់គាត់ដោយផ្អែកទៅលើការណែនាំមកពីថ្នាក់លើ។" ប្រាក់ យុត ក៏បានប្រាប់អ្នកស៊ើបអង្កេត ក.ស.ច.ស ផងដែរថា៖ "ខ្ញុំចង់បញ្ជាក់ម្តងទៀតថា បញ្ជាដែលខ្ញុំទទួលបានគឺច្បាស់លាស់ណាស់ ព្រោះគេបានបញ្ជាក់ថាយើងត្រូវតែសម្លាប់ជនជាតិចាមទាំងអស់។ ខ្ញុំគ្មានជម្រើសអ្វីក្រៅពីអនុវត្តតាមបញ្ជានោះឡើយ។"

ហើយយើងដឹងតាមរយៈសក្ខីកម្មរបស់ យូ វ៉ាន់ <ជាលេខាឃុំ>ប្រាប់ថា ប្រាក់ យុត បញ្ជាឲ្យគាត់រៀបចំបញ្ជី<ឈ្មោះ>ជនជាតិចាម ជនជាតិវៀតណាម និងអតីតទាហានសីហនុ។ នៅថ្ងៃ១៤ មករា ២០១៦ <>យូ វ៉ាន់ ក៏បានផ្តល់សក្ខីកម្មអំពីការបាត់ខ្លួនជនជាតិចាម<ម្តងមួយៗ>។ គាត់បាននិយាយជាមួយនឹងមេបញ្ជាការយោធាស្រុក ហើយមេបញ្ជាការយោធាស្រុកបានប្រាប់ យូ វ៉ាន់ ថាជនជាតិចាម<ទាំងអស់នោះ>ត្រូវបានគេបោសសម្អាត។ <រឿងរ៉ាវដែលគួរឲ្យចាប់អារម្មណ៍មួយទៀតដែល>យូ វ៉ាន់ បានប្រាប់ <គឺ>ថា ប្រាក់ យុត ទៅភ្នំពេញម្តងពីរដងក្នុង១ខែ ពេលខ្លះទៅដល់១០ថ្ងៃ ដើម្បីទៅរៀនសូត្រ។ ដូច្នេះ ប្រាកដណាស់ថា គោលនយោបាយដែល ប្រាក់ យុត អនុវត្តគឺជាគោលនយោបាយមកពីមជ្ឈិម <ចេញ>មកពីភ្នំពេញ គឺមកពីជនជាប់ចោទ និង ប៉ុល ពត តែម្តង។ ប្រាក់ យុត មិនមែនជាសាក្សីតែមួយរូបដែល<ឃើញ>អំពីការសម្លាប់ជនជាតិចាម នៅក្នុងស្រុកកំពង់សៀម

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

នោះ<ប៉ុណ្ណោះ>ទេ <មាន> សេង គុយ ដែលជាអ្នកភូមិខ្មែរត្រូវបានគេបញ្ជាឱ្យ<ដឹក>បញ្ជូនជនជាតិចាមដែលគេចាប់ ដើម្បីយកទៅសម្លាប់នៅវត្តអូរត្រកួននោះ ក៏បាននិយាយថា គាត់បានឮមេឃុំ ប្រធានមន្ទីរសន្តិសុខឃុំ<ប្រតិបត្តិការចាប់ខ្លួន បាននិយាយថា ខ្ញុំសូមដកស្រង់៖ “>យើងត្រូវសម្លាប់ជនជាតិចាមទាំងអស់ ហើយមិនត្រូវលើកលែងអ្នកណាម្នាក់ឡើយ។” ម៉ុក សេងលី ដែលជាដើមបណ្ដឹងរដ្ឋប្បវេណី ជាអ្នកភូមិខ្មែរនៅស្រុកកំពង់សៀមបានប្រាប់ ក.ស.ច.ស ថាគាត់ត្រូវបានគេហៅឱ្យចូលប្រជុំ ហើយឮ ប្រាក់ យុត និយាយថា ចាមជាខ្មាំងអង្គការ។ ដោយសារតែពួកគេមានផែនការបះបោរ ដូច្នេះអង្គការត្រូវតែកម្ទេចពួកគេ។ ប្រសិនបើមានចាមនៅសល់ ត្រូវតែរាយការណ៍ ដើម្បីឱ្យយើងបោសសម្អាត ពីព្រោះថានេះជាផែនការរបស់ថ្នាក់លើ។

[១៤:២១:៣៧]

លោក លោកស្រីចៅក្រម ខ្ញុំដឹងថា យើងជិតដល់ពេលសម្រាកហើយ ដូច្នេះខ្ញុំព្យាយាមនិយាយឱ្យបានលឿនបន្តិចទៅលើចំណុចទាំងអស់នេះ។ <យើងមានភស្តុតាងសក្ខីកម្មជាច្រើនទៀត គឺបុគ្គលមួយចំនួនដែលបានដឹងអំពីផែនការកម្ទេចចាម។> ខ្ញុំនឹងលើកបង្ហាញអំពីសក្ខីកម្មមួយទៀតគឺ សាយ ឌឿន ដែលជាប្រធានកងមួយ នៅក្នុងស្រុកកងមាស <ទទួលបន្ទុកខាងចាប់ចង> បាន<ធ្វើសក្ខីកម្ម>ថា៖ “ខ្ញុំបានឮផែនការថា មិនត្រូវទុកឱ្យមានសល់ចាមណាមួយនោះឡើយ”។ គឺគាត់ផ្ដល់សក្ខីកម្ម<នៅថ្ងៃទី១២ ខែមករា >ឆ្នាំទៅ។ រស់ វំលី ដែលបានផ្ដល់សក្ខីកម្មកាលពីថ្ងៃ០៨ មករា ២០១៦ គាត់ជាស្មៀនឃុំក្រូចឆ្មារ ហើយគាត់បាននិយាយថា៖ “ប្រធានសន្តិសុខបានមកដល់ហើយអត់ដឹងថា <វំលី> ហ្នឹងចាមទេ <>ដោយសារតែគាត់មិនបានស្លៀកពាក់សម្លៀកបំពាក់ជនជាតិចាម។ ហើយប្រធានសន្តិ-សុខនុំង បាននិយាយថា ដោយដឹងថា មានជនជាតិចាមប្រហែលជា១៥ភាគរយនៅសល់ក្នុងឃុំហ្នឹង គឺអ៊ីចឹងបានន័យថា អនាគតត្រូវតែកម្ទេចឱ្យអស់ កុំឱ្យមានសល់មួយ។” សុះ កំរី ដែលធ្វើការនៅក្នុងកងចល័តនៅ<ខេត្ត>កំពង់ចាម <ផ្ដល់សក្ខីកម្មថា>បានចូលរួមនៅក្នុងការប្រជុំមួយនៅក្នុងស្រុកចំការលើនៅឆ្នាំ៧៧ ដែលនៅពេលនោះ គឺនិយាយ<>ផែនការកម្ទេចចាម។ នៅពេលក្រោយមក គាត់ឃើញ<កូនសៀវភៅមួយ>នៅមន្ទីរឃុំអ៊ូរនង ដែលរៀបរាប់ថា ចាមគឺជាខ្មាំងធំបំផុតដែលចាំបាច់ត្រូវតែកម្ទេចឱ្យអស់មុនឆ្នាំ១៩៨០។ <ចុងក្រោយ> ប៉ែន យៀវនិន បានសម្ភាសជាមួយ យ៉ា ម៉ាត់ ដែលប្រាប់គាត់អំពីការដែលគាត់ឃើញឯកសារនៅឆ្នាំ៧៨ នៅក្នុងតំបន់<៤៣ ក្នុងភូមិភាគកណ្ដាល> ដែលមានចំណងជើងថា “ឯកសារ១៦៣” ដែលនិយាយថា “យើងមិនត្រូវទុកពួកចាមឡើយ<> ប្រសិនបើយើង

ទុកពួកចាម ពួកគេនឹងបះបោរ។ <ដូច្នេះ ត្រូវកម្ទេចឲ្យអស់។"> ហើយ ប៉ែន យៀវនិន បាននិយាយជាមួយមនុស្សម្នាក់ទៀតឈ្មោះ អូស អែល ដែលបានប្រាប់គាត់អំពីការឃើញឯកសារ១៦៣ នៅក្នុងខែមិថុនា ៧៨ ផងដែរ <ក្នុងស្រុកបារាយណ៍>។

[១៤:២៣:៤១]

ខ្ញុំគិតថា ប្រហែលជាយើងដល់ពេលសម្រាក ឬមួយក៏យ៉ាងម៉េច? សូមលោកប្រធានសម្រេច។ សូមទោសលោកប្រធាន ខ្ញុំយល់ច្រឡំអំពីម៉ោងសម្រាក។ នៅពេលដែលយើងនិយាយអំពីកំពង់សៀម នៅពេលដែល ប្រាក់ យុត ជាលេខាស្រុកនោះ គឺថាអ្នកស៊ើបអង្កេត ក.ស.ច.ស បានបញ្ជូន<អ្នកស៊ើបអង្កេត>ជាច្រើនទៅកាន់<ឃុំ>ទ្រាន <ខ្ញុំគិតថា ឃុំទ្រានជាឃុំមួយក្នុង>ចំណោមភូមិទាំង១១ នៅក្នុងស្រុកកំពង់សៀម ហើយ<អ្នកស៊ើបអង្កេត>ក៏បានទៅ<កាន់ភូមិ១២នៅក្នុងឃុំហ្នឹង>ហើយបាននិយាយជាមួយប្រជាជនដែលនៅរស់រានមានជីវិត សល់ពីរបបកម្ពុជាប្រជាធិបតេយ្យ។ ហើយពួកគេសួរថា តើនៅចាំអីខ្លះអំពីជនជាតិចាមនៅក្នុងភូមិហ្នឹង? អ្នកទាំងអស់នោះ គឺគាត់ធ្វើការប៉ាន់ស្មានខុសៗគ្នាទៅលើចំនួន ប៉ុន្តែគាត់និយាយថា ប្រហែលជានៅក្នុងភូមិ១២ហ្នឹង គឺមានជនជាតិចាមប្រហែលជា២៩២គ្រួសារ ដែល<គេយកចេញ និងបាត់ខ្លួន នៅក្នុងរបបនោះ។ ពួកគាត់ប្រាប់ថា មាន>សាកសព<ជាច្រើន> គេទម្លាក់ចូលរណ្ដៅ<គ្រាប់បែក> ខ្លះគេទម្លាក់ចូលក្នុងអណ្ដូងជាដើម។ <អ្នកភូមិចាស់ៗទាំងនោះចងចាំព្រឹត្តិការណ៍ក្នុងរបបនោះ គាត់ប្រាប់ថា គាត់ដឹងថាមានតែបីនាក់ប៉ុណ្ណោះ ក្នុងចំណោះ២៩២>នៅសល់រស់រានមានជីវិត<>។

ខ្ញុំគិតថា យើងកើតការស្មានទាំងអស់ហ្នឹង គឺវាជាការទាយស្មាន បានន័យថា ប្រសិនបើយើងគិតទៅ គឺប្រហែលជានៅក្នុងចំណោម<២៩២គ្រួសារ> មានមនុស្សប្រហែលជាមនុស្ស១.៤៦៥នាក់ត្រូវបានសម្លាប់នៅក្នុងភូមិទាំង១២នុ៎ង <គ្រាន់តែ១១ឃុំ នៅក្នុងស្រុកដែល> ប្រាក់ យុត <គ្រប់គ្រង។ ប្រាក់ យុត ខ្លួនឯងផ្ទាល់ក៏>បានផ្ដល់សក្ខីកម្មថា <ខ្លួនបានរាយការណ៍ទៅមជ្ឈិម ថា>មានគ្រួសារជនជាតិចាមប្រហែលជា១.៦០០គ្រួសារ នៅស្រុកកំពង់សៀម ពេលគាត់មកដល់ហើយ គឺមានប្រហែលជា៨.០០០នាក់។ <ក្រោយមក គាត់បានប្រាប់ថា គាត់បានជួយសង្គ្រោះជីវិតចាមម្នាក់។> មានតែក្មេងស្រីជនជាតិចាមតែម្នាក់<ដែលគាត់យកមកចិញ្ចឹម កាលគាត់នៅក្នុងភូមិភាគនិរតី ដោយមិនដឹងថា ក្មេងនោះជាជនជាតិចាមឡើយ។ ក្មេងស្រីនោះឈ្មោះ ភាព ក្នុងសវនាការ អំឡុងពេលផ្ដល់សក្ខីកម្ម គាត់ក៏និយាយពីក្មេងស្រីនេះដែរ។> ឥឡូវនេះ ខ្ញុំចង់បញ្ជាក់ ដោយបង្ហាញនូវខ្សែវីដេអូដែលនិយាយ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៤:២៦:២២]

*(ការបង្ហាញឯកសារសំឡេង-រូបភាព)*

*"ស្រាប់មីអនថា បងឯងចិញ្ចឹមចាម ខ្ញុំអត់ដឹងដែរ។ កាលនោះគាត់យកមកផ្ញើ ខ្ញុំមិនបានចាប់អារម្មណ៍ ថាកូនចាម កូនខ្មែរអី វាផ្ញើច្រើន។ ហេតុនេះ ដល់ពេលហ្នឹងទៅ បានគាត់យំអ៊ីចឹង ខ្ញុំក៏ណែនាំគាត់ ឈ្មោះ ភាព។ ឥឡូវគេប្អូនថ្លៃរបស់ខ្ញុំ គាត់នៅស្ទឹងកែវ សព្វថ្ងៃនេះ។ ខ្ញុំទុកជីវិតគាត់ម្នាក់ហ្នឹងដែរ។ ជាទស្សនៈរបស់ខ្ញុំ ខ្ញុំយល់ថា រូបគេ រូបខ្ញុំ ខ្ញុំគិតដែរហ្នឹង អ៊ីចឹងចំពោះ ភាព ហ្នឹងខ្ញុំទុក។ ខ្ញុំអត់មានមាត់មានកទេ រហូតដល់ថ្ងៃនេះ ដែលខ្ញុំទុកជីវិតគាត់។ តែគាត់ជាចាមមួយរូបនៅស្ទឹងកែវ ភូមិចាមហ្លួង។ ប៉ុនម៉ែឪដាច់ខាត់ជាមួយខ្ញុំ គាត់យកផ្ញើ។ ហេតុនេះ ខ្ញុំទុកជីវិតគាត់ដល់ថ្ងៃនេះ។ ប៉ុនខ្ញុំនិយាយអ៊ីចឹង វាធ្វើឱ្យលោកថា អ៊ីចឹងបុគ្គលស្រឡាញ់តែម្នាក់ ចំពោះចាមដទៃនៅក្នុងស្រុក អត់មានគិត។ តែនេះជាផ្ទាល់ខ្លួនរបស់ខ្ញុំ ដែលខ្ញុំគាត់នៅជាមួយទៅហើយ អ៊ីចឹងខ្ញុំក៏ទុកគាត់ ទល់ថ្ងៃហ្នឹង។ ឥឡូវជាប្អូនថ្លៃរបស់ខ្ញុំ គាត់នៅ សព្វថ្ងៃនៅស្ទឹងកែវ ហើយអត់ស្លាប់ទេ។ នេះខ្ញុំសូមជម្រាប ដោយការស្មោះត្រង់ គឺទស្សនៈខ្ញុំគឺថាអត់មានអី ខ្ញុំគិតគាត់ អាណិតគាត់។"*

*(បញ្ចប់ការបង្ហាញឯកសារសំឡេង-រូបភាព)*

[១៤:២៨:០១]

នេះគឺជាសក្ខីកម្មដ៏សំខាន់បំផុត។ ប្រាក់ យុត បាននិយាយថា គាត់ជួយជីវិត ភាព ព្រោះថាមានតែ ភាព មួយដែលនៅសល់។ ហេតុអ្វីបានជាគាត់មិនសម្លាប់ ភាព? គឺមានហេតុផលតែមួយទេ គឺថាគេចង់សម្លាប់ ភាព ដោយសារតែហេតុផលតែមួយ គឺ ភាព ជាជនជាតិចាម។ អ៊ីចឹងគាត់ទុកតែ ភាព មួយ ហើយគាត់សម្លាប់ជនជាតិចាមផ្សេងទាំងអស់ នៅក្នុងស្រុកកំពង់សៀម។ គាត់និយាយថា គាត់ជួយ ភាព ព្រោះ ភាព មាន<សំណាងដោយនាងមាន>ទំនាក់ទំនងជាមួយលេខា<ស្រុក។> ដូច្នេះ <ភាពនៅរស់ តែចាមដទៃទៀតត្រូវកំណត់ជាគោលដៅ ហើយសម្លាប់ចោល>។

ឥឡូវនេះ ខ្ញុំនិយាយអំពីសក្ខីកម្មផ្សេងទៀត ដែលយើងបានស្តាប់ឮនៅក្នុងស្រុកកងមាស ហើយនៅក្នុងតំបន់តែមួយ គឺតំបន់៤១ ដែលនៅពេលក្រោយ<របបនោះ> តំបន់នេះត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់កម្មាភិបាលនិរតីឈ្មោះ អោ អាន ដែលជាលេខាតំបន់នោះ។ ហ៊ឹម ម៉ាន គាត់បានមកផ្តល់សក្ខីកម្ម ហើយគាត់និយាយអំពីការមកដល់របស់កម្មាភិបាលនិរតី គឺក្រុមដាវវែងហ្នឹង ទទួលបញ្ជាឱ្យចាប់ជនជាតិចាម គឺបញ្ជាពីលេខាស្រុក។ ចាមត្រូវបានគេចាប់ខ្លួន ហើយបញ្ជូនទៅវត្តអូរត្រកួន។

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហ៊ឹម ម៉ាន បានផ្តល់សក្ខីកម្មនៅថ្ងៃ១៧ កញ្ញា ២០១៥។ គាត់និយាយថា៖ “ក្រៅពីជនជាតិចាម ក៏មានប្រជាជនថ្មី និងអតីតទាហាន លន់នល់ ដែលត្រូវបានគេចាប់ឃុំខ្លួនផងដែរ។” ប៉ុន្តែយើងឃើញ <មានភស្តុតាងពី>សាក្សីក៏បានផ្តល់នូវភាពខុសគ្នាពីរ ទាក់ទងទៅនឹងការចាប់ខ្លួន ក៏ដូចជាការប្រព្រឹត្តចំពោះជនជាតិចាម<នៅតាមកន្លែងដ៏គួរឲ្យខ្លាច ដូចជានៅវត្តអូរត្រកួន ជាដើម>។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយ របស់គាត់ សុខ ម៉េងលី គឺឯកសារ E3/9654 ចម្លើយ១៣ គាត់និយាយថា ភាពខុសគ្នាចំពោះជនជាតិចាម គឺថាគ្រួសារទាំងមូលត្រូវបានគេចាប់ខ្លួនទាំងអស់។ ហើយសាក្សី ម៉ើយវណ្ណី ក្នុងសក្ខីកម្មរបស់ គាត់បាននិយាយថា ខុសពីអតីតទាហាន លន់ នល់ ឬក៏ប្រជាជនថ្មី គឺគេអត់សួរចម្លើយជនជាតិចាមនោះទេ គឺមិនចាំបាច់ត្រូវរកខ្សែបណ្តាញអីនោះទេ គឺថា ត្រូវសម្លាប់ចោលទាំងអស់តែម្តង។ ម៉ើយវណ្ណី បានផ្តល់សក្ខីកម្មថា ចាមទាំងអស់ដែលមកដល់វត្តអូរត្រកួន ត្រូវបានគេយកទៅសម្លាប់ចោល។ <គាត់ប្រាប់ថា >មានពេលមួយនោះ គេសម្លាប់ជនជាតិចាមនោះដល់ទៅ១០០នាក់ក្នុងតែមួយពេល។ នេះជាសក្ខីកម្មរបស់គាត់កាល<ថ្ងៃទី១១ ខែមករា >ឆ្នាំទៅ។ សាយ ឌឿន បានផ្តល់សក្ខីកម្មនៅថ្ងៃ<បន្ទាប់គឺថ្ងៃ>ទី១២ មករា ២០១៦។ នៅក្នុងអំឡុងពេលដែលគាត់ធ្វើជាប្រធាននៃក្រុមដាវវែង គាត់បានផ្តល់សក្ខីកម្មថា៖ “ចាមទាំងអស់នៅក្នុងឃុំពាមជីកង ត្រូវបានចាប់ខ្លួន <នៅពេល>កម្មាភិបាលភូមិភាគនិរតីមកដល់។” <យើងដឹង>ហើយ<ថា>មាន<អ្វីកើតឡើងខ្លះ នៅពេលការមកដល់របស់>កម្មា-ភិបាល<>ភូមិភាគនិរតី<។ ពួកគេទាំងនោះជាពេជ្ឈឃាដដែលមជ្ឈិមចូលចិត្ត ជាកម្មាភិបាលក្រោមបង្គាប់ តាម៉ុក ហើយជាកូនទាហានដែល ប៉ុល ពត និងមជ្ឈិមបក្សទុកចិត្តបំផុត។> សេង គុយ បានផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការថា គឺនៅថ្ងៃទី០៩ កញ្ញា ២០១៥ ថា៖ “ក្រោយពីកម្មាភិបាលភូមិភាគនិរតីមកដល់ ចាមទាំងអស់នៅក្នុងភូមិនេះ នៅឃុំអង្គរបាន ស្រុកកងមាសហ្នឹង រួមទាំងក្មេងៗដែលមានអាយុត្រឹមតែ៣ឆ្នាំ ក៏ត្រូវបានសន្តិសុខឃុំហ្នឹង ចាប់ខ្លួនទាំងអស់។” សេង គុយ បាននិយាយថា៖ “គេបានបញ្ជាឲ្យគាត់យកចាមទាំងអស់នោះ ទៅវត្តអូរត្រកួន ហើយគាត់មិនដែលបានឃើញអ្នកនោះត្រឡប់មកវិញទេ។”

[១៤:៣២:៤០]

ស្រុកទី៣ នៅលើផែនទីយើងនេះ ហើយដែលជាទឹកដីដ៏សំខាន់ កន្លែងចាមរស់នៅដ៏សំខាន់ គឺស្រុកក្រូចឆ្មារ។ យើងបានស្តាប់ឮសួរសាក្សីនិយាយអំពីព្រឹត្តិការណ៍នៅស្រុកក្រូចឆ្មារដែលកើតឡើងនៅក្នុងឆ្នាំ១៩៧៨ <ថាតើការកាប់សម្លាប់កើតឡើងច្រើនប៉ុនណា> ក្រោយកម្មាភិបាល<មកពីបស្ចិម

មកពី>ភូមិភាគនិរតី <និងមកពីមជ្ឈិម>ទៅដល់។ ហើយនៅពេលនោះ <កម្មាភិបាលទាំងនោះ>ស្ថិតនៅក្រោម<បង្គាប់> កែ ពក។ នោ សាទះ បានផ្តល់សក្ខីកម្មថា <ពេល>កម្មាភិបាលនិរតី ពេលទៅដល់ហ្នឹងគេឲ្យរៀបចំបញ្ជីជនជាតិចាម។ អ៊ីចឹងយើងក៏ឮសួរសក្ខីកម្មរបស់ ប្រាក់ យុត និង យូ វ៉ាន់ ផងដែរ<ដែលនៅក្នុងស្រុកជិតគ្នា គឺស្រុកកំពង់សៀម>។ បញ្ជីឈ្មោះនេះ គេអាចបញ្ជូនទៅដល់លេខាស្រុក <ឈ្មោះ បាន សៀក។ ម្តាយរបស់>នោ សាទះ <រួមទាំងប្អូនតូចៗ> ជីដូនមួយ ហើយនិងក្រុមគ្រួសារចាម ដទៃទៀត <ត្រូវបាន>គេយកទៅដាក់នៅក្នុងសាឡាងមួយ ដឹកចេញទៅ ហើយមិនដែលបានឃើញត្រឡប់មកវិញទេ។ វ៉ាន់ ម៉ាត់ បានផ្តល់សក្ខីកម្មថា ពីរថ្ងៃក្រោយ ប៉ុល ពត បើកអង្គប្រជុំនិយាយអំពីខ្មាំង ជនជាតិចាមជាច្រើនត្រូវបានគេបញ្ជូនទៅឃុំជីនិត ហើយមិនដែលត្រឡប់មកវិញទេ។ <គាត់ប្រាប់ថា> មាន<ជនជាតិចាម>ប្រហែលជា៤០០ ទៅ៥០០នាក់ ជនជាតិចាមនៅក្នុងក្រុមពិសេសនេះ ហើយគ្មានអ្នកណាម្នាក់រស់រានមានជីវិតទេ។ ហើយតាមរយៈសក្ខីកម្មនេះផងដែរ គឺថាឃាតករហ្នឹង គឺបានសម្លាប់ហើយ ទម្លាក់សាកសពទាំងនោះចូលទៅទន្លេមេគង្គតែម្តង។ <លោក អ៊ីសា ឧស្មាន ក៏បានលើកបញ្ហានេះ នៅក្នុងសក្ខីកម្មរបស់គាត់ដែរ ប៉ុន្តែ>លេខាស្រុក បាន សៀក ក៏បានទទួលស្គាល់ផងដែរនៅក្នុងសក្ខីកម្មរបស់គាត់ <ជាមួយ ហ្វ បានទទួលស្គាល់>ថា គាត់ឃើញខ្មោចដាច់ក្បាលបាត់ទៅអណ្តែតនៅតាមទឹកនៅពេលដែលគាត់ទៅធ្វើការនៅស្រុកក្រូចឆ្មារ។ គាត់បានផ្តល់សក្ខីកម្មថា គឺឯក-សារ E3/375 នៅក្នុងចម្លើយរបស់គាត់ជូនសហចៅក្រមស៊ើបអង្កេត <ប្រាប់ថា ">អ្នកដែលគេត្រូវសម្លាប់នោះ គេមិនទុកយូរទេ គេគ្រាន់តែវាយការណ៍ទៅថ្នាក់លើ ហើយនៅពេលដែលគេទទួលបានបញ្ជាឲ្យកម្ទេច គឺថាគេកម្ទេចចោលតែម្តង ដោយមិនបាច់សួរចម្លើយវែកមុខរកខ្សែរយៈអ្វីនោះទេ។" សាក្សី អ៊ិត សេន បានរៀបរាប់<ពីរបៀបថា>គាត់ត្រូវបានគេបញ្ជូនទៅមន្ទីរសន្តិសុខនៅក្នុងឆ្នាំ១៩៧៨ ជាមួយនឹងក្រុមគ្រួសារចាម<ប្រហែល>៥០គ្រួសារមកពីភូមិពីរ<>។ គាត់ឃើញប្រជាជនគេចងភ្ជាប់គ្នា <មាន៣០នាក់ក្នុងមួយក្រុម> ហើយគេអូសចូលទៅក្នុងស្ទឹង ទម្លាក់ឲ្យលង់ទឹកស្លាប់នៅក្នុងទន្លេ។ សុះ រំលី បានផ្តល់សក្ខីកម្មថាមានយុវជន <និងកុមារ>ចាម៥០០ទៅ៦០០នាក់ហ្នឹង <>ត្រូវបានគេយកចេញមកពីភូមិទ្រា នៅក្នុងតែរយៈពេល១០ថ្ងៃ ក្នុងឆ្នាំ១៩៧៨ <ក្រោយមក គេយកពួកគេមកកាន់ស្ទឹងនេះដែរ>។ អះម៉ាត់ សហ្វី ហើយនិង នោ សាទះ <ទាំងពីរនាក់>ក៏បានផ្តល់សក្ខីកម្មថា <ពួកគេក៏បានត្រូវគេនាំមកកាន់>ស្ទឹង<នេះដែរ ស្ថិតនៅ>ភូមិទ្រាន។ <ក្នុងក្រុមហ្នឹង មាន> ក្មេងស្រីៗ<>ប្រហែលជា៣០នាក់ <បាន>រស់រានមានជីវិត<ដោយពួកគេប្រាប់ បាន សៀក, ហ្វ ថា ពួកគេជាជនជាតិខ្មែរ>។

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

<ពួកគេមិនបាននិយាយភាសាដែលមានតុងសំឡេងនោះទេ នៅពេលនោះ គេជាប់ដោយនិយាយភាសាខ្មែរ ហើយគេ>មិនស្លៀកសម្លៀកបំពាក់<បុរាណអីដែរ។ បើសិនជាមានក្មេងស្រីណាមួយឆ្លើយថា ខ្លួនគេជាចាម អ្នកនោះនឹងត្រូវនាំទៅសម្លាប់ភ្លាម។>

លោក លោកស្រីចៅក្រម <ប្រហែល>មុនពេលឈប់សម្រាក ខ្ញុំសូមចាក់បញ្ចាំងខ្សែវីដេអូខ្លីមួយប្រហែលជា៦នាទី។ <ជាថ្មីម្តងទៀត >ខ្សែវីដេអូនេះនិយាយអំពីសក្ខីកម្មរបស់ជន<រងគ្រោះជាជន>ជាតិចាម <ដែលបានចូលមកធ្វើសក្ខីកម្ម> ពាក់ព័ន្ធទៅនឹងរឿងរ៉ាវទាំងមូលតែម្តង។ <ខ្ញុំមិនដឹងថា តើលោកចៅក្រមចង់សម្រាកឥឡូវ ឬយ៉ាងណានោះទេ ប៉ុន្តែ ខ្ញុំចង់ចាក់បញ្ចាំងវីដេអូនេះសិន តើបានទេលោកប្រធាន?> បើសិនណាជាលោកប្រធានសម្រេច<ថាបាន> -- អ៊ីចឹងសូមការចាក់បញ្ចាំងវីដេអូលេខ៧។ <សូមអរគុណ។>

[១៤:៣៧:០០]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"របបខ្មែរក្រហមឲ្យហូបសាច់ជ្រូក អ្វីៗដែលខ្មែរអាចធ្វើទៅបាន គឺឲ្យជនជាតិធ្វើតាមទាំងអស់។ នេះហើយហៅថា ការលំបាកវេទនា អាហារក៏គ្មាន សាសនាក៏គ្មាន អ្វីៗក៏គ្មាន។ ឪពុកខ្ញុំស្លាប់ដោយសារមូលហេតុគាត់ជាជនជាតិចាម គាត់កាន់សាសនាអ៊ីស្លាម។ ហើយគាត់គឺជឿជាក់ទៅលើសាសនាគាត់ មិនធ្វើតាមអង្គការកំណត់។ ពេលនោះគេយកសាច់ជ្រូកមកឲ្យគាត់ពិសា តែគាត់មិនព្រមទេ។ អ៊ីចឹងអង្គការបានដាក់ផែនការឲ្យគាត់ បើមិត្តមិនហូបសាច់ជ្រូកទេ អង្គការមានសាច់ជ្រូកឲ្យមិត្តហូប ហើយបើមិត្តមិនហូបទេ អង្គការមិនដឹងជារកអ្វីឲ្យមិត្តឯងហូបទេ។ អ៊ីចឹងហើយពេលនោះ ឪពុកខ្ញុំគាត់ហូបតែទឹក។ ខ្ញុំដើយឆ្ងល់ដែរ ហេតុអ្វីបានជាគេដាក់ខ្នាំងចាមនេះ ខ្នាំងទី១នេះ ខ្ញុំដើយឆ្ងល់ទាល់សព្វថ្ងៃនេះបាទ។ ខ្ញុំមិនដឹងរឿងរ៉ាវអាថ៌កំបាំងរបស់គេទេ។ ដាក់ខ្នាំងចាមខ្នាំងទី១។ នេះវាឃើញរូបភាពហ្នឹង ក្រោយពីហ្នឹងមក ឃើញចាមយ៉ាប់យឺនគេយកទៅសម្លាប់។ វាវ៉ៃពួកជនជាតិ។ ម៉េចក៏ខ្ញុំមកនៅនេះខ្ញុំដឹង វានៅក្បែររណ្តៅប្រហែលជា១០០ម៉ែត្រហ្នឹង។ បាទ ម៉េចក៏ខ្ញុំដឹងបាននៅដល់១០០ម៉ែត្រ។ បានជាដឹង ឮសម្រែក បាទ ខ្ញុំនៅក្រាបជាមួយប្រពន្ធខ្ញុំហ្នឹង ឮសម្រែក គ្រាន់ថាវ៉ៃហ្នឹងក៏ឮដែរ ឮសម្រែកថាអល់ឡោះ ប៉ូយអើយ! អូម៉ាយហ្គុក អាណេះ ប៉ូយអើយ ស្រែកហៅអល់ឡោះ។ ចំណែកយោធាវិញ វាសម្លាប់ណា វាៗចងខ្សែជាប់ហ្នឹងស្នូលនោះ វាបណ្តែតទឹកទុំងហើយ មួយស្នូលៗ មិនដឹងជាប៉ុន្មាននាក់ទេ។ បើកុមារវិញអាយុ១ឆ្នាំ ឬមួយ៦ខែ អីវាច្រកបាវ វាចងរួចវាទម្លាក់ទឹក និយាយពីអណ្តែតឡើងស្ពឹង*

*ៗ។ រួចជួបហេតុការណ៍ជាមួយ បងៗថូ ហ្នឹងក្រូចឆ្មារ អ៊ូ នៅខ្សាច់ប្រឆេះក្រោម គាត់អ្នកធ្វើការនៅខាងយុវជនឃុំ នៅខាងសហករណ៍កាលនៅអាពតហ្នឹងណា ថាអាពតទៅចុះ។ រួចឃើញគាត់ហ្នឹងអណ្តែតទឹក វាអារក ហ្នឹងឃើញដាច់អានេះហើយ ឡើងចំហ រួចនៅអណ្តែតអ៊ីចឹង។ រួចអណ្តែតគាត់ហ្នឹង ដឹងយ៉ាងម៉េចទេ វាចេះតែវិលទៅវិលមក វិលទៅវិលមក អត់ទៅចុះក្រោមទេ វាហូរឡើងលើទៅវិញទៅ វាចុះក្រោមទៅ វាហូរឡើង ដូចថាឡើងចុះ ឡើងចុះ ដូចថាវិញ្ញាណមនុស្សហ្នឹង វាអត់ចង់ទៅណាទេ ចង់នៅតែកន្លែងហ្នឹងហើយយ៉ាង មើលទៅនោះ។*

[១៣:៤០:១៧]

*កងទ័ពហ្នឹងកំពុងតែសម្លាប់ កំពុងតែសម្លាប់ថ្ងៃហ្នឹង ខ្ញុំទៅដល់ផ្ទះហ្នឹង ថ្ងៃហ្នឹងកំពុងសម្លាប់។ យកកាណូតចងៗកន្ទុយកាណូត ពួរៗធំ ពួរធំនោះគេចងដៃ(ឮមិនច្បាស់)គេដោត ពួរហ្នឹងយោងកាណូតទៅក្នុងទឹកតែហ្នង ចងៗប្រុសៗហ្នឹង យោងកាណូតទៅ ពាក់ ស្រាយពួរ កណ្តាលទន្លេ ស្រាយពួរចោលមកយកទៀត។ ថ្ងៃហ្នឹងធ្វើទាល់ល្ងាច។ ខ្ញុំលើ ចងលើនៅលើផ្ទះហ្នឹងមួយថ្ងៃ ទាល់ល្ងាច ទៅមក ទៅមក សម្រុកយកមនុស្សចងកន្ទុយៗកាណូតទៅ ចងដៃដោតពួរទៅ។ ពួកខ្ញុំយំគ្រប់គ្នានៅលើផ្ទះហ្នឹងចងដាក់លើផ្ទះហ្នឹង ឃើញយំ។ បាទ លោកអ្នកឆ្លើយថាចាមហ្នឹង ហើយនិងកូនកាត់ហ្នឹង អ្នកហ្នឹងបានចុះទៅហើយ ចុះទៅម្តងពីរនាក់ ម្តងពីរនាក់ គេហៅទៅហូបបាយនៅខាងក្រោមហ្នឹង គេយកទៅសម្លាប់ចោលហ្នឹងហើយ។ តែពួកក្នុងរយៈកាលជា១០នាក់ខ្ញុំ ប្រហែលជា -- មើលពីរដណ្តប់ បីដណ្តប់នាក់ហ្នឹង ពួកខ្ញុំហ្នឹងហើយប្រាប់ថាខ្មែរនៅហ្នឹង ចងចំណងនៅជាប់ដៃ តែគេអត់ទាន់យកទៅ គេយកទៅតែអ្នកស្រែកថាខ្ញុំហ្នឹងកូនកាត់ ហើយខ្ញុំហ្នឹងចាម ហ្នឹងគេយកទៅ។”*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៤:៤១:៤៨]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះ រហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤១ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:០៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីបន្តការធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួន។

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន។ ដើម្បីជាកំណត់ត្រា ខ្ញុំសូមផ្តល់ឈ្មោះ ហើយនិង<កាលបរិច្ឆេទនៃសក្ខីកម្មដែល>មាននៅក្នុងវីដេអូដែលខ្ញុំបង្ហាញនោះ។ <រូបដំបូងឈ្មោះ ម៉ី ពៅ> ផ្តល់សក្ខីកម្មថ្ងៃ២៩ កុម្ភៈ ២០១៦។ ទី២ គឺ ហ៊ឹម ម៉ាន ២៨ កញ្ញា ២០១៥ ហើយនិងមួយទៀតគឺថ្ងៃ១៧ កញ្ញា ២០១៥។ ម្នាក់ទៀតគឺ នោ សាទះ នៅថ្ងៃ២៨ កញ្ញា ២០១៥។ <អ៊ីត សេន> ថ្ងៃ០៧ កញ្ញា ២០១៥ ហើយនិងចុងក្រោយបំផុត គឺ អះម៉ាត់ សហ្វីយ៉ាស់ ហៅ ម៉ាត់ ស គឺថ្ងៃ១៣ មករា ២០១៦។

លោក លោកស្រីចៅក្រម ខាងព្រះរាជអាជ្ញា <មិនដែល>តម្រូវឲ្យបង្ហាញអំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍<ដើម្បីបង្ហាញ>ថា <>ខ្មែរក្រហមត្រូវតែសម្លាប់គ្រប់ជនជាតិចាមទាំងអស់នោះ<ទេ>នៅក្នុងប្រទេសកម្ពុជា<>ប៉ុន្តែអ្វីដែល<តម្រូវឲ្យធ្វើគឺស្វែងរកចេតនា>បំផ្លាញក្រុមទាំងមូល ឬក៏ដោយផ្នែក<ដូចអ៊ីចឹង>។ ភាសាអង់គ្លេសគេហៅថា "អះសាច់" ចំណែកភាសា<បារាំង គឺ> "*កំ អេតាល*" <ហើយភាសា>ខ្មែរ<មានន័យថា> "ដូចជា" ជាដើមគឺ "ដូចជា" ដូច្នេះគឺមានន័យថា គឺកម្ទេចអត្តសញ្ញាណរបស់ក្រុម។ <នេះគឺជាអ្វីដែលពាក្យ អំពើប្រល័យពូជសាសន៍ ត្រូវបានគេបង្កើតឡើងមិនត្រឹមតែ>ការការពារបុគ្គលណាមួយទេ ប៉ុន្តែការពារជាក្រុម<ផង>។ <មានភាពចម្រូងចម្រាសស្រដៀងគ្នានឹងពាក្យ "បំផ្លាញ"។> វាមានសៀវភៅ<មួយចំនួន ហើយក៏មានពាក្យប្រើក្នុងតុលាការក្នុងសំណុំរឿងនានា >ដែលតុលាការបាននិយាយថា ពាក្យ "កម្ទេច<ឬបំផ្លាញ>" ហ្នឹងមានន័យថា ជាការកម្ទេចផ្លូវកាយ ឬក៏ផ្លូវចិត្ត ប៉ុន្តែ<ដូច>ក្នុងសាលក្រម<គ្រីស្ទីកដែរ លើកឡើងថា ការជម្លៀស> ស្ត្រី ឬក៏ក្មេងៗ <ចេញពី *ស្រេប្រេនីកា* គឺជាចេតនាកម្ទេចក្រុមនោះហើយ។ វាច្បាស់លាស់ដែរថា គ្រាន់តែ> ជម្លៀស មិនមែន<មានន័យថា>សម្លាប់<រាងកាយ>នោះទេ<។ យើងបានលើកឡើងយ៉ាងពិស្តារនៅក្នុងសារណាបញ្ចប់ការពិភាក្សាដេញដោលរបស់យើង ប៉ុន្តែយើងយល់ថា វាមិនស៊ីគ្នាទៅនឹងពាក្យប្រើក្នុង>អនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍<នោះទេ ដែលពាក្យកម្ទេចមានន័យថា គ្រាន់តែសម្លាប់ប៉ុណ្ណោះ គឺបំផ្លាញ ឌី.អិន.អេ របស់សមាជិកក្រុមមួយ។ បើយើងត្រឡប់មកមើលនិយមន័យវិញ យើង

E1/522.1

នឹងឃើញពីវិធីដែលគេអនុវត្តអំពើប្រល័យពូជសាសន៍។> មានសកម្មភាពមួយក្នុងចំណោមសកម្មភាពទាំងប្រាំហ្នឹង គឺ<ជម្លៀសក្មេងៗនៅក្នុងក្រុមនោះ។ បើគេជម្លៀសក្មេងៗ មិនសម្លាប់ក្មេងទេ អ៊ីចឹង ឌី.អិន.អេ របស់ពួកគេនៅតែមានជីវិត។ ប៉ុន្តែ បើសិនណាយើងដកក្មេងៗទាំងនោះ>ចេញពីក្រុមហ្នឹង <បង្រៀនពួកគេភាសាមួយទៀត ទំនៀមទម្លាប់ផ្សេង ក្រុមនោះនឹងលែងមានទៀតទេ។ ជាឧទាហរណ៍ បើសិនណា យកក្រុមក្មេងៗខ្មែរលើពីភាគឦសាននៃប្រទេស ហើយ>បញ្ជូនក្មេងហ្នឹង<ទៅផ្នែកផ្សេងទៀត ក្នុងប្រទេសកម្ពុជា ឬទីក្រុងភ្នំពេញ ចេញពីភូមិភាគឦសាននោះ។ អ៊ីចឹង ក្រុមនោះ ក្នុងជំនាន់ក្រោយមកទៀត នឹងលែងមានទៀតហើយ បើសិនណា ពួកគេធំឡើងមិនបាននិយាយភាសារបស់ខ្លួន មិនស្គាល់ទំនៀមទម្លាប់របស់ខ្លួន ឬជំនឿសាសនា។> ដូច្នេះក្នុងករណីនេះ គ្មានការសម្លាប់ទេ ប៉ុន្តែវាបានធ្វើឱ្យកម្ទេច ធ្វើឱ្យបំបាត់នូវអត្តសញ្ញាណ។ ដូច្នេះ គេសម្លាប់តែអ្នកណាដែលបដិសេធមិនព្រមគោរពតាមប៉ុណ្ណោះ។ <ក្នុងករណីនេះ មានការបញ្ជាក់យ៉ាងច្បាស់ថា ការសម្លាប់កើតឡើងមែន មានការចោទប្រកាន់ ដោយមានចេតនាកម្ទេចជនជាតិចាម ដែលបដិសេធលះបង់អត្តសញ្ញាណរបស់ខ្លួន។ ការសម្លាប់ផ្តោតសំខាន់នៅតាមទីកន្លែង ដែលចាមអាចរស់នៅ គឺមាននៅក្នុងស្រុកទាំងបី ជាពិសេសនៅតាមដងទន្លេមេគង្គ។> ហើយពួកគេក៏ផ្តោតគោលដៅជាពិសេសទៅលើមេដឹកនាំសាសនា ហើយនិងអ្នកដែលបដិសេធមិនគោរពទៅតាមការបញ្ជារបស់គេឱ្យបោះបង់សាសនានោះដែរ។

[១៥:០៥:៣៨]

ដូច្នេះ ខ្ញុំសូមបង្ហាញហួសពីវិមតិសង្ស័យថា អំពើប្រល័យពូជសាសន៍ទៅលើជនជាតិចាម ពិតជាបានលើកឡើង ហើយពួកគេមានគោលដៅដើម្បីកម្ទេចទាំងស្រុង ឬក៏ផ្នែកទៅលើក្រុមជនជាតិចាម។ សាក្សីមួយរូបទៀត បានមកផ្តល់សក្ខីកម្មនៅទីនេះដែរ គឺជាអ្នកភូមិជនជាតិខ្មែរម្នាក់ ប៉ុន្តែគាត់បានសង្ខេបយ៉ាងល្អ អំពី<ប្រវត្តិ>គោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ <ហើយនឹងផលប៉ះពាល់គោលនយោបាយនោះមកដល់> សេង គុយ។ គាត់មកពីភូមិភាគកណ្តាល។ ហើយគាត់បានប្រាប់តុលាការថា ក្រោយពេលខ្មែរក្រហមគ្រប់គ្រងតំបន់<នោះ> ជនជាតិចាមត្រូវបានគេបញ្ចូលជាមួយប្រជាជនខ្មែរ។ សម្លៀកបំពាក់ ជំនឿសាសនាត្រូវបាន<លុបបំបាត់>នៅពេលនោះ ហើយជនជាតិចាមទាំងអស់នោះ បានក្លាយទៅជាជនជាតិខ្មែរ។ គាត់បានផ្តល់សក្ខីកម្មថា នៅក្នុងឆ្នាំ៧៧ <រឿងរ៉ាវមានការផ្លាស់ប្តូរ។ >ជនជាតិចាមត្រូវបានគេចាប់ខ្លួនហើយ បញ្ជូនទៅវត្តអូរត្រកួនដើម្បីសម្លាប់ចោល។ ហើយគាត់ពន្យល់ថា ហេតុផល<ចំពោះគោលនយោបាយទាំងនេះ។ គាត់ប្រាប់ថា> បក្សកុម្មុយនីស្ត

កម្ពុជាមិនចង់ឲ្យមានប្រជាជនចាម ឬក៏ជាតិសាសន៍ដទៃទៀត គឺគេគ្រាន់តែចង់ឲ្យមានពូជសាសន៍តែមួយប៉ុណ្ណោះ។ ដូច្នេះ គឺគេសម្លាប់ដើម្បីកម្ទេចពូជសាសន៍ ឬក៏ក្រុមសាសនាចាមនេះឯង។

ឥឡូវនេះ ខ្ញុំសូមបន្តទៅផ្នែកបន្ទាប់ គឺនិយាយ<ត្រួសៗ>អំពីជនជាប់ចោទ។ ខ្ញុំ នៅក្នុងកំណត់ត្រារបស់ខ្ញុំ ខ្ញុំ<ដាក់ចំណងជើងដោយខ្លួនឯង>ថា“ជើងកាងទាំងបីរូប”។ <ខ្ញុំនឹងពន្យល់ហេតុផលបន្តិចទៀតនេះ។> ខ្ញុំនឹងនិយាយអំពីឧក្រិដ្ឋកម្មមួយៗ ដែលថាជនជាប់ចោទមានការពាក់ព័ន្ធទៅនឹងគោលនយោបាយ ហើយដូចជាសហការីខ្ញុំក៏បាននិយាយរួចហើយ អំពីការដាក់ទៅជាទាសករ ការរៀបការដោយបង្ខំ និយាយអំពីតួនាទីរបស់ជនជាប់ចោទ<លើ>គោលនយោបាយ<ទាំងនេះ>។ ហើយខ្ញុំនឹងចំណាយពេលវេលាពីរបីនាទី ដើម្បីនិយាយអំពីតួនាទីរបស់ជនជាប់ចោទជាទូទៅ។ <យើងមិនចាំបាច់មន្ទិលទេ> នៅថ្នាក់កំពូលរបស់បក្សកុម្មុយនីស្តកម្ពុជា គឺជារបបផ្តាច់ការ គឺគ្មានការបោះឆ្នោត គ្មានការជ្រើសរើស<ពួកគេ>ឡើយ<។ ពួកគេឡើងកាន់អំណាចដោយសារការច្បាំងគ្នា ដោយប្រើកម្លាំង និងល្បិចបោកប្រាស់ ធ្វើពុតថាខ្លួនចូលរួមជាមួយរណសិរ្ស សីហនុ> លាក់បាំង<គោលលទ្ធិ សូម្បី>អត្តសញ្ញាណ<កុម្មុយនីស្តរបស់ខ្លួន>រហូតដល់ឆ្នាំ៧៦ ទើបបង្ហាញ។ គឺពេលនោះ គេបន្លំថាមាន<ការបោះឆ្នោតជ្រើសរើស>សភា <ដឹកនាំដោយ នួន ជា>។ <តើក្នុង>បរិយាកាស<បែបហ្នឹង តើគេសម្រេចដូចម្តេច?>

[១៥:០៨:៣៤]

ខៀវ សំផន <ប្រាកដជា>ដឹងច្បាស់អំពីការណ៍នេះ ហើយគាត់និយាយនៅក្នុងសៀវភៅរបស់គាត់ <មានចំណងជើងថា “ការពិចារណាប្រវត្តិសាស្រ្តកម្ពុជា”>។ គាត់បាននិយាយថា៖ “<នៅក្នុងរដ្ឋកុម្មុយនីស្ត> សេចក្តីសម្រេចទាំងអស់ ត្រូវបានធ្វើឡើងនៅក្នុងក្របខ័ណ្ឌថ្នាក់ដឹកនាំមជ្ឈិម ហើយការអនុវត្តគោលនយោបាយនោះ ត្រូវបានធ្វើឡើងដោយបុគ្គលដូចៗគ្នា។ ខ្មែរក្រហមមានគោលនយោបាយ។ ពួកគេគោរពទៅតាមសេចក្តីសម្រេចរបស់បក្សកុម្មុយនីស្តកម្ពុជា។”<លោក លោកស្រីចៅក្រមមិនចាំបាច់សួរទេ> ដូចជាអង្គភាពនានា គឺមានថ្នាក់លើដែលចេញបញ្ជា ហើយថ្នាក់ក្រោមជាអ្នកអនុវត្តនិងគោរពទៅតាមបញ្ជា ហើយមានវិធានការមួយចំនួនសម្រាប់ថ្នាក់ក្រោម ដែលត្រូវធ្វើ<តាម>។ ដូច្នេះគឺបានន័យថា សេចក្តីសម្រេចទាំងអស់មិនមែនសុទ្ធតែសម្រេចដោយថ្នាក់លើនោះទេ។ ប៉ុន្តែ<នេះមិនមែនមានន័យថា> ខៀវ សំផន ហើយនិង នួន ជា មិនអាចគេចផុតពីការទទួលខុសត្រូវចំពោះគោលនយោបាយដែលពួកគេបង្កើត ហើយមិនអាចគេចផុតពីឧក្រិដ្ឋកម្មដែលទាក់ទង ឬក៏ដែលបណ្តាលមកពី

គោលនយោបាយនោះឡើយ គឺមិនអាចគេចផុតពីហេតុការណ៍ទាំងអស់នេះបានទេ។

[១៥:០៩:៥១]

លក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជា E3/214 បានបញ្ជាក់ថា "ប្រភេទទាំងបីនៃកងទ័ពបដិវត្តន៍កម្ពុជា គឺកងទ័ពទូទៅ កងទ័ពឈ្លប ហើយនិងកងទ័ពតំបន់ត្រូវតែស្ថិតក្រោមការគ្រប់គ្រងផ្ដាច់មុខរបស់បក្សកុម្មុយនីស្តកម្ពុជា។" ប្រសិនបើយើងមើលឯកសារ E3/12 <មានសេចក្ដីសម្រេចមួយ ដែលយើងដឹង ប៉ុន្តែ>ខ្ញុំអនុញ្ញាតបង្ហាញនៅលើអេក្រង់<ឲ្យសាធារណជនទស្សនា>។ នេះគឺជាសេចក្ដីសម្រេចរបស់មជ្ឈិម របស់ ប៉ុល ពត ហើយនិង នួន ជា គឺនៅថ្ងៃ៣០ មីនា ៧៦ គឺនិយាយអំពីសិទ្ធិក្នុងការកម្ទេចក្នុងជួរ និងក្រោយជួរ។ យើងដឹងអំពីសិទ្ធិសម្រេចកម្ទេចក្នុងជួរ និងក្រោយជួរបក្សនេះ គឺគោលដៅ "<មានក្របខ័ណ្ឌ និងការអនុវត្តដាច់ខាតសម្រាប់>បដិវត្ត<យើង ដើម្បី>ពង្រឹងប្រជាធិបតេយ្យសង្គមនិយម ហើយសំខាន់បំផុតគឺពង្រឹងអំណាចរដ្ឋរបស់យើង។" <សេចក្ដីសម្រេចនេះលើកឡើងថា សិទ្ធិសម្រេចក្នុងការសម្លាប់ យោងតាមក្របខ័ណ្ឌ សម្រេចដោយគណៈភូមិភាគ > ហើយចំពោះមន្ទីរមជ្ឈិម សម្រេចដោយគណៈមន្ទីរមជ្ឈិម <ហើយនៅតាមតំបន់ឯករាជ្យមួយចំនួនសម្រេចដោយគណៈអចិន្ត្រៃយ៍ និងសេនាធិការយោធា>។ ដូច្នេះ នួន ជា ខៀវ សំផន មិនអាចគេចផុតពីការទទួលខុសត្រូវ ដែលថាមានការសម្លាប់នោះធ្វើឡើងដោយថ្នាក់ក្រោមនោះទេ <ដោយពួកគេអនុញ្ញាតឲ្យសម្លាប់ ហើយការសម្លាប់ទាំងនេះធ្វើទៅតាមគោលនយោបាយរបស់អង្គការមជ្ឈិម>។ ហ្វីលីព ស្ប៊ត បានផ្តល់សក្ខីកម្មនៅថ្ងៃ០៨ ឧសភា ២០១៣ ថាវាមិនអាចនោះទេ ដែលមេបញ្ជាការភូមិភាគធ្វើឡើងខុសពីគោលនយោបាយរួម ដែលបានដាក់ដោយមជ្ឈិមនោះ គាត់បានប្រាប់មេធាវីការពារក្ដី<នៅពេលនោះ>ថា "យើងមិនមែននិយាយជាមួយនឹងកងកម្លាំងដែលមានទំហំតូចតាចនោះទេ ប៉ុន្តែជាកងកម្លាំងដែលមានទំហំធំ <ដែលគេគ្រប់គ្រងយ៉ាងតឹងរ៉ឹង>។" <លោក លោកស្រីចៅក្រម មេដឹកនាំ>មជ្ឈិមបានដាក់នូវគោលនយោបាយ<ឧក្រិដ្ឋកម្ម>នេះ <បួនចំណុច។ ទី១> គេចេញបញ្ជានិងសេចក្ដីសម្រេច។ ទី២ តាមរយៈសុន្ទរកថា ឬក៏ការបណ្ដុះបណ្ដាល ដែលមានសាក្សីជាច្រើន និយាយថាកម្មាភិបាលតំបន់ ឬក៏កម្មាភិបាលមូលដ្ឋានបានមកចូលរួមវគ្គប្រជុំ<នៅទីក្រុងភ្នំពេញ> ដូចជាវគ្គប្រជុំដែលដឹកនាំដោយ ខៀវ សំផន នួន ជា ជាដើមនោះ។ ហើយទី៣ គឺតាមរយៈមធ្យោបាយដ៏សំខាន់មួយ គឺគេបង្កើត ដាក់ចេញនូវគោលនយោបាយតាមរយៈឧទាហរណ៍។ គឺថាមានកន្លែងដែលបង្កើតជាឧទាហរណ៍ដ៏ល្អបំផុត គឺ ស-២១ ជាកន្លែងមន្ទីរសន្តិសុខ<មជ្ឈិម> ដែលបង្ហាញថា សូម្បីតែអ្នកដែលស្និទ្ធបំផុតនឹងមេដឹកនាំដូច

ជា ប៉ុល ពត, នួន ជា, ខៀវ សំផន ក៏ត្រូវបានយកទៅសម្លាប់នៅទីនោះដែរ។ ហើយការសម្លាប់ហ្នឹង ក៏ត្រូវបានគេធ្វើឡើងនៅភ្នំពេញផងដែរ គឺក្រោយ<ថ្ងៃរំដោះ ១៧ មេសា ពេលដែលអតីតសមាជិក ថ្នាក់ដឹកនាំយោធា ក្នុងរបបចាស់ ត្រូវបានប្រមូលផ្ដុំ និងកម្ទេចនៅទីនោះ>។

[១៥:១៣:២៨]

គឺថាដូចជាសុភាសិតខ្មែរ “ជើងក្រោយតាមជើងមុខ”។ <មេដឹកនាំមជ្ឈិមបានធ្វើជាឧទាហរណ៍ដ៏ច្បាស់ក្រឡែត ដោយដាក់ចេញ>គោលនយោបាយ<សាហាវព្រៃផ្សៃ និងឃោរឃៅ> ហើយថ្នាក់ក្រោមជាអ្នកគោរពតាម។ ហើយសំខាន់បំផុតគឺគេបញ្ជាក់ថា <គោលនយោបាយនេះត្រូវតែអនុវត្តដោយ>គេសម្លាប់<អ្នកណាដែលគាំទ្រមាគ៌ាមិនសូវដាច់ខាត> ឧទាហរណ៍ដូចជាការសម្លាប់ ហ៊ូ យន់ ជាដើម។ យើងបានឃើញនៅក្នុងសារទូរលេខដែលខាងតំបន់រាយការណ៍ភូមិភាគ ភូមិភាគរាយការណ៍ទៅមជ្ឈិម ហើយមជ្ឈិមបានផ្ដល់សេចក្ដីណែនាំត្រឡប់មកវិញ។ <យើងឃើញកម្មាភិបាលថ្នាក់ភូមិភាគ ថ្នាក់តំបន់ ថ្នាក់ស្រុក សូម្បីថ្នាក់ឃុំ ក៏បានមកចូលវគ្គសិក្សារៀនសូត្រនៅទីក្រុងភ្នំពេញដែរ។ យើងដឹងហើយថា មេដឹកនាំកំពូលគឺ ប៉ុល ពត> ប៉ុន្តែ<>ខៀវ សំផន បានប្រាប់តាមវិទ្យុនៅក្នុងឆ្នាំ២០០៧ <ថា “>ប៉ុល ពត <តាមប្រមាញ់> ហើយចាប់ខ្លួន<មនុស្ស ដោយមានការចូលរួមពីគណៈអចិន្ត្រៃយ៍ផងដែរ។> គាត់មិនដែលធ្វើអ្វីតែម្នាក់ឯងនោះទេ។” <>ខៀវ សំផន ដឹងច្បាស់ ព្រោះគាត់ចូលរួមជាទៀងទាត់នៅក្នុងកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ <ដូចដែលយើងបានឃើញតាមឯកសារសេសសល់ពីជំនាន់នោះ>។ ហើយអ្វីដែលសំខាន់បំផុតនោះគឺថា ខៀវ សំផន រួមជាមួយ នួន ជា ពួកគេគឺជាដៃជើងជិតស្និទ្ធបំផុតរបស់ ប៉ុល ពត ហើយខ្ញុំចង់បញ្ជាក់ឲ្យបានច្បាស់ គឺយើងមិនចង់និយាយថាពួកគេក្នុងក្រុម<ស្និទ្ធស្នាលបំផុត របស់ ប៉ុល ពត>នោះទេ ព្រោះថាភស្តុតាងបានបង្ហាញលើសពីចំណុចនេះទៅទៀត គឺបង្ហាញថា<ក្នុងមជ្ឈិមបក្ស មាន> ប៉ុល ពត <>នួន ជា ហើយនិង ខៀវ សំផន <ជាជើងកាងទាំងបី។ ពួកគេ> គឺជាចំណុចស្នូលដែលធានាថាគោលនយោបាយរបស់ ប៉ុល ពត ត្រូវបានអនុវត្ត<នៅតាមភូមិភាគ និងកន្លែងនានា ដោយស្វែងរកសត្រូវគោលដៅដែលជាអ្នកអាចប្រឆាំងនឹងការគ្រប់គ្រងរបស់ខ្លួន ហើយយកអ្នកទាំងនោះទៅសម្លាប់ដោយសាមញ្ញប៉ុណ្ណោះ>។ <>

[១៥:១៥:៤៧]

នួន ជា ហើយនិង ខៀវ សំផន នៅជាមួយ ប៉ុល ពត រហូតៗដល់ពេលដែល ប៉ុល ពត ត្រូវបានចាប់ខ្លួន ហើយនិងស្លាប់នៅពេលក្រោយ។ <ពួក>គេតែងតែគាំទ្រគោលនយោបាយរបស់ ប៉ុល ពត

ហើយពួកគេមិនដែលប្រឆាំងជាមួយ ប៉ុល ពត នៅក្នុងរបបនោះឡើយ សូម្បីតែក្រោយរបប ក៏គេមិនដែលចោទប្រកាន់<> ប៉ុល ពត ដែរគឺគេនៅតែគាំទ្រ កោតសរសេរអំពី ប៉ុល ពត ពួកគេតែងតែស្មោះត្រង់ជាមួយ ប៉ុល ពត។ ហើយពួកគេការពារគ្នាទៅវិញទៅមក។ នួន ជា ការពារ ខៀវ សំផន ដូចដែលយើងឃើញច្បាស់ហើយ នៅពេលដែលមានចម្លើយសារភាពឆ្លើយដាក់ ខៀវ សំផន, នួន ជា បញ្ជាឲ្យលុបចោល។ ភស្តុតាងបានបង្ហាញថា ពួកគេទាំងបីនោះគឺជើងកាងទាំងបីហ្នឹង ពួកគេរស់ជាមួយគ្នា ធ្វើការជាមួយគ្នា ហូបចុកជាមួយគ្នា។

ហើយឥឡូវនេះ ខ្ញុំសូមបង្ហាញនូវវីដេអូទី១ ជាវីដេអូដែលបានផ្តល់នៅក្នុងសក្ខីកម្មរបស់ ភី ភួន ផងដែរ។ គឺឯកសារវីដេអូមានចំណងជើងថា កម្ពុជាឆ្នាំសូន្យ ឯកសារ E3/2346R។ យើងឃើញគឺពួកគេទាំងបីនាក់ ប៉ុល ពត, នួន ជា, ខៀវ សំផន អានផែនទី ហើយ ភី ភួន បាននិយាយថា នេះគឺជានៅពេលដែលគេត្រៀមរៀបចំវាយប្រហារចុងក្រោយទៅលើទីក្រុងភ្នំពេញ។ ភី ភួន គឺជាសន្តិសុខ និងនីរសាររបស់ ប៉ុល ពត ដូច្នេះគាត់ដឹងអំពីការរស់នៅរបស់ ប៉ុល ពត <យ៉ាង>ច្បាស់។ គាត់បានផ្តល់សក្ខីកម្មថា ប៉ុល ពត ហូបបាយព្រឹក បាយថ្ងៃត្រង់ជាមួយ នួន ជា ហើយនិង ខៀវ សំផន ហើយពួកគេធ្វើការជាមួយគ្នារហូត។ ហើយគាត់បានបញ្ជាក់ថាក្រោយថ្ងៃ១៧ មេសា ៧៥ គឺគាត់ឃើញពួកគេទាំងបីនៅជាមួយគ្នារហូតទាំងយប់ទាំងថ្ងៃ ទាំងនៅក្នុងស្ថានីយ៍រថភ្លើង ក៏ដូចជានៅក្រសួងពាណិជ្ជកម្ម <ពេលគេប្តូរទៅទីនោះ>។ មិនមែនមានតែ ភី ភួន ទេដែលនិយាយ<រឿងនេះ> សូម្បី ខៀវ សំផន នៅក្នុងកិច្ចសម្ភាសន៍ក៏គាត់និយាយថា ចំពោះការរស់នៅប្រចាំថ្ងៃ ប៉ុល ពត ហើយនិង នួន ជា ហូបបាយជាមួយខ្ញុំ យើងហូបបាយជាមួយគ្នា យើងមិនដែលធ្វើអ្វីនៅដាច់ពីគ្នាឡើយ <ក្នុងឯកសារ E3/3118។> នួន ជា បានអះអាងដូចគ្នាផងដែរ នៅពេលដែលគាត់សម្ភាសជាមួយ ថេត សម្បត្តិ និងក្នុងសៀវភៅរបស់គាត់ <មានចំណងជើងថា "នៅក្រោយវាលពិឃាត" >ដែលគាត់និយាយថា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពួកគេទាំងបី ខៀវ សំផន, ប៉ុល ពត និង នួន ជា គឺហូបបាយរួមគ្នាជាទូទៅ។ សួង ស៊ីគឿន ក៏បានផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង០០២/០១។ សួង ស៊ីគឿន គឺជាកម្មាភិបាលជាន់ខ្ពស់មកពីមន្ទីរប-១ គឺក្រសួង <ការបរទេស ហើយក្រោយមក> គាត់ស្គាល់ ប៉ុល ពត ច្បាស់ណាស់ ព្រោះគាត់ជាអ្នកបកប្រែ <ផ្ទាល់>របស់ ប៉ុល ពត។ ហើយគាត់បាននិយាយអំពីទំនាក់ទំនងរបស់ ប៉ុល ពត ជាមួយ នួន ជា។ ខ្ញុំសូមបង្ហាញវីដេអូនេះ។

[១៥:១៩:០៨]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"សួង ស៊ីគឿន គឺជាជំនួយការផ្ទាល់របស់ ប៉ុល ពត ហើយគាត់ដឹងច្បាស់។ នួន ជា គឺបងទី២ ប្រធានគណៈសន្តិសុខ គឺពួកគេមានឯកសារជាច្រើនប្រឆាំងគាត់។ ខ្ញុំគិតថាលោកដឹង គឺជាមនុស្សខ្លាំង បំផុតបន្ទាប់ពី ប៉ុល ពត ខ្ញុំគិតថា នួន ជា គាត់ជាស្រមោលរបស់ ប៉ុល ពត។"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៥:១៩:៤២]

សួង ស៊ីគឿន បានហៅ នួន ជា ថាជាស្រមោលរបស់ ប៉ុល ពត ដូច្នេះគឺថា -- ហើយ នួន ជា បាននិយាយថា ខ្ញុំ -- ខៀវ សំផន បាននិយាយថា "ខ្ញុំគោរព ប៉ុល ពត យ៉ាងខ្លាំង"។ <ហើយនៅក្នុងកិច្ច សម្ភាសន៍នោះ គាត់ហៅប៉ុល ពត ជាមេដឹកនាំដ៏អស្ចារ្យ> គឺនៅក្នុងវីដេអូមួយដែលមានចំណងជើងថា៖ "ប្រឈមជាមួយ<អំពើ>ប្រល័យពូជសាសន៍" E3/109/2.3R។ <គាត់និយាយដូចតទៅ។ សូម អនុញ្ញាតបង្ហាញឯកសារលេខ៣។>

[១៥:២០:២១]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"...ពេលដែលគាត់មកធ្វើការនៅប៉ៃលិន ខ្ញុំតាមគាត់រហូត ដូចជាស្រមោលអន្ទោលតាមប្រាណ អ៊ីចឹង។"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៥:២០:៣៩]

ខៀវ សំផន ក៏អះអាងថា គាត់ជាស្រមោលរបស់ ប៉ុល ពត ដែរ។ អ៊ីចឹងបានន័យថា ស្រមោល ពីរ គាំទ្រ ប៉ុល ពត ជាពិសេសនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ដោយសារតែ ប៉ុល ពត <កើតជំងឺ ត្រដេវរិច> អ៊ីចឹងគាត់មិនទុកចិត្តមនុស្សច្រើនទេ គាត់ទុកចិត្តតែពីរនាក់ប៉ុណ្ណោះគឺ នួន ជា និង ខៀវ សំផន។ ខៀវ សំផន ស្មោះត្រង់ជាមួយគាត់ ហើយគាត់មានអារម្មណ៍<ក្តុកក្តួល ពេលនិយាយពី>ទំនាក់ ទំនង<នេះ>។ ខ្ញុំសូមអនុញ្ញាតបង្ហាញវីដេអូមួយនេះ។

[១៥:២១:១៤]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"...ខ្ញុំឃើញគាត់ជាប់ជាប្រចាំនៅទីនេះ នៅភ្នំក្រវាញ នៅកន្លែងនេះ នៅកន្លែងនោះ រូបភាពគាត់*

*គឺជក់ជាប់ក្នុងអារម្មណ៍ខ្ញុំជានិច្ច។ តើលោកនឹក ប៉ុល ពត ទេ? នឹក ពីព្រោះគាត់ជាមនុស្សកម្រកបាន ណាស់សម្រាប់ពួកយើង។"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៥:២២:១១]

នួន ជា នៅក្នុងខ្សែភាពយន្ត "នៅពីក្រោយវាលពិឃាត" គាត់បាននិយាយថាតើ ប៉ុល ពត ឡើងកាន់អំណាចដោយរបៀបណា? ប៉ុល ពត ឡើងកាន់ជាប្រធានបក្សកុម្មុយនីស្តកម្ពុជា ដោយរបៀបណា? <>គាត់ជាបុគ្គលទី២<បន្ទាប់ពី ប៉ុល ពត> ព្រោះយ៉ាងណា ក៏ដោយគាត់មានបញ្ហាដោយសារពូរបស់គាត់ឈ្មោះ ស៊ីវ ហេង ហ្នឹងធ្វើការនៅក្នុងរបប សម្ដេច សីហនុ <ប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជា។> ដូច្នេះហើយទើប<គាត់ស្នើ> ប៉ុល ពត <ធ្វើ>ជាមេដឹកនាំ។ ប៉ុន្តែ ប៉ុល ពត និយាយថា ទាល់តែធ្វើការជាក្រុមបានគាត់ឡើងធ្វើប្រធាន។ ហើយ ថេត សម្បត្តិ បានសួរ នួន ជា ថាតើនៅពេលនុ៎ងគេដោះស្រាយយ៉ាងដូចម្ដេចដែរ? ហើយគាត់បានឆ្លើយទៅនឹងសំណួរទាំងអស់នេះថា ខ្ញុំសូមអនុញ្ញាតបង្ហាញនៅក្នុងវីដេអូទី៥។

[១៥:២៣:០៥]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"...ប៉ុល ពត ធ្លាប់មានការពិភាក្សាណាមួយដ៏តឹងរ៉ឹងនឹងគ្នាទេបាទ? ពេលដែលគ្រប់គ្រងអំណាចហើយ ៧៥, ៧៦មកបាទ។ ដូចគ្នានទេៗ មិនមានទេ ៧៥-៧៩។ មិនមានបញ្ហាអីគ្នា នឹងគ្នាទេអត់។"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៥:២៣:៣៥]

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ចាប់តាំងពីការជម្លៀស<ដោយបង្ខំ ការដាក់មនុស្សទៅជាទាសករនៅតាមការដ្ឋាន>សហករណ៍<ជាកន្លែងដែលគេដាច់បាយ មិនមានសេរីភាពក្នុងមន្ទីរសន្តិសុខគឺមាន>មន្ទីរសន្តិសុខ<ចំនួន>១៩០ ដែលគេបង្កើតឡើងនៅទូទាំងប្រទេស ដែលគេបញ្ជូនមនុស្សទៅសម្លាប់នៅទីនោះ ដោយគ្មាននីតិវិធីច្បាស់លាស់អីហ្នឹងក៏ដោយ គឺថារួមទាំងគោលនយោបាយចំពោះចាម វៀតណាម គឺគោលនយោបាយប្រល័យពូជសាសន៍គឺថា នួន ជា បានអះអាងថា <> មិនដែលមានការប្រកែកគ្នាធ្ងន់ធ្ងរអ្វីជាមួយ ប៉ុល ពត នោះទេ។ ហើយចំពោះ ខៀវ សំផន នៅពេលគេសួរអំពី

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ប៉ុល ពត វិញនុំង គាត់បានផ្ដល់នូវចម្លើយដូចតទៅនេះ ខ្ញុំចាក់នូវវីដេអូលេខ៦ ដែលមានចំណងជើងថា "ប្រឈមជាមួយអំពើប្រល័យពូជសាសន៍"។

[១៥:២៤:២៩]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"...ការចោទអ៊ីចឹង ចោទថា ប៉ុល ពត ជាជនផ្ដាច់ការ ហើយនិងអនុវត្តអំពើប្រល័យពូជសាសន៍ហ្នឹង គឺមិនត្រឹមត្រូវទេ។ មេដឹកនាំចលនាដ៏ធំបែបហ្នឹង មិនអាចធ្វើបែបហ្នឹងទេ បើគាត់ធ្វើអ៊ីចឹងមែន គាត់មិនអាចបង្កើតចលនាបែបហ្នឹងបានទេ។ ខ្ញុំនឹងស្រែកបែបនេះ នៅមុខតុលាការ។"*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៥:២៥:១០]

នៅក្នុងសៀវភៅ ខៀវ សំផន <មានចំណង "ប្រវត្តិសាស្ត្រកម្ពុជានាពេលថ្មីៗ" សរសេរ>ថា "ប៉ុលពត តំណាងឲ្យមេដឹកនាំប្រវត្តិសាស្ត្រដែលមិនដែល<ចេះ>ខុស នៅពេលដែលគាត់ធ្វើការសម្រេចចិត្តសំខាន់ៗ។" នួន ជា នៅក្នុងកិច្ចសម្ភាសន៍របស់គាត់ នៅក្នុងខ្សែភាពយន្តវីដេអូ "<នៅក្រោយវាលពិឃាត>" ក៏គាត់និយាយអំពី<របៀបដែល>គាត់ ហើយនិង ប៉ុល ពត ចូលរួមវគ្គស្វ័យទិតៀន។ <គេសួរតើ ប៉ុល ពត រិះគន់ នួន ជា ថាយ៉ាងម៉េចខ្លះ?> ហើយគាត់បាននិយាយថា អ្វីដែល ប៉ុល ពត រិះគន់គាត់<ថាប្រកាន់មាគ៌ាយ៉ាងតឹងរ៉ឹងជ្រុល ហើយពិតជាគួរឲ្យភ្ញាក់ផ្អើលដែល ប៉ុល ពត ថាគាត់ប្រកាន់មាគ៌ាជ្រុល> ហើយគាត់រិះគន់ ប៉ុល ពត<វិញថា> ដោយសារតែថា ប៉ុល ពត ហ្នឹងឆាប់ជឿគេពេក។ <ខ្ញុំគិតថា នួន ជា គិតថា ប៉ុល ពត គួរតែ>សង្ស័យ <ហើយ>មិនទុកចិត្តគេថែមទៀត។ ពួកគាត់ទាំងអស់នេះ ស្មោះត្រង់ជាមួយគ្នាទៅវិញទៅមក។ នួន ជា, ខៀវ សំផន បានផ្ដាច់ខ្លួនចូលរដ្ឋាភិបាលរួមគ្នានៅថ្ងៃតែមួយ គឺថ្ងៃ២៥ ធ្នូ ៩៨។ ហើយយើងបាននិយាយផងដែរ អំពីចម្លើយសារភាពដែល នួន ជា ជួយ ខៀវ សំផន ដោយបញ្ជាឲ្យ ឌុច នៅពេលដែល ឌុច មកនិយាយជាមួយគាត់ គឺថាចំពោះចម្លើយសារភាពដែលឆ្លើយដាក់ ខៀវ សំផន គឺថាគាត់ប្រាប់ ឌុច ថាឲ្យលុបចោលនូវចម្លើយសារភាពទាំងអស់នោះ <កុំលើកមកនិយាយទៀត។ នេះមិនមែនជាសក្ដិកម្មរបស់ ឌុច ទេ ទោះបី> ឌុច និយាយបែបនេះដូចគ្នា<ក៏ដោយ>។ នេះគឺជាអ្វីដែល នួន ជា បានប្រាប់ ថេត សម្បត្តិ ហើយគាត់ប្រាប់ថា គាត់<ជួយខៀវ សំផន ពីព្រោះមាន>ចម្លើយសារភាពដែលឆ្លើយដាក់<ខៀវ សំផន។ គាត់ប្រាប់ថា មានចម្លើយសារភាពឆ្លើយដាក់ ខៀវ សំផន ហើយបញ្ជាឲ្យ ឌុច ចេញក្រៅ ហើយមិនត្រូវមកជួបគាត់វិញដោយ

មានចម្លើយសារភាពឆ្លើយដាក់>ខៀវ សំផន តទៅទៀត។ <អ៊ីចឹង ពួកគាត់ទាំងបីនាក់នេះ> ស្រមោលទាំងពីររបស់ ប៉ុល ពត <បង្កើតបានជាជើងកាងទាំងបី ក្នុងរង្វង់>ក្រុមកាន់អំណាចផ្ទៃក្នុងបំផុត ដែលគាត់ជាអ្នកដាក់ចេញនូវគោលនយោបាយឧក្រិដ្ឋនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ <លោក លោកស្រីចៅក្រម> ប្រពន្ធរបស់ កែ ពក មកផ្តល់សក្ខីកម្មកាលពីថ្ងៃ០៤ មិថុនា ២០១៥ នៅពេលដែលគេសួរគាត់ថា តើអ្នកណាជាប្រធានរបស់ប្តីលោកស្រី? ព្រោះថាប្តីគាត់ហ្នឹង គឺជាមេដឹកនាំភូមិភាគ<ដែរនៅចុងរបបនោះ ជាម្នាក់ក្នុងចំណោមពេជ្ឈឃាដក្នុងការបោសសម្អាតនោះ។ ចុះសាក្សីឆ្លើយថាយ៉ាងម៉េចវិញ?> គាត់ឆ្លើយថា ប៉ុល ពត, នួន ជា ហើយនិង ខៀវ សំផន <ជាមេ>។ ប្រាកដណាស់ថា នួន ជា និង ខៀវ សំផន បានផ្តល់នូវរឿងរ៉ាវច្រើន ដែលឆ្លើយខុសទៅនឹងអ្វីដែលពួកគេបានធ្វើ។ ហើយពួកគេព្យាយាមគេចចេញពីការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនានា។ ហើយ<វិធីមួយ>ជាពិសេស ខៀវ សំផន បានពឹងផ្អែកជាញឹកញាប់ហ្នឹង គឺពឹងផ្អែកទៅលើការអះអាងរបស់គាត់ ដែលថាគាត់អត់ដឹង។ អត់ដឹងអីសោះ អំពីអ្វីដែលកើតឡើងនៅ<ក្នុងរបប>កម្ពុជា<ប្រជាធិបតេយ្យ> អត់ដឹងអំពីការដាក់ឲ្យទៅជាទាសករ អត់ដឹងអំពីការបោសសម្អាត អត់ដឹងអ្វីទាល់តែសោះ អំពីឧក្រិដ្ឋកម្មដែលបានកើតឡើងនេះ។ ដូច្នេះ ខ្ញុំសូមបង្ហាញនូវវីដេអូលេខ៧។

[១៥:២៨:៥៣]

*(ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

*"បើតាមយោបល់លោក តើមានមនុស្សស្លាប់ប៉ុន្មាននាក់ នៅរបបខ្មែរក្រហម? ខៀវ សំផន៖ ខ្ញុំមិនអាចប្រាប់ពីតួលេខពិតប្រាកដបានទេ ពិតណាស់ ថាមានច្រើន។ ប៉ុន្តែខ្ញុំមិនជឿថា មានមនុស្សស្លាប់រហូតដល់២លាននាក់នោះទេ វាដូចជាពន្លើសពេកហើយ។ អ្នកកាសែត៖ តើលោកទទួលខុសត្រូវអ្វីខ្លះចំពោះអ្វីដែលបានកើតឡើង? ខៀវ សំផន៖ ការទទួលខុសត្រូវរបស់ខ្ញុំ? អ្នកកាសែត៖ បាទ ពិតមែនហើយ។ ខៀវ សំផន៖ ខ្ញុំគ្មានអំណាចអ្វីទាល់តែសោះ។ បើនិយាយពីការទទួលខុសត្រូវ គេមិនអាចបន្ទោសខ្ញុំបានទេ ពីព្រោះខ្ញុំមិនដឹងអ្វីទាំងអស់ ខ្ញុំអត់ដឹងអីទាល់តែសោះ។ ហេតុអីបានជាខ្ញុំមិនដឹង? ហេតុអ្វីបានជាខ្ញុំមិនព្យាយាមចង់ដឹង? ប្រហែលជាលោកអាចបន្ទោសខ្ញុំបាន ពីការទទួលខុសត្រូវនោះ ប៉ុន្តែចំពោះខ្ញុំ បានជាខ្ញុំមិនព្យាយាមចង់ដឹង ដោយសារតែខ្ញុំគោរពវិន័យបក្ស។ អ្នកកាសែត៖ តើលោកមានអារម្មណ៍ថាត្រូវបាន ប៉ុល ពត បោកប្រាស់ ដោយមិនប្រាប់ព័ត៌មានទាំងអស់នេះឲ្យដឹងដែរឬទេ? ខៀវ សំផន៖ អត់ទេ ពីព្រោះខ្ញុំយល់ថា ឲ្យគាត់ធ្វើត្រូវអ្វីដែល ប៉ុល ពត បានធ្វើគឺគាត់ធ្វើត្រូវ គាត់មាន*

*មូលហេតុ។ អ្នកកាសែត៖ ចុះស-២១? ខៀវ សំផន៖ ស-២១ ខ្ញុំមិនដឹងទេ ខ្ញុំអត់ដឹងអីទាល់តែសោះ។ ដូច្នេះខ្ញុំមិនអាចទម្លាក់កំហុសទៅលើ ប៉ុល ពត បានទេ ដោយសារតែខ្ញុំមិនដឹងថាមានស-២១ផងនោះ។”*

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង-រូបភាព)*

[១៥:៣០:៤៤]

លោក លោកស្រីចៅក្រម សូម្បីតែនៅក្នុងផ្នែកតូចនេះ គឺថា ខៀវ សំផន បានគេចដោះសា <ដោយផ្ទុយគ្នានឹងខ្លួនគាត់ គាត់>ថា<ដំបូង>គាត់មិនបានដឹងអំពីការសម្លាប់ មិនដឹងអ្វីទាំងអស់។ ហើយគាត់ថា ប៉ុល ពត នេះគឺថាតែងតែមានហេតុផល នូវអ្វីៗដែល ប៉ុល ពត ធ្វើតែងតែមានហេតុផលច្បាស់លាស់ណាស់។ តាមការពិតគឺគាត់បានដឹង <ពីព្រោះ>គាត់គឺជាប្រធានគណៈប្រធានរដ្ឋ។ គាត់បានផ្តល់ចម្លើយទៅសហចៅក្រមស៊ើបអង្កេតថា គាត់បានចូលរួមកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ជាទៀងទាត់។ គាត់បានឆ្លើយពីមុន<ក្នុងកិច្ចសម្ភាសន៍>ថា គាត់ធ្វើការជាមួយ ប៉ុល ពត នៅថ្នាក់មជ្ឈិមហ្នឹង ហូបបាយ ហូបទឹកជាមួយ ប៉ុល ពត និង នួន ជា។ <មើល>រូបភាពនេះ<កាលពីរបបកម្ពុជាប្រជាធិប-តេយ្យ>បញ្ជាក់ឲ្យឃើញថា ប៉ុល ពត, នួន ជា និង ខៀវ សំផន គឺថាហូប<បាយ>ល្ងាចជាមួយគ្នា<>។ ចុះបាយល្ងាចអ៊ីចឹង និយាយគ្នាពីអី? និយាយពីកុន មើលកុន ឬក៏និយាយពីអី។ អ៊ីចឹង ខៀវ សំផន ដឹងច្បាស់ណាស់ពីគោលនយោបាយរបស់ ប៉ុល ពត ក្នុងការបោសសម្អាត ជាពិសេសអ្នកដែលជិតដិតជាមួយនឹង ខៀវ សំផន ដែរ ត្រូវបានបាត់ខ្លួន ដូចជា ហ៊ូ នឹម, ហ៊ូ យន់ ដែលពីដើមនោះគេហៅថា “ខ្មោចទាំងបី” គឺមាន ខៀវ សំផន, ហ៊ូ នឹម, ហ៊ូ យន់ នេះឯង។

[១៥:៣២:០០]

គាត់អះអាងថា គឺឯកសារ E3/578៖ “ខ្ញុំ<មិនមែនជាមេដឹកនាំខ្មែរក្រហមទេ។ គេបង្ខំខ្ញុំ>ឲ្យចូលរួមជាមួយខ្មែរក្រហម”។ នៅក្នុងឯកសារ E3/18 <ជាសៀវភៅរបស់គាត់ គាត់អះអាង>ថា៖ “ខ្ញុំគ្រាន់តែដើរតាមគេ ខ្ញុំមិនមែនជាមនុស្សរបស់បក្សទេ”។ <ពិតណាស់ គាត់គ្រាន់តែដើរតាមបក្ស។> គាត់បានសារភាពថា <គាត់បានទទួលតំណែងបន្ទាប់ពី អៀង សារី ជាប្រធានរង្វង់ម៉ាក្សនិយម> នៅក្នុងឆ្នាំ១៩៥០ទៅ៥៧ <>ក្នុងប្រទេសបារាំង<>។ ហើយគាត់ប្រាប់ ហ្វីលីព ស្បត ហ្នឹងថា គាត់ធ្វើការជាមួយ ប៉ុល ពត និង នួន ជា <នៅទីក្រុងភ្នំពេញ> នៅក្នុងគណៈមជ្ឈិម នៅចុងទសវត្សរ៍១៩៥០ក្រោយពេល<គាត់>ត្រឡប់មកពីប្រទេសបារាំងវិញ <ហើយគេបានដាក់ការងារផ្សេងៗឲ្យគាត់ធ្វើ>។ ហើយក្នុងឆ្នាំ១៩៦៧ គាត់រត់គេចចេញពីភ្នំពេញ <ដោយមានការឧបត្ថម្ភពី>ចលនាបក្សកុម្មុយនីស្ត

កម្ពុជា។ គាត់<ទទួលស្គាល់ថា គាត់ចូលបក្សនៅភ្នំឱរ៉ាល់ ក្នុងឆ្នាំ១៩៦៩។ នេះគឺអ្វីដែលលោក ខៀវ សំផន បាន>និយាយ<នៅក្នុងតុលាការនេះ កាលពី>ថ្ងៃទី០៨ កុម្ភៈ ២០១២។ <> នួន ជា ក៏បានឆ្លើយពីខាងដើមថា នៅក្នុងឯកសារ E3/3 នៅក្នុងឆ្នាំ១៩៦៣ ខៀវ សំផន មិនទាន់បានចូល<>ជាមួយមជ្ឈិមនៅឡើយទេ ប៉ុន្តែគាត់ចូលរួមជាមួយនឹងបក្សហើយ តែមិនជាសមាជិកមជ្ឈិមទេ។ អ៊ីចឹង ខៀវ សំផន ថាគាត់មិនមែនជាមនុស្សរបស់បក្សទេ មិន<មែនមេដឹកនាំខ្មែរក្រហមទេ អ៊ីចឹង គាត់និយាយកុហកដោយគ្រាន់តែគេចវេះការ>ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលកើតឡើងនោះទេ។

[១៥:៣៣:៥០]

ខៀវ សំផន បានរៀបរាប់ប្រាប់សហចៅក្រមស៊ើបអង្កេតថា គាត់កត់សម្គាល់ឃើញថាសមាជិកមជ្ឈិមហ្នឹង គឺបានបាត់ខ្លួនម្តងមួយ ម្តងមួយជាបន្តបន្ទាប់។ ហើយពាក់ព័ន្ធទៅនឹងការបាត់ខ្លួនគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ គឺថាម្នាក់ៗហាក់បីដូចជាមានការយល់ស្រប។ ជាពិសេសឯកសារ <E3/3169> នៃកិច្ចសម្ភាសន៍ជាមួយ ស្ទីវ ហេដឌ័រ គាត់<បានកត់សម្គាល់>ថាមានថ្នាក់ដឹកនាំជាន់ខ្ពស់របស់ហ្រ្គុង និង ហ្វុង នេះរណសិរ្សរួបរួមជាតិនេះគឺថា បាត់ខ្លួនជាច្រើនក្នុងចំណោមឥស្សរជនទាំង ១៦នាក់នេះ ប្រាំបួននាក់ត្រូវបានសម្លាប់ចោល។ ក្នុងនោះរួមមាន ហ៊ូ យន់, ហ៊ូ នឹម, ស្តេច នរោត្តម ភូរីស្សារា, ទូច ភឿន, វ៉ាន់ ពីនី។<អ្នកទាំងអស់ជាសុទ្ធជាអ្នកដែល ខៀវ សំផន ទទួលខុសត្រូវ។> ហើយក្នុងសៀវភៅរបស់គាត់ "ប្រវត្តិកម្ពុជានៅពេលថ្មីៗ<>" គាត់<ទទួលដឹងឮ>ដូចតទៅ "នៅជិតពាក់កណ្តាលឆ្នាំ១៩៧៨ ខ្ញុំឮសូរអំពីការចាប់ខ្លួនក្នុងទ្រង់ទ្រាយធំ និងការសម្លាប់រង្គាលនៅ<ខេត្ត> ព្រះវិហារ គឺប្រពន្ធរបស់ខ្ញុំនឹងឯងដែលគាត់យំ ហើយប្រាប់ខ្ញុំអំពីការកាប់សម្លាប់រង្គាលប្រឆាំងទៅនឹងបងប្អូនសាច់ញាតិរបស់គាត់ <រួមទាំងជនរងគ្រោះដទៃទៀត>។" <អ៊ីចឹង តើគាត់ធ្វើអ្វីបានខ្លះ? គាត់បានបញ្ជាឲ្យគេដោះលែងសាច់ញាតិប្រពន្ធគាត់ ហើយមិនឲ្យធ្វើបាបគេទៀត។ >គាត់បាននិយាយជាច្រើនដងថា គាត់ដឹងថា ប៉ុល ពត ហ្នឹងមានជំងឺ<ត្រដេវរីច ជាហេតុផលដែលគាត់បញ្ជាឲ្យ>បោសសម្អាត។ ហើយគាត់នៅក្នុងឯកសារ E3/4032 ខៀវ សំផន បាននិយាយ<ក្នុងកិច្ចសម្ភាសន៍គាត់>ដូចតទៅ គាត់គឺ "ប៉ុល ពត ហ្នឹង បានយកចិត្តទុកដាក់ចំពោះស្ថានភាព និងកម្មាភិបាលជាពិសេសកម្មាភិបាលសំខាន់ៗ។ <គាត់តែងតែអញ្ជើញអ្នកទាំងនោះ>មកនិយាយគ្នាលែង ហើយអ្នកដែលមកនិយាយគ្នាលែងហ្នឹង គឺគេមិនបានដឹងអំពីចេតនាពិតប្រាកដរបស់ ប៉ុល ពត ទេ។" ឯកសារ E3/203 ខៀវ សំផន បាននិយាយអំពីការបោសសម្អាតនេះដែរ។ "អ្នកទាំងអស់នេះមានតួនាទីសំខាន់ៗណាស់ អ្នកខ្លះ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

នោះគឺថា កាន់កាប់តួនាទីនៅភូមិភាគសំខាន់ៗ <តែពួកគេបានប្រព្រឹត្តិខុសមាគ៌ារបស់យើង>។” <គាត់> ថា “ទោះយ៉ាងណាក៏ដោយ គឺថាយើងបានវាយ និងធ្វើឱ្យពួកគេបរាជ័យជាបន្តបន្ទាប់។ រហូតមកដល់ឆ្នាំ៧៧, ៧៨ យើងចាត់ចែងដោះស្រាយជាមួយអ្នកទាំងនេះ<បាន>ទាំងស្រុងតែម្តង ហើយយើងបានឱ្យប្រទេសជាតិវិលត្រឡប់មកភាពធម្មតាវិញ។”

[១៥:៣៦:២៩]

បាទ ខ្ញុំសូមរំលងពីរបីទំព័រ។ ខ្ញុំចង់<កត់សម្គាល់អំពី>អ្វីដែល ខៀវ សំផន អះអាងថាគាត់មិនដឹងថាមានការបោសសម្អាត <និងចាប់ខ្លួន>នោះទេ ដូច ខឿន នេះដែលជាសមាជិកនៃ<គណៈ>មន្ទីរ៨៧០។ ប៉ង់ ដែលធ្វើការជាមួយថ្នាក់ដឹកនាំមជ្ឈិម<ស-៧១> <គាត់ធ្វើការយ៉ាងជិតស្និទ្ធនឹង ខៀវ សំផន ក្នុងមន្ទីរ៨៧០។ ឯក ហេន បានផ្តល់សក្ខីកម្ម>នៅក្នុងឆ្នាំ២០១៣ <ថា> ខៀវ សំផន <និយាយយ៉ាង>លម្អិតនៅក្នុងវគ្គរៀនសូត្រមួយនៅបុរីកីឡានេះ <មានពលករប្រហែល៤០០នាក់។>គាត់និយាយអំពីការចាប់ខ្លួន<>ប៉ង់ៗ ត្រូវបានចាប់ខ្លួនដោយសារតែសហការជាមួយនឹងយួន។ ដូច្នេះ ខៀវ សំផន នោះដឹងហើយ និយាយអំពីការចាប់ខ្លួន ដូចជាការចាប់ខ្លួនវន វ៉េត <ជាសមាជិកគណៈអចិន្ត្រៃយ៍ ធ្លាប់> ជា<ឧបនាយក>រដ្ឋមន្ត្រីក្រសួង<សេដ្ឋកិច្ច។ ដូច្នេះ គាត់អាចមានការទទួលខុសត្រូវរួមគ្នាជាមួយ ខៀវ សំផន ទាក់ទងនឹងការនាំចេញ និងបញ្ហាពាណិជ្ជកម្មផ្សេងៗទៀត។>

ឥឡូវនេះ ខ្ញុំសូមលើកឡើងអំពី<កិច្ចប្រជុំគណៈអចិន្ត្រៃយ៍។ កន្លងមក យើងបាននិយាយខ្លះៗ ហើយអំពី>សំណុំរឿង០០២/០១។ <ខៀវ សំផន បានប្រាប់ ក.ស.ច.ស>ថា <គេអញ្ជើញ>គាត់ បានចូលរួមកិច្ចប្រជុំគណៈ<អចិន្ត្រៃយ៍ មួយ ឬ>ពីរដងក្នុងមួយខែ <ជាកិច្ចប្រជុំធំ។> គាត់ថា “ពីឆ្នាំ ១៩៧៥-៧៩ <មិនមានកិច្ចពិភាក្សាដេញដោលអីទេ។ ការប្រជុំដែលខ្ញុំចូលរួម>គឺ<មានតែ> ប៉ុល ពត <និយាយតែឯង។” វាគួរឱ្យចាប់អារម្មណ៍ផងដែរ ចំពោះការអះអាងរបស់មេធាវីការពារក្តី លើកឡើងថា នៅក្នុងរង្វង់បក្សកុម្មុយនីស្តកម្ពុជា តែងតែងមានជម្លោះមិនស្រាកស្រាន្ត។ បក្សបែកបាក់គ្នាដោយគូបដិបក្ខ។ ខៀវ សំផន និយាយថា គ្រប់គ្នានៅក្នុងបក្សនោះត្រូវរ៉ូវគ្នាណាស់ក្នុងកិច្ចប្រជុំ។> ឥឡូវនេះ ខ្ញុំក៏បាត់បង់សម្រង់ដែរ ខ្ញុំព្យាយាមរកសម្រង់នោះមកបង្ហាញជូនអង្គជំនុំជម្រះឡើងវិញ។ <គឺថា នៅក្នុងបក្សនោះ គេមានភាពស្និទ្ធស្នាលគ្នាណាស់។>

ខ្ញុំសូមបង្ហាញ*ស្លាយ*បន្ទាប់ <លេខ៨០ ស្លាយ២> គឺពាក់ព័ន្ធនឹង<តារាង>អ្នកដែលចូលរួមកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍។ <យើងចាំបានថា មានកំណត់ត្រា១៩ បញ្ជីអ្នកចូលរួមប្រជុំ ដែលនៅ

សេសសល់ ហើយយើងឃើញថា នួន ជា បានចូលរួមច្រើនជាងគេ បន្ទាប់មក មាន ប៉ុល ពត និង ខៀវ សំផន។ ក្នុងតារាងនេះ យើងបានដាក់ពណ៌ទឹកក្រូចលើ>អ្នកដែលត្រូវបានបោសសម្អាត។ <យើងឃើញថា អ្នកទីបួន ដែលចូលរួមញឹកញាប់ជាងគេ គឺឈ្មោះ ឌឿន។ អ៊ីចឹង>នៅពេលដែល ខៀវ សំផន និយាយអំពីកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ធំធេងនេះ គឺគាត់ ហើយនិង ឌឿន នោះក៏ចូលរួមប្រជុំដែរ។ <យើងអាចយល់បាន> គឺថាពួកគាត់ធ្វើការនៅមន្ទីរ៨៧០ គឺជាៗអ្នកបម្រើឲ្យគណៈអចិន្ត្រៃយ៍នេះឯង។ ដូច្នេះកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍នេះគឺមាន ខៀវ សំផន និង ឌឿន ចូលរួមផងដែរ។ <យើងកត់សម្គាល់ឃើញមាន> មេដឹកនាំភូមិភាគ<> រួមមានតាម៉ុក ហ្នឹងកម្រនឹងចូលរួមប្រជុំ ហើយ សោ ភឹម ក៏ដូច្នោះដែរ កម្រនឹងចូលរួមប្រជុំកិច្ចប្រជុំគណៈអចិន្ត្រៃយ៍នេះណាស់។ <ក្នុងកំណត់ត្រាទាំង១៩ នៃកិច្ចប្រជុំនោះ>ប្រហែលពីអ្នកទាំងអស់នេះរវល់កិច្ចការនៅតាមភូមិភាគរបស់ខ្លួន។ អ៊ីចឹងកិច្ចប្រជុំនេះ គឺថាមានសមាជិកតិចតួចណាស់។ យើងឃើញហើយតាមតារាងនេះ គឺអ្នកដែលចូលរួមប្រជុំជាអចិន្ត្រៃយ៍<ញឹកញាប់ទាំងនោះ>ក៏ត្រូវបានបោសសម្អាត<ដែរ។ យើងមិនបានដាក់ក្នុងបញ្ជីអ្នកដែលចូលរួមបានមួយ ឬពីរដងនោះទេ> ពីព្រោះ<អ្នកទាំងនោះ មកគ្រាន់តែរាយការណ៍កិច្ចការ>សំខាន់ៗ។ ហើយអ្នកដែលបោសសម្អាតនេះ <រួមមាន> កុយ ធួន បោសសម្អាតតាំងពីដើមដំបូង អ៊ីចឹងយើងឃើញ<នៅលេខ>សល់ប្រាំមួយ <ជាអ្នកចូលរួមប្រជុំ បន្ទាប់មកមាន> វន វ៉េត ហើយនិង ឌឿន ទៀត។ អ៊ីចឹងសរុបទៅឃើញថា សមាជិកគណៈអចិន្ត្រៃយ៍នៅសល់តែប្រាំនាក់ <ដែលខ្ញុំដាក់ពណ៌ខៀវ> ហើយពីរនាក់ក្នុងចំណោមប្រាំនាក់ហ្នឹង គឺមាន អៀង សារី ហើយនិង សុន សេន ហ្នឹងក៏តែងតែទៅឆ្ងាយ<ដែរ។> អៀង សារី គាត់តែងតែចេញទៅ<បេសកកម្ម>ក្រៅប្រទេស ហើយ សុន សេន គេបញ្ជូនទៅសមរភូមិប្រយុទ្ធជាមួយនឹងវៀតណាមនៅ<ចុង>ឆ្នាំ៧៧។ អ៊ីចឹងនៅពេលដែលមានការបោសសម្អាតបែបនេះ នៅពេល សុន សេន គេបញ្ជូនទៅសមរភូមិ យើងឃើញថា<>អំណាចរបស់ ខៀវ សំផន ចេះតែកើនឡើង កើនឡើង ពីមួយពេលទៅមួយពេល។

[១៥:៤១:១៤]

លោក ស្ទីវ ហេដឌ័រ នៅក្នុងឯកសារ <E3/3169> នេះនិយាយអំពី<ការចូលរួមបោសសម្អាតរបស់>ខៀវ សំផន<។ >គាត់និយាយថា៖ "ការពាក់ព័ន្ធរបស់ ខៀវ សំផន ក្នុងការបោសសម្អាតជាទូទៅនោះ គឺ<មានលក្ខណៈ>ការិយាធិបតេយ្យហើយ ពីព្រោះថា<>ឋានៈរបស់គាត់<នៅក្នុងអង្គការបក្ស គឺទទួលបន្ទុក>តាមដានការអនុវត្តគោលនយោបាយ<របស់បក្ស ស្របទៅនឹង>សេចក្ដីសម្រេច

របស់ ប៉ុល ពត ដែលថាភារកិច្ចសំខាន់<របស់បក្សកុម្មុយនីស្តកម្ពុជា គឺមិនមែន>ការកសាងសេដ្ឋកិច្ចរបស់កម្ពុជា<ប្រជាធិបតេយ្យនោះទេ គឺអ្វីដែលចាំបាច់ ត្រូវ>វែកមុខរកអ្នកណាដែលត្រូវចោទប្រកាន់<>ជាភ្នាក់ងារខ្មាំង <ដែលអាច>ធ្វើវិទ្ធង្សនាមកលើបដិវត្តន៍របស់គាត់។" <នេះមានការផ្លាស់ប្តូរមួយដោយផ្តល់អាទិភាពខ្ពស់បំផុតដក់កិច្ចការបោសសម្អាត ហើយត្រូវផ្សព្វផ្សាយដល់ផ្ទៃបក្ស ដោយ>អនុលេខាបក្ស នួន ជា នេះឯង។

<លោក លោកស្រីចៅក្រម> ឥឡូវនេះខ្ញុំអនុញ្ញាតឲ្យសហការីរបស់ខ្ញុំ <សហព្រះរាជអាជ្ញាជាតិ> បង្ហាញជូនលោក លោកស្រីចៅក្រមជាបន្ត <អំពីការកាត់ទោស>។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញ!

[១៥:៤២:៣១]

**លោកស្រី ជា លាង៖**

សូមគោរពលោកប្រធាន ចៅក្រម ភាគី និងសវនាការទាំងមូលសាជាថ្មី។ ឥឡូវនេះ ឈានដល់ពេលចុងក្រោយដែលសហព្រះរាជអាជ្ញាបានបង្ហាញភស្តុតាងនានា ក្នុងរយៈពេល២ថ្ងៃនេះ។ លោកប្រធាន លោកចៅក្រម សហព្រះរាជអាជ្ញានឹងបញ្ចប់សេចក្តីសន្និដ្ឋាន ដោយស្នើឲ្យធ្វើការសម្រេចថាមានពិរុទ្ធភាព និងផ្តន្ទាទោស នួន ជា និង ខៀវ សំផន។

ជាដំបូង គឺស្នើឲ្យសម្រេចថា ជនជាប់ចោទទាំងពីររូបមានពិរុទ្ធភាព សម្រាប់ការចូលរួមរបស់ពួកគេនៅក្នុងអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើសន្ធិសញ្ញាក្រុងហ្សឺណែវ ដូចមានចែងលម្អិតនៅក្នុងដីកាដំណោះស្រាយ។ យើងស្នើដែរថា ផ្អែកទៅលើគុណភាព និងបរិមាណនៃភស្តុតាង ដែលបានទទួលយកនៅក្នុងការជំនុំជម្រះនេះ។ នេះគឺជាសេចក្តីសន្និដ្ឋានសមហេតុផលតែមួយគត់ ដែលអាចធ្វើឲ្យហួសពីវិមតិសង្ស័យលើភស្តុតាងទាំងនោះ។ សម្រាប់ការផ្តន្ទាទោស នួន ជា និង ខៀវ សំផន មានចំណុចសំខាន់ៗមួយចំនួនដែលត្រូវលើកយកមកពិចារណា។ ភស្តុតាង រួមទាំងសេចក្តីសន្និដ្ឋានដែលបានដាក់បង្ហាញ ៗថាជនជាប់ចោទទាំងពីររូប គឺស្ថិតក្នុងចំណោមក្រុមតូចមួយនៃក្រុមមនោគមន៍វិជ្ជានាំមុខ ស្ថាបនិក អ្នករៀបចំផែនការ និង អ្នកអនុវត្តនៅក្នុងបក្សកុម្មុយនីស្តកម្ពុជាដែលជាប្រព័ន្ធមួយក្នុងចំណោមប្រព័ន្ធពេញលេញ និងឃោរឃៅបំផុតនៃការរំលោភសិទ្ធិមនុស្ស ដែលត្រូវបានដាក់នៅក្នុងប្រទេសកម្ពុជា ក្នុងទសវត្សរ៍ទី២០។ នៅក្នុងពេលដែរ

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

នៅពេលដែលពួកគេឡើងកាន់អំណាច ជនជាប់ចោទទាំងនេះ បានចាប់ផ្តើមវាយប្រហារ និងធ្វើទុក្ខទោសប្រជាជនខ្មែរ ដែលពួកគេត្រូវមានការទទួលខុសត្រូវ ការពារប្រជាជនទាំងនោះ។

[១៥:៤៤:៤៣]

នៅក្នុងគំនិតរបស់ជនជាប់ចោទទាំងពីរ ពួកគេគិតថា វាសំខាន់សម្រាប់ពួកគេកាន់អំណាច ទោះត្រូវចំណាយអ្វីក៏ដោយ និង ដើម្បីសម្រេចបាននូវ ដើម្បីសម្រេចបាននូវទស្សនៈនៃលទ្ធិកុម្មុយនីស្តមួយដ៏ល្អឥតខ្ចោះ ជៀសវាងការគោរព និងការការពារសិទ្ធិមនុស្សជាមូលដ្ឋានបំផុត ដែលប្រជាជនខ្មែរទាំងអស់ត្រូវមាន នៅក្នុងរយៈពេលកម្ពុជាប្រជាធិបតេយ្យ។ នៅក្រោមការគ្រប់គ្រងរយៈពេល៣ឆ្នាំ ៨ខែ និង២០ថ្ងៃ ជនជាប់ចោទទាំងនេះ ជាមួយនឹងជនសមគំនិតដទៃទៀត បានទុកចោលនូវកាតព្វកិច្ចរបស់ប្រទេសកម្ពុជាចំពោះសិទ្ធិសញ្ញាសិទ្ធិអន្តរជាតិ និងដោយមានចេតនា ធ្វើការវាយប្រហារលើសិទ្ធិមនុស្សជាមូលដ្ឋានរបស់ប្រជាជនកម្ពុជា។ ពួកគេបានដកហូតនូវសិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានការការពារខ្លួន សិទ្ធិទទួលបានការជំនុំជម្រះដោយត្រឹមត្រូវ និងយុត្តិធម៌ សិទ្ធិបញ្ចេញមតិ និងសិទ្ធិធ្វើដំណើរពីប្រជាជនកម្ពុជា។ ពួកគេបានដកហូតនូវសិទ្ធិគោរពប្រតិបត្តិការសាសនាតាមជម្រើស។ សិទ្ធិគ្រួសារ រៀបការ ធ្វើការ សម្រាក និងសិទ្ធិទទួលបានអាហារគ្រប់គ្រាន់ ទឹក អនាម័យ ការថែទាំសុខភាព និងជម្រកក្នុងចំណោមសិទ្ធិដទៃទៀត ពីប្រជាជន។

[១៥:៤៦:២៤]

នួន ជា និង ខៀវ សំផន ក្នុងការអនុវត្តមនោគមន៍វិជ្ជានយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាជឿថា ពួកគេមានអំណាចពេញលេញ ធ្វើអ្វីក៏បានតាមចិត្តចង់របស់ពួកគេមកលើប្រជាជនខ្មែរ។ ហើយពួកគេពិតជាបានធ្វើដូច្នេះមែន ដូចជា ពួកគេបានបង្ខំប្រជាជនចាកចេញពីគេហដ្ឋានរបស់ខ្លួន និងធ្វើការដោយបង្ខំនៅតាមការដ្ឋានពលកម្មនានាទូទាំងប្រទេស ដោយពួកគេត្រូវរងទទួលការឈឺចាប់ និងស្លាប់ក្រោមស្ថានភាពអមនុស្សធម៌។ ទី២ ពួកគេបានបំបែកគ្រួសារ បំបែកកូនចៅពីឪពុកម្តាយ និងបំបែកប្តីពីប្រពន្ធ ដើម្បីកាត់បន្ថយអំណាចគ្រួសារ និងឥទ្ធិពល។ ទី៣ ពួកគេបង្ខំបុរស និងនារី ឲ្យរៀបការ និងរួមសង្វាសដោយគ្មានការព្រមព្រៀង។ ទី៤ ពួកគេបានធ្វើទុក្ខបុកម្នេញ និងសម្លាប់សមាជិកគ្រួសារនៃក្រុមដែលជនជាប់ចោទចាត់ទុកថា ជាគូសត្រូវនយោបាយសក្តានុពល ដែលក្រុមទាំងនេះ រួមមាន អតីតមន្ត្រី និងអ្នករដ្ឋការសម័យសាធារណរដ្ឋ អតីតអ្នករស់នៅទីក្រុង និងទីប្រជុំជន កម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ទាហាន និងបុគ្គលិកក្រសួងរបស់កម្ពុជាប្រជាធិបតេយ្យ ពុទ្ធសាសនិក ជនជាតិចាម និងវៀត

ណាម។

ការធ្វើទុក្ខបុកម្នេញនេះ ត្រូវបានធ្វើឡើងតាមរយៈការដាក់ពន្ធនាគារ ការធ្វើទារុណកម្ម ការសម្លាប់ក្រៅប្រព័ន្ធតុលាការ និងអំពើអមនុស្សធម៌ដទៃទៀត ទាំងនៅក្នុង និងក្រៅប្រព័ន្ធមន្ទីរសន្តិសុខដ៏ច្រើនសន្ធឹកសន្ធាប់របស់បក្សកុម្មុយនីស្តកម្ពុជា។ ការរំលោភបំពានជាប្រព័ន្ធ និងដោយចេតនានេះ ត្រូវបានអនុវត្តទូទាំងភូមិភាគ និងខេត្តនានា នៅក្នុងកម្ពុជាប្រជាធិបតេយ្យសម្រាប់រយៈពេលទាំងមូល ដែលជនជាប់ចោទកាន់អំណាច។ ប្រសិនបើមាននរណាម្នាក់អាចនៅរស់រានមានជីវិតពីរបបខ្មែរក្រហមនេះ ពួកគេនៅតែទទួលអារម្មណ៍ប៉ះពាល់ទាំងផ្លូវកាយ ទាំងផ្លូវចិត្ត ដោយសារការប្រព្រឹត្តដោយបក្សកុម្មុយ-នីស្តកម្ពុជា។ ជនជាប់ចោទបានធ្វើឲ្យប្រជាជនកម្ពុជាទទួលរងនូវការឈឺចាប់ ការរំលោភបំពានជាប្រព័ន្ធនេះ និងការអនុវត្តដោយមិនរាថយដោយជនជាប់ចោទ បានបង្កើតនូវបរិយាកាសនៃការភ័យខ្លាចក្នុងចំណោមប្រជាជនកម្ពុជា ដោយពួកគាត់មានការភ័យខ្លាចថា ពួកគេនឹងត្រូវបានសម្លាប់ ឬជួបគ្រោះថ្នាក់បន្ថែម ក្នុងពេលណាមួយមិនខាន់។ របបផ្តាច់ការឃោរឃៅដែលជនជាប់ចោទបានដឹកនាំមួយនេះ បានបន្សល់ទុកដល់ប្រជាជនកម្ពុជានូវការខូចខាតខាងផ្លូវចិត្ត និងផ្លូវកាយ រយៈពេលវែង ដែលការខូចខាតនេះ នឹងកំពុងបន្តនៅជាមួយពួកគេអស់មួយជីវិត។

[១៥:៤៩:៤១]

តួនាទីរបស់ នួន ជា និង ខៀវ សំផន នៅក្នុងការរំលោភបំពានទៅលើប្រជាជនជាប្រព័ន្ធនេះ គឺជាចំណុចដែលសំខាន់ និងចាំបាច់។ ជនទាំងពីររូបនេះ គឺស្ថិតនៅចំណុចកំពូលនៃរដ្ឋអំណាចរបស់បក្សកុម្មុយនីស្តកម្ពុជាដែលបានគ្រប់គ្រងប្រទេសពេញរបបកម្ពុជាប្រជាធិបតេយ្យ។ តួនាទីរបស់ នួន ជា ជាអ្នកទទួលខុសត្រូវទី២នៃបក្សកុម្មុយនីស្តកម្ពុជា និងតួនាទី ខៀវ សំផន ជាប្រមុខរដ្ឋ ដែលជាតួនាទីមួយក្នុងចំណោមតួនាទីដ៏ច្រើនដែលពួកគេមាននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងបក្សកុម្មុយនីស្តកម្ពុជានៅថ្នាក់ខ្ពស់បំផុត គឺជាចំណុចសំខាន់សម្រាប់ការអភិវឌ្ឍ និងការអនុវត្តគោលនយោបាយឧក្រិដ្ឋទាំងនេះ។ នៅក្នុងតួនាទីទាំងនេះជនជាប់ចោទទាំងពីរ បានរំលោភបំពានអំណាចរបស់គេដល់កម្រិតខ្ពស់បំផុត សម្រាប់ជនទាំងនេះ លទ្ធផលគឺត្រូវតែទទួលបានតាមមធ្យោបាយណាក៏ដោយ ទោះបីជាមធ្យោ-បាយនោះយង់ឃ្នងយ៉ាងណាក៏ដោយ។ មិនត្រូវមានការបន្ធូរបន្ថយក្នុងការផ្តន្ទាទោសជនជាប់ចោទទាំងពីរនេះឡើយ ទោះបីដោយសារតែវ័យចាស់ជរា ការសិក្សា ឬកម្រិតស្មារតីរបស់ពួកគេក្តី។ នួន ជា មានអាយុ៤៨ឆ្នាំ និង ខៀវ សំផន អាយុ៤៣ឆ្នាំ នៅពេលដែលបក្សកុម្មុយនីស្តត្រួតត្រាប្រទេសកម្ពុជាក្នុងឆ្នាំ

១៩៧៥។ ហើយអ្នកទាំងពីរធ្លាប់បានស្ថិតក្នុងចំណោមមនុស្សតិចតួចបំផុតនៅប្រទេសកម្ពុជា ដែលមានសិទ្ធិសិក្សានៅបរទេស។ នួន ជា បានទៅសិក្សាច្បាប់នៅប្រទេសថៃ។ ហើយ ខៀវ សំផន បានសិក្សាច្បាប់ និងសេដ្ឋកិច្ច ថ្នាក់បណ្ឌិតនៅប្រទេសបារាំង។ ពួកគេជាមនុស្សមានប្រាជ្ញា ហើយយល់ដឹងពីលទ្ធផលនៃអំពើរបស់ខ្លួន ជាមនុស្សដែលមានជំនាញក្នុងការសិក្សា និងបំនិនជីវិត ដោយដឹងនូវរបៀបគ្រប់គ្រង និងជះឥទ្ធិពលលើអប្បកិរិយារបស់ប្រជាជន ដើម្បីបំពេញបំណងរបស់ខ្លួន ទោះជាល្អឬអាក្រក់ក្តី។ ជនជាប់ចោទក៏មិនត្រូវទទួលបាននូវការបន្ធូរបន្ថយដោយផ្អែកលើការសំអាងថា ឧក្រិដ្ឋកម្មរបស់ពួកគេត្រូវបានប្រព្រឹត្តក្រោមការបង្ខិតបង្ខំ មិនដូចគ្នាទៅនឹងការអ្នកយាមមន្ទីរសន្តិសុខវ័យក្មេង ដែលត្រូវបានបក្សកុម្មុយនីស្តកម្ពុជាបង្ខំឲ្យធ្វើការតាមមន្ទីរសន្តិសុខនានា ដូចជា មន្ទីរសន្តិសុខស-២១ ហើយដែលត្រូវបានគេដាក់សម្ពាធឲ្យរំលោភបំពាន ធ្វើទារុណកម្ម និងសម្លាប់ ឬពួកគេនឹងត្រូវគេសម្លាប់។ ជនជាប់ចោទទាំងនេះ មិនស្ថិតនៅក្រោមសម្ពាធបែបនេះឡើយ គឺពួកគេនេះហើយដែលជាអ្នកបង្កើតគោលនយោបាយឧក្រិដ្ឋ ដើម្បីបង្កើតនូវបរិយាកាសភ័យខ្លាច ហើយមិនមែនពួកគេទេដែលជាអ្នកទទួលរងនូវបរិយាកាសនេះ។

[១៥:៥២:៥២]

ជនជាប់ចោទទាំងពីរមិនបានសហការជាមួយនឹង អ.វ.ត.ក អ្វីធំដុំទេ ក្រៅពីអ្វីដែលជាតម្រូវការច្បាប់ ឲ្យពួកគេចូលរួមក្នុងដំណាក់កាលស៊ើបអង្កេត និងជំនុំជម្រះឡើយ។ ក្នុងរយៈពេល៣៨ឆ្នាំចុងក្រោយ ចាប់តាំងពីឧក្រិដ្ឋកម្មទាំងនេះ ត្រូវបានប្រព្រឹត្តដោយជនជាប់ចោទ ពុំមានពួកគេណាម្នាក់បានបង្ហាញពីវិប្បដិសារីពិតប្រាកដឡើយ។ ទោះបីជាជនជាប់ចោទទាំងពីរ បានពាក់ព័ន្ធក្នុងការផលិតសៀវភៅ និងភាពយន្តឯកសារនានាស្តីពីតួនាទីរបស់ពួកគេក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យក្តី ពួកគេបានប្រើមធ្យោបាយផ្សព្វផ្សាយនេះ ដើម្បីផ្តល់ហេតុផល ថាអំពើរបស់ពួកគេត្រឹមត្រូវ ជៀសវាងធ្វើការសារភាពកំហុសចំពោះអំពើទាំងនោះ។ ខៀវ សំផន មានទស្សនៈថា ខ្លួនមិនបានធ្វើខុស ធ្វើឲ្យខ្លួនអៀនខ្មាសនៅចំពោះមុខនរណាម្នាក់ឡើយ។ នួន ជា និយាយថា ខ្លួនមិនស្តាយក្រោយសម្រាប់អ្នកដែលត្រូវបានគេសម្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យឡើយ។ ទោះបីជា នួន ជា និយាយថា ខ្លួនទទួលខុសត្រូវតែផ្នែកសីលធម៌សម្រាប់អ្វីដែលបានកើតឡើង នួន ជា បានបដិសេធមិនទទួលយកការទទួលខុសត្រូវបុគ្គលចំពោះសកម្មភាពផ្ទាល់របស់ខ្លួន។ គួរឲ្យស្តាយ នៅពេលដែលសួរថា តើគាត់នឹងធ្វើបដិវត្តម្តងទៀត បើសិនជាគាត់កើតឡើងវិញ ចម្លើយដែលគ្មានការកែប្រែរបស់គាត់គឺ គាត់នឹងធ្វើបដិវត្តទៀត ធ្វើ

បដិវត្តទៀត។

ការពិតដែលថា ជនជាប់ចោទទាំងពីរ បានកាន់អំណាចដែលពួកគាត់មាននៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ ហើយអំណាចនេះបានផ្តល់សិទ្ធិទាំងស្រុងឲ្យពួកគាត់ធ្វើការជ្រើសរើសអ្នកអាចរស់ និងអ្នកដែលត្រូវស្លាប់ និងរបៀបដែលពួកគេរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បង្ហាញអំពីភាពគ្មានវិប្បដិសារីទាំងស្រុង។ នេះក៏បង្ហាញនូវការភ័ន្តច្រឡំជាមូលដ្ឋានរបស់ពួកគេ ថាតើសង្គមដែលមានស្ថានភាពល្អមួយ ត្រូវមានសភាពបែបណា។ សង្គមបែបនេះ គឺជាសង្គមមួយដែលមនុស្សសរសើរ មិនមែនជាសង្គមដូចខ្មោចបិសាចនោះទេ។ ការរំលោភបំពាន ការរំលោភអំណាច និងការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរបែបនេះ ត្រូវតែថ្កោលទោសយ៉ាងខ្លាំងបំផុតដោយតុលាការនេះ។

[១៥:៥៥:៣៦]

លោកប្រធាន លោកចៅក្រម យើងស្នើឡើងថា ការផ្តន្ទាទោសដែលសាកសមបំផុតតែមួយគត់សម្រាប់ជនជាប់ចោទទាំងពីរ គឺការផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។ ការផ្តន្ទាទោសបែបនេះ គឺឆ្លុះបញ្ចាំងពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយជនជាប់ចោទទាំងពីររូប និងតួនាទីសំខាន់ដែលពួកគេមាននៅក្នុងការប្រព្រឹត្ត។ យើងដឹងថា សាលក្រម និងការផ្តន្ទាទោសនេះ នឹងមិនធ្វើឲ្យអ្នកដែលត្រូវបានសម្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានជីវិតឡើងវិញបានឡើយ និងមិនអាចព្យាបាលនូវការខូចខាតអ្នកដែលបានទទួលរងការឈឺចាប់នៅក្នុងរបបនោះឡើយ។ ទោះជាយ៉ាងណាក្តី យើងសង្ឃឹមថា ការផ្តន្ទាទោសបែបនេះ នឹងនាំឲ្យមានយុត្តិធម៌ខ្លះសម្រាប់ជនរងគ្រោះនៃឧក្រិដ្ឋកម្មទាំងនេះ និងជួយធ្វើឲ្យញញើតដល់ការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ កុំឲ្យកើតមានឡើងនៅអនាគត ដោយផ្ញើសារថា មិនមានបុគ្គលណាមួយនៅលើច្បាប់ ទោះបីមានឋានៈ ឬតួនាទីណាក៏ដោយ។

នៅពេលដែលលោកប្រធាន និងលោកចៅក្រម ចេញសាលក្រមសេចក្តីសម្រេចនៅក្នុងការជំនុំជម្រះនេះ យើងស្នើជាពិសេសសូមលោកប្រធាន លោកចៅក្រមផ្តល់នូវសាលក្រមពេញលេញបំផុតមួយ ដោយធ្វើការបង្ហាញលម្អិតបំផុតតាមដែលអាចធ្វើទៅបាន អំពីអង្គហេតុសម្រាប់ការចោទប្រកាន់ បរិបទនៃអង្គហេតុទាំងនោះ និងប្រភពភស្តុតាងដែលអង្គហេតុទាំងនោះ និងសេចក្តីសម្រេចរបស់តុលាការយកមកធ្វើជាមូលដ្ឋាន។ នៅពេលដែលដែលធ្វើដូច្នេះ សាលក្រមនេះនឹងអាចផ្តល់នូវមេរៀនរឹងមាំមួយ សម្រាប់ប្រជាជនជំនាន់ក្រោយ និងរដ្ឋាភិបាលកម្ពុជានាអនាគត ស្តីពីការពិតនៃប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ និងការយល់ដឹងច្បាស់លាស់នៃកាលៈទេសៈដែលនាំឲ្យមានការប្រព្រឹត្ត

ឧក្រិដ្ឋកម្មសាហាវយង់ឃ្នង ដើម្បីកុំឲ្យឧក្រិដ្ឋកម្មទាំងនេះត្រូវបានប្រព្រឹត្តឡើងជាថ្មីម្តងទៀត ចាសសូម អរគុណ។

[១៥:៥៨:០៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ឥឡូវនេះ សវនាការនៅថ្ងៃនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃសុក្រ ទី១៦ ខែមិថុនា ឆ្នាំ២០១៧ ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលលើសំណុំរឿង ០០២ ដែលនឹងផ្តើមធ្វើដោយក្រុមមេធាវីការពារក្តី លោក នួន ជា សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន និងលោក នួន ជា ត្រឡប់ទៅកាន់មន្ទីរឃុំឃាំង អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៥:៥៩ នាទី)*